# សាកលវិទ្យាល័យភូមិន្ទកសិកម្ម

ROYAL UNIVERSITY OF AGRICULTURE

## មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី

FACUTLY OF LAND MANAGMENT AND LAND ADMINISTRATION

ថោន បញ្ញាវត្តី

THON PANHAVATEY


# ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ ក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប

# THE DISSEMINATION PROCEDURE OF SYSTEMATIC LAND REGISTRATION PROCESS IN SANGKAT KOUK CHAK, KRONG SIEM REAP, SIEM REAP PROVINCE


ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី ១០
( ២០១១-២០១៥ )

សារណាបញ្ចប់ការសិក្សា
រាជធានីភ្នំពេញ. ខែកញ្ញា ឆ្នាំ២០១៥

# សាកលវិទ្យាល័យភូមិន្ទកសិកម្ម

ROYAL UNIVERSITY OF AGRICULTURE

មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី

FACULTY OF LAND MANAGEMENT AND LAND ADMINISTRATION

**សារណាបទ**

THESIS

# ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ ក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប

# THE DISSEMINATION PROCEDURE OF SYSTEMATIC LAND REGISTRATION PROCESS IN SANGKAT KOUK CHAK, KRONG SIEM REAP, SIEM REAP PROVINCE


ថោន បញ្ញាវត្តី

THON PANHAVATEY


សារណាបទថ្នាក់បរិញ្ញា ជំនាន់ទី ១០

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**
**មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី**


ថោន បញ្ញាវត្តី
THON PANHAVATEY


# ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ ក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប

THE DISSEMINATION PROCEDURE OF SYSTEMATIC LAND REGISTRATION PROCESS IN SANGKAT KOUK CHAK, KRONG SIEM REAP, SIEM REAP PROVINCE

**សមាសភាពគណៈមេប្រយោគ**

ប្រធានគណៈមេប្រយោគ ៖ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ចៅ ម៉ុនថាន**
ព្រឹទ្ធបុរសរង ៖ **លោកស្រី បេង ម៉ុននេត**
អ្នកដឹកនាំ ៖ **លោក សំ សុមនោ**
អ្នកជំនួយការ ៖ **លោក វឹង សេដ្ឋា**
៖ **លោក ពិន សុខខន**

ជំនាន់ទី១០
(២០១១-២០១៥)

សារណាបញ្ចប់ការសិក្សា
រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១៥

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**
មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី

# សារណាបទ
THESIS

# ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធ ក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប

STUDY ON THE DISSEMINATION PROCEDURE OF SYSTEMATIC LAND REGISTRATION PROCESS IN SANGKAT KOUK CHAK, KRONG SIEM REAP, SIEM REAP PROVINCE

**គណៈកម្មការសារណាបទ**

| | | | | |
|---|---|---|---|---|
| អ្នកដឹកនាំ | ៖ | **លោក** | **សំ សុមនោ** | ........................................ |
| អ្នកជំនួយការ | ៖ | **លោក** | **ទឹង សេដ្ឋា** | ........................................ |
| អ្នកជំនួយការ | ៖ | **លោក** | **ពិន សុខខន** | ........................................ |
| ព្រឹទ្ធបុរសរង | ៖ | **លោកស្រី** | **បេង ប៊ុននេត** | ........................................ |

**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**
**សាកលវិទ្យាធិការ**

## ការធានាអះអាងលើសារណាបទ

នាងខ្ញុំសូមធានាអះអាងថា រាល់ទិន្នន័យ ខ្លឹមសារ និងលទ្ធផលស្រាវជ្រាវនៅក្នុងស្នាដៃនៃសារណាបទនេះ ពិតជាមានលក្ខណៈវិទ្យាសាស្ត្រថ្មីមួយ ដែលមិនមែនជាស្នាដៃរបស់អ្នកដទៃទៀត ហើយក៏មិនត្រូវបានគេបោះពុម្ពផ្សព្វផ្សាយ ឬបង្ហាញឡើយ ។

រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ............ឆ្នាំ២០១៥

**ហត្ថលេខា**

**ថោន បញ្ញាវត្តី**

## សេចក្តីថ្លែងអំណរគុណ

ទូលបង្គំ **ថោន បញ្ញាវត្តី**

**សូមក្រាបថ្វាយបង្គំ**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

សូមថ្លែងព្រះអំណរព្រះគុណព្រះករុណាទិគុណ សម្តេចជាអង្គម្ចាស់ជីវិតលើត្បូង ដែលបានបំពេញនូវព្រះរាជបេសកកម្ម បង្រួបបង្រួមជាតិមាតុភូមិ ប្រទានសុខសន្តិភាព ដល់ប្រទេសជាតិ កូនចៅ ពិសេសប្រទានឱកាសដល់កូនចៅ និងទូលបង្គំបានសិក្សារហូតបានសម្រេចជោគជ័យ។ ទូលបង្គំសូមថ្វាយព្រះពរ សូមព្រះអង្គទ្រង់ព្រះចម្រើន ព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ដល់កូនចៅជំនាន់ក្រោយ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

- ថ្នាក់ដឹកនាំ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- ថ្នាក់ដឹកនាំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តសៀមរាប
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី
- មជ្ឈមណ្ឌលឯកសារ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

ដែលបានអនុញ្ញាត និង ផ្តល់លទ្ធភាពដល់រូបនាងខ្ញុំឲ្យបានសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវចំណេះដឹងផ្នែកវិទ្យាសាស្ត្រទាំងឡាយ ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ និងជួយផ្តល់ឯកសារស្រាវជ្រាវវិទ្យាសាស្ត្រក្នុងរយៈពេលចុះកម្មសិក្សារហូតទទួលបានជោគជ័យជាស្ថាពរ ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

- ឯកឧត្តម **អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាស្ត្រាចារ្យបណ្ឌិត **សុក គន្ធី** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាស្ត្រាចារ្យបណ្ឌិត **ម៉ែន សារុម** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាស្ត្រាចារ្យបណ្ឌិត **សេង មុំ** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- លោក **ទី ចាន់ណា** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

- សាស្ត្រាចារ្យរង **ទឹង សេដ្ឋា** ព្រឹទ្ធបុរស មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី
- លោកស្រី **មេង ម៉ុននេត** ព្រឹទ្ធបុរសរង មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី
- លោក **ម៉ៅ ណារ៉ា** ព្រឹទ្ធបុរសរង មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី
- លោក និងលោកស្រី សាស្ត្រាចារ្យទាំងអស់ នៃមហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី

ដែលបានបង្កលក្ខណៈងាយស្រួលដល់កាសិក្សា ជួយបង្ហាត់បង្រៀន ពន្យល់ណែនាំអស់ពីសមត្ថភាព និងជួយដាស់តឿន អប់រំគ្រប់បែបយ៉ាងក្នុងពេលសិក្សាកន្លងមកនេះ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

- លោក **សំ សុមនោ** ជាអ្នកដឹកនាំ
- លោក **ទឹង សេដ្ឋា** ជាអ្នកជំនួយការ
- លោក **ពិន សុខខន** ជាអ្នកជំនួយការ

ដែលបានជួយពិនិត្យ ពន្យល់ណែនាំ ចង្អុលបង្ហាញផ្លូវក្នុងការធ្វើសារណាបទនេះ ប្រព្រឹត្តទៅដល់ទីបញ្ចប់ប្រកបដោយជោគជ័យ និងពោរពេញដោយអត្ថន័យ និងខ្លឹមសារ។

**សូមថ្លែងនូវកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ**

- លោកតា **ញឹម គុជ**
- លោកឪពុក **ថោ ម៉ុនថោន**
- អ្នកមីង **ញឹម ធីរ៉ា**
- អ្នកមីង **ញឹម សុភៈ** និង លោកពូ **ពេជ្រ សុភ័ក្រ្តា**
- បងស្រី **ថោន ណានីដា** និង បងថ្លៃ **សេង ឆារ៉ា**
- ព្រមទាំង លោកពូ អ្នកមីង បងប្អូន សាច់ញាតិជិតឆ្ងាយ និងមិត្តភ័ក្រ្តិទាំងអស់

ដែលអ្នកទាំងអស់គ្នាបានខិតខំប្រឹងប្រែង និងជួយចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់ ទំនុកបំរុងអស់ពីកម្លាំងកាយចិត្ត និងសម្ភារៈគ្រប់បែបយ៉ាង ។ ផ្តល់ការអប់រំទូន្មានប្រៀនប្រដៅប្រកបដោយដំបូន្មានល្អៗ និងមានព្រហ្មវិហារធម៌គ្រប់បែបយ៉ាងដើម្បីជួយជំរុញដំណើរការសិក្សារបស់នាងខ្ញុំប្រព្រឹត្តទៅបានល្អប្រសើរ ហើយ ទីបំផុតនាងខ្ញុំបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យជាស្ថាពរ ។ គុណដ៏ថ្លៃថ្លារបស់លោកអ្នកមានគុណគឺមានតម្លៃ ដែលគ្មានអ្វីដែលអាចប្រៀបផ្ទឹម និងមិនអាចកាត់ថ្លៃបានទេ។

## សង្ខេបសារណាបទ

ប្រទេសកម្ពុជា ជាប្រទេសមួយកំពុងអភិវឌ្ឍន៍គ្រប់វិស័យនៅក្នុងចំណោមបណ្តាប្រទេសក្រីក្រទាំងឡាយនៅលើពិភពលោក ។ ដោយសារសង្គ្រាមបានអូសបន្លាយរយៈពេលជាងពីរទសវត្សរ៍កន្លងមកហើយ នេះបានធ្វើឲ្យការកាន់កាប់ដីរបស់ប្រជាពលរដ្ឋ មិនមានភាពច្បាស់លាស់ជាម្ចាស់កម្មសិទ្ធិ ។ ដូចនេះហើយទើប រាជរដ្ឋាភិបាលបានបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើងដើម្បីធ្វើកំណែទំរង់ដីធ្លី ធានានូវសុវត្ថិភាព នៃការកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ រួមចំណែកកាត់បន្ថយភាពក្រីក្រ ជំលោះដីធ្លី និងដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការចុះបញ្ជីដីធ្លី និង ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ។

នៅក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធជាសង្ខេបមាន ៥ ដំណាក់កាលគឺ : ១- ដំណាក់កាលត្រៀមរៀបចំ ២- ដំណាក់កាលប្រតិបត្តិការបច្ចេកទេស ៣- ដំណាក់កាលបិទផ្សាយជាសាធារណៈនូវឯកសារនៃការ វិនិច្ឆ័យ ៤- ដំណាក់កាលសំរេចលើឯកសារនៃការវិនិច្ឆ័យ ( ប្លង់សុរិយោដី និង បញ្ជីឈ្មោះម្ចាស់ដី ) ៥- ដំណាក់កាលចេញប័ណ្ណ និងចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ។

ដំណាក់កាលទាំង ៥ នេះ ដំណាក់កាលត្រៀមរៀបចំ ទាមទារឲ្យមានការជួបប្រជុំផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ គឺធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ និងការផ្លាស់ប្តូរផ្ទេរសិទ្ធិនាពេលខាងមុខ។ ដូចនេះហើយទើបនាងខ្ញុំធ្វើការសិក្សាស្រាវជ្រាវស្តីអំពី "ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប " ដែលមានគោលបំណងពីរ៖

១. ការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

២. ការលំបាករបស់ប្រជាពលរដ្ឋ ក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

សំរាប់ការសិក្សានេះនាងខ្ញុំបានជ្រើសរើសនូវ សង្កាត់គោកចក មកធ្វើការស្រាវជ្រាវ ដែលក្នុងនោះបានកំណត់យកភូមិចំនួនពីរមកស្រាវជ្រាវគឺ ភូមិត្រពាំងសេះ និងភូមិទក្សិណខាងត្បូង ដែលមានប្រជាពលរដ្ឋចំនួន ៥៨ គ្រួសារ គឺជាចំនួនសំណាកដែលបានគណនា។

តាមលទ្ធផលវិភាគបង្ហាញអោយឃើញថា ក្នុងចំណោមសំណាក ៥៨ គ្រួសារប្រជាពលរដ្ឋដែលបានសម្ភាសន៍ ភាគច្រើនជាស្ត្រី ដែលមានចំនួន ៤៣ គ្រួសារស្មើនឹង ៧៤ ភាគរយ ចំណែកបុរសវិញ គឺមានតែ ១៥ គ្រួសារស្មើនឹង ២៦ ភាគរយ។ ជាមួយគ្នានោះប្រជាពលរដ្ឋ ២០ គ្រួសារស្មើនឹង ៣៤ ភាគរយនៃចំនួនសំណាកសរុបប៉ុណ្ណោះដែលបានរៀនត្រឹមបឋមសិក្សា ហើយក្នុងនោះមានគ្រួសារចំនួន ១១ គ្រួសារស្មើនឹង ២០ ភាគរយដែលបានរៀនត្រឹមអនុវិទ្យាល័យ ហើយមាន ១០ គ្រួសារស្មើនឹង ១៧ ភាគរយ ដែលបានរៀនត្រឹមវិទ្យាល័យ និងមានប្រជាពលរដ្ឋរៀនដល់មហាវិទ្យាល័យចំនួន ១៧ គ្រួសារស្មើនឹង ២៩ ភាគរយនៃចំនួនសំណាកសរុប។

ក្នុងចំណោមប្រជាពលរដ្ឋ ៥៨ គ្រួសារ មាន ២២ គ្រួសារស្មើនឹង ៣៨ ភាគរយទទួលបានព័ត៌មានអំពីការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធពីប្រជាពលរដ្ឋដែលបានមកចូលរួមប្រជុំក្នុងភូមិជាមួយមន្រ្តីផ្សព្វផ្សាយ ចំណែកប្រជាពលរដ្ឋចំនួន ៣០ គ្រួសារស្មើនឹង ៥២ ភាគរយទទួលព័ត៌មានបានពីមន្រ្តីផ្សព្វផ្សាយ ដែលបានផ្សព្វផ្សាយព័ត៌មាននៅក្នុងភូមិ ហើយចំនួន ៦ គ្រួសារទៀតស្មើនឹង ១០ ភាគរយបានដឹងពីអាជ្ញាធរដែនដី (មេភូមិ ចៅសង្កាត់) ដូចនេះប្រជាពលរដ្ឋបានយល់ដឹង និងចូលរួមក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ។

ចំពោះការផ្សព្វផ្សាយស្តីអំពីនីតិវិធីក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ មានប្រជាពលរដ្ឋចំនួន ៤៥ គ្រួសារស្មើនឹង ៧៨ ភាគរយពេញចិត្តនឹងការផ្សព្វផ្សាយរបស់មន្រ្តីផ្សព្វផ្សាយ រីឯប្រជាពលរដ្ឋចំនួន ១០ គ្រួសារ

ស្មើនឹង ១៧ ភាគរយ មិនសូវពេញចិត្ត និងប្រជាពលរដ្ឋចំនួន ៣ គ្រួសារស្មើនឹង ៥ ភាគរយ មិនមានយោបល់អ្វីទាំងអស់។

លទ្ធផលបង្ហាញអោយឃើញថាមានប្រជាពលរដ្ឋ ៩៥ គ្រួសារ ស្មើនឹង ៩៥ ភាគរយ យល់ថាការផ្សព្វផ្សាយមានសារៈសំខាន់ណាស់ពីព្រោះពួកគាត់បានទទួលការយល់ដឹងពីនីតិវិធី និងដំណើរការនៃការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធដោយបានត្រៀមរៀបចំឯកសារទុកជាមុន និងមកចូលរួមតាមការកំនត់របស់មន្ត្រី ។ ចំណែក ៣ គ្រួសារទៀតស្មើនឹង ៥ ភាគរយមិនសូវខ្វល់ និងមិនយល់អំពីការផ្សព្វផ្សាយនេះទេ ហើយពួកគាត់គិតថាវាគ្មានសារៈសំខាន់។

តាមរយៈការសិក្សាលើប្រធានបទនេះ យើងអាចធ្វើការសន្និដ្ឋានបានថា ការផ្សព្វផ្សាយអំពីនីតិវិធីនៃដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈ បានចូលរួមចំណែកបំពេញបន្ថែមទៅលើកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ក្នុងការកាន់កាប់ដីធ្លី មានឆន្ទៈក្នុងការចូលរួមចុះបញ្ជីដីធ្លី និងយល់ដឹងអំពីសារៈប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ ដែលអាចលើកស្ទួយជីវភាពរស់នៅរបស់ពួកគាត់ និងការអភិវឌ្ឍន៍សង្គមជាតិនាពេលអនាគត ។

# Abstract

Cambodia is a country developing in all fields among the poorest countries in the world. Because the war has lasted for more than two decades ago, this was the land of the people do not have clear ownership. So that is why the government created the Ministry of Urban Planning and Construction to land reform to ensure the security of tenure of the people contributing to poverty reduction and land disputes in order to improve the living standards of citizens through land registration and titling of land to citizens.

In the process of land registration system Summary 5 stages are: 1. The preparatory phase, 2-phase 3-phase technical operations post public documents of the 4-phase decision on criteria of judgment (cadastral and registry landowners) 5. Issuance phase and to citizens Title.

Stage 5 preparatory stage requires meeting widely spread out to people is to give citizens a better understanding of the process of land registration are in the interests of the system and change titles upcoming transfer. Research like this is why I am working on "The promotion of land registration procedures in Chak district, Siem Reap," which has two objectives:

1. Awareness and participation of citizens in the process of land registration system

2. The difficulties of the people in the process of land registration system

For this study, I have chosen the neighborhood Chak research in which the two villages Research Horse Village South and Southern village, which has a population of some 58 families is the number of samples calculated.

The analytical results show that among a sample of 58 families interviewed are women, accounting for 43 families or 74 percent, while men are only 15 families or 26 percent. Meanwhile, residents of 20 families or 34 percent of the sample total only one to learn, primary and including the families of 11 families or 20 percent, who learned only secondary, and there are 10 families or 17 percent, have learned high school and people learn to college some 17 families or 29 percent of the sample population.

Among residents, 58 families have 22 families or 38 percent get information about land registration of the property from people who came to attend the meeting the village with officers media whereas 30 families accounting for 52 percent received information from officials media disseminated information in the village, and 6 families about 10 percent are aware of local authorities (chiefs grandchildren war limited), so people understand and participate in land registration in the nature of the system.

For the media regarding the procedures in land registration of the property, there are some 45 families or 78 percent satisfied with the promotion of the officer promotions, while some 10 families or 17 percent less satisfied and citizens of 3 families, equivalent to 5 per cent do not have a comment at all.

The results show that people 55 families or 95 percent understand that the media is very important because they have an understanding of the procedures and the process of registration of the property by the preparatory documents in advance and to attend to a limited their officials.

. 3 family contribution equal to 5 percent less care and do not understand about this and they think it's not important

Through studies on the subject, we can conclude that the promotion procedure of the registration process, land features have contributed complement to the level of awareness of the people in the land are willing to participate in land registration and awareness about importance of titles that can boost their livelihood and development of society in the future.

# បញ្ជីមាតិកា

ទំព័រ

សេចក្តីថ្លែងអំណរគុណ........i
សង្ខេបសារណារបទ........iii
បញ្ជីមាតិកា........vi
បញ្ជីវិចិត្ររូប........ix
បញ្ជីអក្សរកាត់........xi

## ជំពូក ១ សេចក្តីផ្តើម

១.១ លក្ខណៈទូទៅ........១
១.២ មូលហេតុនៃការសិក្សាស្រាវជ្រាវ........២
១.៣ គោលបំណងនៃការសិក្សា........២
១.៤ ទំហំនៃការសិក្សាស្រាវជ្រាវ........២

## ជំពូក ២ សំយោគឯកសារ

២.១ ប្រវត្តិនៃការកាន់កាប់ដីធ្លីនៅកម្ពុជា........៣
២.២ ការចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា........៦
២.២.១ ការចុះបញ្ជីដីធ្លីមុនឆ្នាំ១៩៨៩........៦
២.២.២ ការចុះបញ្ជីដីធ្លីក្រោយឆ្នាំ១៩៨៩........៧
២.៣ ការចុះបញ្ជីដីធ្លី........៧
២.៣.១ ការចុះបញ្ជីដំបូង........៧
២.៣.២ ការចុះបញ្ជីបន្ត........៨
២.៤ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ........៨
២.៤.១ តំណាក់កាលត្រៀមរៀបចំ........៨
២.៤.២ តំណាក់កាលប្រតិបត្តិការបច្ចេសទេស........១០
២.៤.៣ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ........១១
២.៤.៤ ការសម្រេចលើឯកសារនៃការវិនិច្ឆ័យ........១៣
២.៤.៥ ដំណាក់កាលចែកវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ........១៤

## ជំពូក ៣ វិធីសាស្ត្រសិក្សាស្រាវជ្រាវ

៣.១ ការជ្រើសរើសទីតាំងសិក្សា........១៦
៣.២ សម្ភារៈ និងមធ្យោបាយធ្វើដំណើរ........១៦
៣.២.១ សម្ភារៈសម្រាប់ការងារវាល........១៦
៣.២.២ សម្ភារៈសម្រាប់ការងារការិយាល័យ........១៦
៣.២.៣ មធ្យោបាយធ្វើដំណើរ........១៦
៣.៣ ការជ្រើសរើសសំណាក........១៧

៣.៣.១ ការជ្រើសរើសសំណាកតាមគោលបំណង ...... ១៧
៣.៣.២ ការជ្រើសរើសសំណាកដោយចៃដន្យ ...... ១៨
៣.៣.៣ វិធីសាស្ត្រគណនាសំណាក ...... ១៩
៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ ...... ១៩
៣.៤.១ ទិន្នន័យមានស្រាប់ ...... ១៩
៣.៤.២ ទិន្នន័យបឋម ...... ២០
៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ ...... ២០
៣.៥.១ ការវិភាគទិន្នន័យតាមកម្មវិធី Microsoft Excel ...... ២០
៣.៥.២ ការវិភាគទិន្នន័យបែប SWOT ...... ២០
៣.៦ ដំណើរការនៃការចុះអង្កេត ...... ២១

## ជំពូក ៤ លទ្ធផល និងការពិភាក្សា

៤.១ ស្ថានភាពទូទៅនៅតំបន់សិក្សា ...... ២៣
៤.១.១ ស្ថានភាពទូទៅខេត្តសៀមរាប ...... ២៣
៤.១.២ ទីតាំងភូមិសាស្ត្រក្នុងក្រុងសៀមរាប ...... ២៥
៤.២ ស្ថានភាពភូមិសាស្ត្រសង្កាត់គោកចក ...... ២៧
៤.៣ ការកំណត់តំបន់ធ្វើការវិនិច្ឆ័យ ...... ២៩
៤.៣.១ ការជ្រើសរើសតំបន់វិនិច្ឆ័យ ...... ២៩
៤.៣.២ តំបន់ធ្វើការវិនិច្ឆ័យ ...... ២៩
៤.៤ ការរៀបចំផែនការក្នុងតំបន់វិនិច្ឆ័យ និងនៅថ្នាក់ភូមិ ...... ៣០
៤.៤.១ គោលបំណងនៃការផ្សព្វផ្សាយ ...... ៣០
៤.៤.២ តួនាទី និងភារកិច្ចរបស់មន្ត្រីផ្សព្វផ្សាយ ...... ៣១
៤.៤.៣ កាតព្វកិច្ចរបស់ម្ចាស់ដី និងអ្នកកាន់កាប់ដី ...... ៣២
៤.៥ ការងារចម្បងរបស់មន្ត្រីផ្សព្វផ្សាយ ...... ៣៣
៤.៥.១ ការរៀបចំជាមុននៅការងាររដ្ឋបាលរបស់មន្ត្រីផ្សព្វផ្សាយ ...... ៣៣
៤.៥.២ ការពិភាក្សាជាមួយរដ្ឋអំណាចមូលដ្ឋានអំពីស្ថានភាពបន្ទុប្បន្ន ...... ៣៤
៤.៥.៣ ការប្រមូលទិន្នន័យពីអាជ្ញាធរមូលដ្ឋាន ...... ៣៥
៤.៦ សកម្មភាពរបស់មន្ត្រីផ្សព្វផ្សាយចុះអនុវត្តជាក់ស្តែងនៅតាមភូមិ ...... ៣៦
៤.៦.១ ប្រមូលទិន្នន័យប្រវត្តិដីភូមិ ...... ៣៦
៤.៦.២ កិច្ចសម្ភាសន៍ជាមួយមេភូមិ ...... ៣៦
៤.៧ ការជួបពិភាក្សាជាមួយក្រុមគោលដៅ ...... ៣៧
៤.៨ ការផ្សព្វផ្សាយជាមួយក្រុមបុរស និងស្ត្រី ...... ៣៧
៤.៩ ការផ្សព្វផ្សាយជាមួយក្រុមពិសេស ...... ៣៨
៤.១០ ដំណើរការនៃការផ្សព្វផ្សាយ ...... ៣៨
៤.១១ ព័ត៌មានទូទៅរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់គោកចក ...... ៤០

៤.១១.១ ចំនួនអ្នកផ្តល់បទសម្ភាសន៍ ..................................................................... ៤០
៤.១១.២ ស្ថានភាពនៅក្នុងគ្រួសាររបស់ប្រជាពលរដ្ឋ ..................................................................... ៤១
៤.១១.៣ កម្រិតវប្បធម៌របស់ប្រជាពលរដ្ឋ ..................................................................... ៤១
៤.១១.៤ ប្រភពព័ត៌មាននៃការចុះបញ្ជីដីធ្លីការ ..................................................................... ៤២
៤.១១.៥ ការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះការផ្សព្វផ្សាយ ..................................................................... ៤៤
៤.១១.៦ ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលត្រៀមរៀបចំ ..................................................................... ៤៥
៤.១១.៧ ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលប្រតិបត្តិការបច្ចេសទេស ..................................................................... ៤៦
៤.១១.៨ ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលបិទផ្សាយឯកសារ ..................................................................... ៤៧
៤.១១.៩ ដំណាក់កាលសម្រេចលើឯកសារ ..................................................................... ៤៨
៤.១១.១០ ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលចេញប័ណ្ណ ..................................................................... ៤៨
៤.១១.១១ តម្លៃសេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ..................................................................... ៤៩
៤.១១.១២ ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ ..................................................................... ៥០
៤.១១.១៣ ការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះដីដែលមានប័ណ្ណ និងដីដែលគ្មានប័ណ្ណកម្មសិទ្ធិ ..................................................................... ៥១
៤.១២ បញ្ហាជួបប្រទះនៅក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ..................................................................... ៥២
៤.១៣ ការពិភាក្សា ..................................................................... ៥៣

**ជំពូក ៥ សន្និដ្ឋាន និងអនុសាសន៍**

៥.១ សន្និដ្ឋាន ..................................................................... ៥៥
៥.២ អនុសាសន៍ ..................................................................... ៥៦

**បណ្ណាល័យសាស្ត្រ**

**ឧបសម្ព័ន្ធ**

**ព្រឹត្តិប័ត្រព័ត៌មាននិស្សិត**

# បញ្ជីវិចិត្ររូប


| ល.រ | លេខលំដាប់ | | ចំណងជើង | ទំព័រ |
|---|---|---|---|---|
| | | | **តារាង** | |
| ០១ | តារាងទី ៣.១ | ៖ | ចំនួនមន្ត្រីអាជ្ញាធរនៅមូលដ្ឋានដែលត្រូវសម្ភាសន៍តាមគោលបំណង | ១៧ |
| ០២ | តារាងទី ៣.២ | ៖ | ចំនួនគ្រួសាររបស់ប្រជាពលរដ្ឋក្នុងភូមិនៃសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប | ១៨ |
| ០៣ | តារាងទី ៣.៣ | ៖ | ចំនួនសំណាកដែលត្រូវជ្រើសរើសក្នុងការសម្ភាសន៍តាមភូមិនីមួយៗ | ១៩ |
| ០៤ | តារាងទី ៣.៤ | ៖ | តារាងវិភាគ SWOT | ២២ |
| ០៥ | តារាងទី ៤.៥ | ៖ | សង្ខេបពីការផ្សព្វផ្សាយជាទូទៅក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ | ៣៩ |
| ០៦ | តារាងទី ៤.៦ | ៖ | សង្ខេបពីការផ្សព្វផ្សាយតាមរយៈ PACP | ៤០ |
| ០៧ | តារាងទី ៤.៧ | ៖ | សង្ខេបពីការផ្សព្វផ្សាយក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ | ៤០ |
| ០៨ | តារាងទី ៤.៨ | ៖ | ភាគរយនៃការផ្តល់បទសំភាសន៏ | ៤១ |
| ០៩ | តារាងទី ៤.៩ | ៖ | ភាគរយនៃកម្រិតវប្បធម៌របស់ប្រជាពលរដ្ឋ | ៤២ |
| ១០ | តារាងទី ៤.១០ | ៖ | ប្រភពព័ត៌មានស្តីពីការចុះបញ្ជីដីធ្លី | ៤៣ |
| ១១ | តារាងទី ៤.១១ | ៖ | ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះការផ្សព្វផ្សាយ | ៤៤ |
| ១២ | តារាងទី ៤.១២ | ៖ | ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលត្រៀមរៀបចំ | ៤៥ |
| ១៣ | តារាងទី ៤.១៣ | ៖ | ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលបច្ចេសទេស | ៤៧ |
| ១៤ | តារាងទី ៤.១៤ | ៖ | ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលបិទផ្សាយ | ៤៧ |
| ១៥ | តារាងទី ៤.១៥ | ៖ | ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលចេញប័ណ្ណ | ៤៩ |
| ១៦ | តារាងទី ៤.១៦ | ៖ | ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ នៃតំលៃសេវាក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ | ៥០ |
| ១៧ | តារាងទី ៤.១៧ | ៖ | ភាគរយនៃយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើផលប្រយោជន៏នៃប័ណ្ណកម្មសិទ្ធិ | ៥១ |
| ១៨ | តារាងទី ៤.១៨ | ៖ | ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ចំពោះដីដែលមានប័ណ្ណ និងដីដែលគ្មានប័ណ្ណ | ៥២ |
| | | | **ផែនទី** | |
| ១៩ | ផែនទី ៤.១ | ៖ | ផែនទីរដ្ឋបាលខេត្តសៀមរាប | ២៤ |
| ២០ | ផែនទី ៤.២ | ៖ | ផែនទីក្រុងសៀមរាប | ២៦ |
| ២១ | ផែនទី ៤.៣ | ៖ | ផែនទីសង្កាត់គោកចក | ២៨ |

## ដ្យាក្រាម និងក្រាហ្វិច


២២ ដ្យាក្រាមទី ១ ៖ ភាគរយនៃការផ្តល់បទសំភាសន៏.................................................................៤១

២៣ ដ្យាក្រាមទី ២ ៖ ភាគរយនៃកម្រិតវប្បធម៌របស់ប្រជាពលរដ្ឋ..................................................... ៤២

២៤ ដ្យាក្រាមទី ៣ ៖ ភាគរយនៃប្រភពព័ត៌មានស្តីពីការចុះបញ្ជីដីធ្លី ............................................. ៤៣

២៥ ដ្យាក្រាមទី ៤ ៖ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះការផ្សព្វផ្សាយ .........................៤៤

២៦ ដ្យាក្រាមទី ៥ ៖ ភាគរយនៃការយល់ដឹងររបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលរៀបចំ....................៤៥

២៧ ដ្យាក្រាមទី ៦ ៖ ភាគរយការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើការដំណាក់កាលបច្ចេសទេស ......៤៦

២៨ ដ្យាក្រាមទី ៧ ៖ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលបិទផ្សាយ................៤៨

២៩ ដ្យាក្រាមទី ៨ ៖ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការចេញប័ណ្ណ............................៤៩

៣០ ដ្យាក្រាមទី ៩ ៖ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ នៃតំលៃសេវាក្នុងការចុះបញ្ជីដីធ្លីមាន លក្ខណៈជាប្រព័ន្ធ..........................................................................................................៥០

៣១ ដ្យាក្រាមទី ១០ ៖ ការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើផលប្រយោជន៏នៃប័ណ្ណកម្មសិទ្ធិ..............៥១

៣២ ដ្យាក្រាមទី ១១ ៖ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ចំពោះដីដែលមានប័ណ្ណ និងដីដែលគ្មានប័ណ្ណ ............................................................................ ៥២


## គំនូសបំព្រួញ


៣៣ គំនូសបំព្រួញទី ៣.១ ៖ ដំណើរការនៃការចុះអង្កេត ................................................................ ២១

## បញ្ជីអក្សរកាត់

| ពាក្យសរសេរកាត់ | | ការពន្យល់ |
|---|---|---|
| ក្រសួង ដ ន ស | : | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| មន្ទីរ ដនសស | : | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី |
| ការិ. ដ ន ស ភ | : | ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាល |
| ស.វ.ភ.ក | : | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| គម២ | : | គីឡូម៉ែត្រការ៉េ |
| % | : | ភាគរយ |
| NLSF | : | National Land Survey of Finland |
| CMLRPP | : | Cadastral Mapping and Land Registration Pilot Project |
| CCP | : | Cambodian Cadastral Project |
| GTZ | : | German Technical |
| Ms. Excel | : | Microsoft Excel |
| SWOT | : | Strengths, Weakness, Opportunities, Threats |
| PACP | : | Public Awareness Community Participation |

# ជំពូក ១
# សេចក្តីផ្តើម

# ជំពូក ១

# សេចក្តីផ្តើម

## ១.១ លក្ខណៈទូទៅ

ក្នុងបណ្តាប្រទេសជាច្រើនលើពិភពលោក មួយភាគធំនៃសកម្មភាពសេដ្ឋកិច្ច ត្រូវពឹងផ្អែកទៅលើវិស័យឧស្សាហកម្មដោយឡែកប្រទេសកម្ពុជា សកម្មភាពមួយភាគធំត្រូវពឹងផ្អែកទៅលើវិស័យកសិកម្ម។ មូលដ្ឋានគ្រឹះដ៏រឹងមាំនៃវិស័យកសិកម្មនោះគឺ ដីធ្លីដែលជាសក្តានុពល និងជាមធ្យោបាយផលិតកម្មមួយយ៉ាងសំខាន់មិនអាចអត់បាន។ ហេតុនេះហើយរដ្ឋចាំបាច់ត្រូវធ្វើការគ្រប់គ្រងដីឲ្យបានល្អ ដើម្បីងាយស្រួលក្នុងការធ្វើផែនការអភិវឌ្ឍន៍នានា ការវិនិយោគ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ មិនតែប៉ុណ្ណោះការគ្រប់គ្រងដីឲ្យបានល្អ គឺអាចធ្វើឲ្យ សង្គមមានស្ថេរភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ថែមទាំងជម្រុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងការទាញ យកផលប្រយោជន៍ពីដីទៀតផង។ ដូច្នេះហើយរដ្ឋទាមទារចាំបាច់ត្រូវចុះបញ្ជីក្បាលដីទាំងអស់ ទាំងដីឯកជន និងដីរដ្ឋចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី។

ហេតុនេះដើម្បីជួយប្រជាពលរដ្ឋឲ្យមានការលំបាកតិចតួចបំផុត ហើយព្រមទាំងចំណាយថវិកាតិចនោះ រដ្ឋាភិបាលបានធ្វើកិច្ចសហប្រតិបត្តិការបច្ចេកទេស ជាមួយបណ្តាប្រទេសជឿនលឿនមួយចំនួនដូចជា ប្រទេសអាឡឺម៉ង់ ហ្វាំងឡង់ និងកាណាដា ដើម្បីធ្វើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ ក្នុងគោលបំណងធានានូវសុវត្ថិភាពនៃការកាន់កាប់ ប្រើប្រាស់ដីធ្លី និងកាត់បន្ថយទំនាស់ដីធ្លី ព្រមទាំងលើកស្ទួយកម្រិតជីវភាពរបស់ប្រជាពលរដ្ឋដោយពួកគាត់អាចយក ទៅប្រើប្រាស់ក្នុងការ ដាក់បញ្ចាំ ហ៊ីប៉ូតែក ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រដើម្បីជម្រុញឲ្យប្រទេសជាតិមានសុខសន្តិភាព ស្ថេរភាពសង្គម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។

ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ត្រូវបានអនុវត្តតាមនីតិវិធីជាធរមានដោយយោងតាមអនុក្រឹត្យលេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីអំពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងសារាចរណែនាំលេខ ០០១ ដនស/សជ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ កំណត់លម្អិតអំពីដំណាក់កាលនីមួយៗនៃការចុះបញ្ជីដីធ្លីនូវក្នុងដំណើការអនុវត្តជាក់ស្តែងលើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

## ១.២ មូលហេតុនៃការសិក្សា

ថ្វីបើកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី (LASSP) ខិតខំពង្រឹងការអនុវត្តន៍ការងារយ៉ាងណាក៏ដោយ ក៏នៅតែមានបញ្ហាចោទនៅឡើយ។ ជាក់ស្តែងដំណើរការផ្សព្វផ្សាយនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ជាជំហ៊ានដំបូងក្រោយពីតំបន់វិនិច្ឆ័យត្រូវបានប្រកាសបើករួចហើយ មន្ត្រីផ្សព្វផ្សាយត្រូវធ្វើការផ្សព្វផ្សាយ ឲ្យប្រជាពលរដ្ឋបានយល់ដឹងពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ សិទ្ធិ កាតព្វកិច្ច ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ និងផែនទីភូមិទាំងដីឯកជន និងដីសាធារណៈរដ្ឋមកចូលរួមឲ្យបានគ្រប់គ្នាក្នុងដំណើរការចុះបញ្ជីដីធ្លី មានលក្ខណៈជាប្រព័ន្ធនេះ។

ដោយយល់ឃើញនូវសារៈសំខាន់នៃការផ្សព្វផ្សាយក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ប្រធានបទមួយត្រូវបានលើកយកមកធ្វើការសិក្សាគឺៈ " **ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប**"។

## ១.៣ គោលបំណងនៃការសិក្សា

ការសិក្សាទៅលើប្រធានបទ "ការសិក្សាអំពី **ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប** មានគោលបំណងសំខាន់ពីរដូចខាងក្រោមៈ

១. ការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

២. ការលំបាករបស់ប្រជាពលរដ្ឋ ក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

## ១.៤ ទំហំនៃការសិក្សា

ដើម្បីឆ្លើយតបទៅ នឹងគោលបំណងខាងលើនៃការសិក្សាស្រាវជ្រាវដែលមានរយៈពេលខ្លី ដូចនេះការសិក្សានេះត្រូវធ្វើឡើងដោយផ្តោតលើតែតំបន់ដែលធ្វើការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ដូចនេះនាងខ្ញុំសម្រេចយកសង្កាត់គោកចកនេះយកមកធ្វើការសិក្សាស្រាវជ្រាវ។ មួយវិញទៀតដើម្បីឲ្យការសិក្សាស្រាវជ្រាវលើប្រធានបទនេះទទួលបានលទ្ធផលល្អ នាងខ្ញុំបានកំណត់យកភូមិចំនួន ២ ក្នុងសង្កាត់គោកចក មកធ្វើការស្រាវជ្រាវរកទិន្នន័យដែលទាក់ទង នឹងគោលបំណងទាំងពីរខាងលើ ភូមិនោះរួមមាន ៖ ភូមិត្រពាំងសេះ និងភូមិទក្សិណខាងត្បូង ដែលនាំឲ្យមានភាពងាយស្រួលក្នុងការចុះប្រមូលទិន្នន័យ ក៏ដូចជាធ្វើបទសំភាសន៍ជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរដែលពាក់ព័ន្ធ។

ដើម្បីធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ ចាំបាច់ត្រូវទៅកាន់មូលដ្ឋានផ្ទាល់ ដើម្បីចុះប្រមូលព័ត៌មាន។ ដោយអាស្រ័យទៅលើពេលវេលាមានកំណត់របស់សាលា ដូចនេះការសិក្សាត្រូវបានធ្វើឡើងនៅសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។ ការសិក្សាស្រាវជ្រាវ គឺផ្តោតទៅលើកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ចំពោះដំណាក់កាលនីមួយៗនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

# ជំពូក ២
# សំយោគឯកសារ

# ជំពូក ២

# សំយោគឯកសារ

## ២.១ ប្រវត្តិនៃការកាន់កាប់ដីធ្លីនៅកម្ពុជា

តាមប្រវត្តិសាស្ត្រប្រទេសកម្ពុជា សិទ្ធិលើកម្មសិទ្ធិដីធ្លីមានលក្ខណៈផ្សេងៗគ្នា ទៅតាមការផ្លាស់ប្តូរនៃរបបនីមួយៗ។ តាមឯកសារស្តីពីប្រវត្តិសាស្ត្រកម្ពុជាដីធ្លីទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រង និងជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ។ ប៉ុន្តែតាមការអនុវត្តជាក់ស្តែង ដីធ្លីទាំងនេះជារបស់ប្រជាពលរដ្ឋ ដែលកាន់កាប់ដាំដំណាំលើដីនោះពោលគឺ កសិករទៅវិញទេដែលជាម្ចាស់លើដីនោះ។ ក្នុងអំឡុងពេលនោះសង្គមខ្មែរត្រូវបែងចែកជាវណ្ណៈផ្សេងៗគ្នា។ ក្រៅពីញាតិវង្សានុវង្ស គឺមានវណ្ណៈក្នុងសង្គមផ្សេងៗទៀតរួមមានក្សត្រា (អ្នកចម្បាំង) សមាជិកនៃក្រុមសាសនាផ្សេងៗ (ព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា សាសនាតៅ) អ្នកដែលមានសេរីភាព និងទាសាទាសី។ ការបែងចែកវណ្ណៈក្នុងសង្គមបានធ្វើឲ្យប្រជាជនមានសិទ្ធិខុសគ្នាអាស្រ័យទៅតាមវណ្ណៈរបស់ពួកគេ។ ដូច្នេះនៅពេលនិយាយសំដៅសិទ្ធិរបស់បុគ្គលក្នុងការកាន់កាប់ដីធ្លី យើងមិនអាចសន្និដ្ឋានបានថា បុគ្គលគ្រប់រូបមានសិទ្ធិដូចគ្នានោះទេ។ សិទ្ធិកាន់កាប់ដីធ្លីអាចមានចំពោះតែសមាជិកនៃវណ្ណៈមួយចំនួន ក្នុងសង្គមខ្មែរតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតនៅក្នុង ប្រទេសកម្ពុជាមុនការកាន់កាប់របស់បារាំង កម្មសិទ្ធិគឺ ជាសិទ្ធិចល័ត។ ម្ចាស់ដីដែលកំពុងធ្វើកសិកម្មអាចចាកចោលពីតំបន់មួយទៅចាប់ធ្វើកសិកម្មលើតំបន់មួយទៀត និងធ្វើម្ចាស់ដីនោះតាមឆន្ទៈ និងមិនចាំបាច់មានទម្រង់ការណាមួយឡើយ។ ប្រព័ន្ធជាប្រពៃណីនោះបានបន្តមរតករបស់ជាតិ តាមលក្ខខ័ណ្ឌនៃធនធានធម្មជាតិពីការធ្វើអាជីវកម្មដោយអ្នកដែលមកពីខាងក្រៅ។ ភាពដែលអាចផ្លាស់ប្តូរតាមកាលៈទេសៈ និងគ្មានទម្រង់ការនៃកម្មសិទ្ធិបានអនុញ្ញាតឲ្យមនុស្សជាច្រើន ធ្វើការលើដីធ្លីតាមឱកាសហុចឲ្យពេលណាក៏បាន។ ជាលើកដំបូងបារាំងបានដាក់អាណានិគមរបស់ខ្លួនមកលើប្រទេសកម្ពុជាក្នុងឆ្នាំ ១៨៦៣។ បារាំងបាននាំមកនូវទស្សនៈនៃរបបកម្មសិទ្ធិឯកជន។ ដើម្បីឲ្យកិច្ចការពាណិជ្ជកម្ម និងការវិនិយោគដំណើរការទៅបាននោះ ពួកគេត្រូវការធានាថា ដីធ្លីដែលពួកគេកាន់កាប់នោះគឺមានកិច្ចការពារជាផ្លូវការដោយរដ្ឋ។ ដូច្នេះគំនិតស្តីពីកម្មសិទ្ធិដីធ្លីបានមកជាមួយបារាំងដែលគំនិតនេះត្រូវបានគេស្គាល់នៅក្នុងបណ្តាប្រទេសភាគច្រើននៅសម័យឥឡូវនេះ។ ក្នុងឆ្នាំ ១៨៨៤ ជាលើកដំបូងបារាំងបានប្រកាសឲ្យប្រើនូវច្បាប់ដីធ្លីមួយនៅកម្ពុជា។ ប៉ុន្តែការផ្លាស់ប្តូរទាំងនេះបានជួបប្រទះនូវការតស៊ូប្រឆាំងតបយ៉ាងធ្ងន់ធ្ងរ ក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសក្នុងចំណោមវីរៈជន។ ដោយសារតែមានចលនាតស៊ូរបស់កសិករកម្ពុជា ទើបបានជាការកែទម្រង់ដីធ្លីមិនត្រូវបានគេអនុវត្តយ៉ាងពេញលេញមុនឆ្នាំ ១៩១២។ ក្នុងចំណោមរឿងដទៃៗទៀតនោះបារាំងចង់បានការផលិត និងកាន់កាប់ត្រួតត្រាដ៏រឹងមាំថែមទៀត មកលើប្រជាពលរដ្ឋកម្ពុជា។ ជាងនេះទៅទៀតនោះតំបន់ទំនេរគ្មានការកាន់កាប់ទាំងអស់បានក្លាយទៅជាទីផ្សារអាចលក់ដូរបាន។ ជាយថាហេតុ រឿងនេះបាននាំទៅរកការបង្កើតឲ្យមានឡើងនូវចំការដំណាំខ្នាតធំៗ។

ហេតុនេះទើបគោលការណ៍ច្បាស់លាស់នៃកម្មសិទ្ធិដីធ្លីក៏ត្រូវបានបង្កើតឡើងនៅក្នុងក្រមស៊ីវិលប្រទេសកម្ពុជាក្នុងឆ្នាំ ១៩២០ ។ ក្រមនេះបានចែងឲ្យមាននូវការបញ្ជាក់ ដោយលិខិត និងការកត់ត្រា នៃក្បាលដីជាក់លាក់ ។ ក្រោមប្រព័ន្ធនេះ ប័ណ្ណកម្មសិទ្ធិ ត្រូវបានគេចុះបញ្ជីជាប្រយោជន៍របស់កសិករម្នាក់ៗជាភស្តុតាងនៃកម្មសិទ្ធិ ការបង្ហាញថាជាអ្នកណាម្នាក់។ ការបង្ហាញអ្នកណាម្នាក់ជាម្ចាស់ដី គឺមានសំអាងគ្រប់គ្រាន់ ដូចជាការដៅព្រំប្រទល់ដីនិងធ្វើសកម្មភាពលើដីឡូត៍ជាក់ស្តែង នាអំឡុងពេលគ្រប់គ្រង និងចាត់ទុកជាភស្តុតាងកម្មសិទ្ធិគ្រប់គ្រាន់ ។ តាម

ពិតក្រមរដ្ឋប្បវេណីបានចែងយ៉ាងជាក់លាក់ពីលទ្ធកម្មនៃកម្មសិទ្ធិដីធ្លី ចំពោះដីដែលមិនបានចុះបញ្ជី ភោគីណាដែលកាន់កាប់ដោយ សន្តិភាព សុចរិត មានការដឹងឮជាសាធារណៈ គ្មានការបន្លំ ហើយដីនោះជាដីទំនេរ គ្មានបញ្ជីការ និងបានកាន់កាប់ជាប់ៗគ្នាសម្រាប់រយៈពេល ៥ ឆ្នាំ ភោគីនោះនឹងក្លាយជាកម្មសិទ្ធិករនៃដីនោះជាធរមាន។

គំនិតកម្មសិទ្ធិរបស់បរទេស គឺនៅតែមាននៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ ១៩៥៣ ហើយនៅចុងឆ្នាំ ១៩៦០ បញ្ហាជាច្រើននៅជនបទនៃប្រទេសកម្ពុជាមានកាន់តែធ្ងន់ធ្ងរឡើងៗ តាមរយៈចំនួនកំណើននៃកសិករដែលជាប់បំណុលគេ និងជាយថាហេតុនោះ គឺការគ្មានដីធ្លី។ ទោះជាយ៉ាងណា ក៏វាមិនដូចពីមុនឡើយ ព្រោះកសិករក្រីក្រត្រូវខ្ចីប្រាក់ទិញស្រូវក្នុងតម្លៃថ្លៃសម្រាប់សាបព្រួសលើដីស្រែរបស់ពួកគេ។ អ្នកក្រមិនមានច្រកទៅរកប្រព័ន្ធឲ្យខ្ចីការប្រាក់ជាផ្លូវការឡើយ ដូចជាធនាគារជាដើម។ ដូច្នេះពួកគេត្រូវខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជនដែលយកថ្លៃអត្រាការប្រាក់ប្រចាំខែយ៉ាងខ្ពស់រហូតដល់ ៣០ ភាគរយ ហើយជួនកាលដល់ទៅ ១០០-២០០ ភាគរយក្នុងមួយរដូវ។ សម្រាប់កសិករដែលក្រីក្រជាងគេបំផុតបញ្ហាខាងហិរញ្ញវត្ថុ គឺកាន់តែធ្ងន់ធ្ងរឡើងៗ ពីព្រោះពួកគេត្រូវលក់ស្រូវទាំងអស់ទៅឲ្យអ្នកដែលគេខ្ចីប្រាក់ដើម្បីសងបំណុលរបស់ខ្លួន។ តាមរបៀបនេះគ្មានស្រូវនៅសល់ដើម្បីចិញ្ចឹមគ្រួសារឡើយ ដោយហេតុនេះបានបង្ខំឲ្យពួកគេខ្ចីប្រាក់បន្ថែម និងទិញស្រូវត្រឡប់មកវិញ។ ប្រាក់កម្ចីត្រូវសងបន្ទាប់ពីផលដំណាំលើកក្រោយ។ កសិករមួយចំនួននៅទីបំផុតត្រូវលក់ដីដើម្បីសងបំណុលគេ ហើយក៏ក្លាយជាអ្នកគ្មានដី។ បច្ចាមិត្តរបស់អ្នកស្រែកម្ពុជា គឺអាចនិយាយបានថា ជាឈ្មួញទីក្រុងជាជាងម្ចាស់ដី។

សាធារណៈរដ្ឋខ្មែរត្រូវបានប្រកាសឡើង បន្ទាប់ពីសម្តេចនរោត្តមសីហនុ ត្រូវបានគេទម្លាក់ពីតំណែងដោយរដ្ឋប្រហារយោធានៅថ្ងៃទី ០៨ ខែមិនា ឆ្នាំ១៩៧០។ កម្មសិទ្ធិទ្រព្យសម្បត្តិឯកជនត្រូវបានបន្តទទួលស្គាល់ដោយរបបសាធារណរដ្ឋខ្មែរ។ អំឡុងពេលនៃប្រវត្តិសាស្ត្រកម្ពុជាពេលនោះបានក្លាយជាល្បីល្បាញថា ជាការទទួលការញាំញីយ៉ាងខ្លាំងដោយអំពើពុករលួយដែលបានជ្រាបចូលគ្រប់ស្រទាប់អាជ្ញាធររដ្ឋ និងរដ្ឋបាល។ ជាការកត់សម្គាល់ គឺថាអត្រាការប្រាក់ប្រចាំខែដែលទាមទារដោយអ្នកឲ្យខ្ចីប្រាក់ឯកជននៅកន្លែងជាច្រើនលើសពី ៣០ ភាគរយ។ នៅពេលនោះកម្ពុជាស្ថិតនៅក្រោមគោលនយោបាយនាយទុន បានជួបប្រទះនូវវិបត្តិខ្វះស្បៀងអាហារ ដោយសារតែតម្រូវការផ្គត់ផ្គង់អាហារច្រើននៅពេលដែលផលិតផលស្រូវថយចុះ។ តាមទិន្នន័យជាចំនួនតួលេខដោយលោក Porter and Hildebrand ការកាត់បន្ថយតំបន់ផលិតកម្មជាសរុបចំនួន ២.៤ លានហិកតា ក្នុងឆ្នាំ១៩៦៩ ទៅប្រហែលជាចំនួន ៥០០.០០០ ហិកតានៅក្នុងឆ្នាំ១៩៧៥។ ប្រជាពលរដ្ឋចំនួន ២លាននាក់ បោះបង់ចោលភូមិ និងដីស្រែរបស់ពួកគេស្វែងរកការជ្រកកោននៅទីក្រុង។ ប្រជាពលរដ្ឋនៅភ្នំពេញកើនពី ៥០០.០០០នាក់ នៅឆ្នាំ១៩៧០ ដល់ ២លាននាក់ នៅឆ្នាំ ១៩៧៤-៧៥ ។ គេជឿថាចំនួនប្រជាពលរដ្ឋមានចំនួនជិត ៣ លាននាក់ ពីព្រោះជនភៀសខ្លួនទាំងនោះមិនបានចុះបញ្ជី ហើយកាលនោះសហរដ្ឋអាមេរិកជាអ្នកផ្គត់ផ្គង់ស្បៀងដ៏សំខាន់ គិតជាប្រាក់ប្រហែលជិត ១.៩ ពាន់លានដុល្លាអាមេរិក។

ខ្មែរកុម្មុយនីស្តដែលគេស្គាល់ថា ជាខ្មែរក្រហមបានដណ្តើមអំណាចពី លន់ នល់ និងបានប្រកាសយកឆ្នាំ ១៩៧៥ ជាឆ្នាំសូន្យ។ អង្គការ គឺជាម្ចាស់ទឹកម្ចាស់ដី។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាមាន

រដ្ឋធម្មនុញ្ញដែលប្រកាសឲ្យប្រើជាផ្លូវការនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ១៩៧៦ ។ ប៉ុន្តែរដ្ឋធម្មនុញ្ញនាពេលនោះបានលុបបំបាត់ចោលនូវរាល់របបកម្មសិទ្ធិឯកជន ដែលបានបន្សល់ទុកដោយបារាំងនៅក្នុងពាក់កណ្ដាលសតវត្សទី ១៩ ។ រដ្ឋធម្មនុញ្ញបានដាក់ជាសមូហភាពនូវមធ្យោបាយផលិតកម្មសំខាន់ៗទាំងអស់ រដ្ឋធម្មនុញ្ញមាត្រា ២ បានចែងថា "កម្ពុជាប្រជាធិបតេយ្យអនុវត្តគោលការណ៍សមូហភាព ក្នុងភាពជាអ្នកនាំមុខ និងក្នុងការងារ"។ ការពន្យល់អំពីរដ្ឋធម្មនុញ្ញពីសប្ដាហ៍មុនការប្រកាសឲ្យប្រើ ខៀវ សំផន បានចុះបញ្ជីនូវវត្ថុដែលត្រូវដាក់ជាសមូហភាពដូចជាដីស្រែ ចំការឈើផ្លែ ដីកសិកដ្ឋាន រោងចក្រ រទេះភ្លើង រថយន្ត កប៉ាល់ និងកាណូត ដោយបន្សល់ទុកត្រឹមតែសម្លៀកបំពាក់ ប្រដាប់ប្រើប្រាស់ផ្ទាល់ខ្លួន (ប៉ុន្តែមិនមែនគ្រឿងអលង្ការទេ) និងឧបករណ៍ក្នុងដៃផ្ទាល់ខ្លួន ដូចនេះកម្មសិទ្ធិទ្រព្យសម្បត្តិ និងសិទ្ធិកាន់កាប់ដីធ្លីត្រូវបានគេដកចេញ។ សិទ្ធិសំខាន់របស់ប្រជាពលរដ្ឋដែលគេឲ្យតាមអត្ថបទនោះគឺសិទ្ធិការងារ។

អាជ្ញាធរថ្មីដែលបានផ្ដួលរំលំរបបខ្មែរក្រហម និងឡើងកាន់អំណាចនៅក្នុងឆ្នាំ ១៩៧៩ បានប្រកាសប្រទេសកម្ពុជា ជាសាធារណរដ្ឋប្រជាមានិតកម្ពុជា។ របបនេះបានបន្តនូវមាគ៌ានៃកម្មសិទ្ធិទ្រព្យសម្បត្តិសមូហភាពចំណែកឯដី និងផ្ទះសំបែង គឺមានជាប់ពាក់ព័ន្ធស្រដៀងគ្នានឹងរបបខ្មែរក្រហមដែរ គេបានបែងចែកប្រជាពលរដ្ឋទៅជាកម្លាំងការងារសមូហភាពនោះ គឺក្រុមសាមគ្គី។ ក្រុមសាមគ្គីមានគ្នាពី ១០ ទៅ ១៥ គ្រួសារហើយតាមទ្រឹស្ដីក្រុមសាមគ្គីត្រូវបានគេធ្វើសមូហភាវូបនីយកម្មយ៉ាងពេញលេញជាកងការងារកសិកម្ម ធ្វើការលើកសិដ្ឋានរួមគ្នាលើដីធ្លីដែលគេបានលៃទុកដោយឡែកសម្រាប់ពួកគេ។ ក្រុមសាមគ្គីត្រូវបានគេចាត់តាំងឲ្យធ្វើការងារដទៃៗទៀត ដូចជាការនេសាទ និងឧស្សាហកម្មខ្នាតតូចជាដើម។ ប៉ុន្តែប្រព័ន្ធនេះបានធ្លាក់ដាច់ចេញពីគ្នាយ៉ាងឆាប់រហ័ស ហើយក៏បានបំបែកចេញជាកសិដ្ឋានពឹងផ្អែកលើគ្រួសារជាមួយនឹងក្រុមសាមគ្គីដែលស្ម័គ្រចិត្ត។ ទោះបីនៅពេលនោះដីទាំងអស់ គឺជារបស់រដ្ឋក៏ដោយ ក៏ម្ដងម្កាលគេសង្កេតឃើញដីលំនៅស្ថានខ្លះៗត្រូវបានប្រជាជនផ្ទេរចុះឡើងជាលក្ខណៈក្រៅផ្លូវការតាមការព្រមព្រៀងគ្នាទៅវិញទៅមក។ នៅចុងឆ្នាំ ១៩៨៨ មន្ត្រីស្រុកជាច្រើនបានបង្ហាញពីការលំបាកខ្លាំងក្នុងការថែទាំផលិតកម្មជាសមូហភាព។ អាជ្ញាធរសាធារណៈរដ្ឋកម្ពុជានាពេលនោះ បានចាប់ផ្ដើមសារជាថ្មីឡើងវិញនូវកម្មសិទ្ធិឯកជនដីធ្លីនៅឆ្នាំ ១៩៨៩ និងស្របពេលនោះដែរគេក៏ជម្រុញឲ្យក្រុមសាមគ្គីរក្សាទុកសម្រាប់ខ្លួនឯងនូវមធ្យោបាយផលិតកម្មដែលបានកាន់កាប់ជាសមូហភាព។ តាមអនុក្រឹតលេខ ៣១ អ.ន.ក្រ ឆ្នាំ១៩៨៩ បានបង្កើតស្ថាប័នដីធ្លីដំបូងដោយផ្ទេរនាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឲ្យទៅជានាយកដ្ឋានសុរិយោដី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សិទ្ធិសមូហភាពលើលំនៅស្ថានត្រូវបានកែប្រែយ៉ាងច្រើន ដោយបានផ្ដល់ប័ណ្ណកម្មសិទ្ធិលើផ្ទះសម្បែងដល់បុគ្គលម្នាក់ៗ ហើយប័ណ្ណនេះអាចធ្វើការផ្ទេរតាមរយៈមរតកសាសន៍ ឬការលក់។

ក្រោយជំនួបរវាងសម្ដេច ហ៊ុន សែន និងសម្ដេច សីហនុ នៅខែធ្នូ ឆ្នាំ១៩៨៧ និងខែមករា ឆ្នាំ១៩៨៨ "ការប្រជុំក្រៅផ្លូវការនៅទីក្រុងហ្សាកាតា" ប្រទេសឥណ្ឌូនេស៊ី នាំឲ្យមានការរួបរួមរវាងភាគីទំនាស់ទាំងអស់នៅកម្ពុជា ដែលអំពាវនាវឲ្យមានការផ្សះផ្សាជាតិ។ នាកិច្ចប្រជុំចិសាមញ្ញនៅថ្ងៃទី ២៩-៣០ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋសភាបានធ្វើវិសោធនកម្មមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ ដោយប្ដូរឈ្មោះប្រទេសកម្ពុជាទៅជា រដ្ឋកម្ពុជា។ រដ្ឋសភាបានអនុម័ត

ច្បាប់ភូមិបាលថ្មីឆ្នាំ១៩៩២។ របបកម្មសិទ្ធិឯកជនត្រូវផ្តល់ឲ្យតែទៅលើដីលំនៅដ្ឋានតែមួយគត់ ហើយដីដែលស្ថិតនៅតំបន់ទីក្រុងត្រូវបានបញ្ញត្តិតាមច្បាប់ ដោយឡែកតាមច្បាប់នេះ របបកម្មសិទ្ធិអាចផ្ទេរបានតាមរយៈសន្តតិកម្មមរតកសាសន៍ កិច្ចសន្យានៃការលក់ ដោយប្រទានកម្ម និងដោយភោគៈ។ ភោគៈត្រូវបានស្គាល់អនុលោមតាមផ្នែកទី២ (មាត្រា៦១-៧៦) នៃច្បាប់ភូមិបាលឆ្នាំ ១៩៩២ និង អនុញ្ញាតឲ្យមានកម្មសិទ្ធិតាមរយៈភោគៈ។ ដើម្បីក្លាយទៅជាកម្មសិទ្ធិករនៃដី ភោគីត្រូវតែបង្ហាញថា ខ្លួនបានកាន់កាប់ដោយសន្តិវិធីដោយសុចរិត ដោយមានការដឹងឮជាសាធារណៈ ដោយមិនមានការអាក់ខាន និងដោយគ្មានការបន្លំអស់រយៈពេល ៥ ឆ្នាំយ៉ាងតិច។

នៅក្នុងឆ្នាំ ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីមួយត្រូវប្រកាសថា កម្ពុជាក្លាយទៅជា "ព្រះរាជាណាចក្រកម្ពុជា" និងបង្កើតឲ្យមានរដ្ឋាភិបាលថ្មីមួយ។ មាត្រា ៤៤ នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់អះអាងសាជាថ្មីស្តីពីសិទ្ធិក្នុងការធ្វើជាម្ចាស់លើដីធ្លី ប៉ុន្តែការកំណត់សិទ្ធិនេះ គឺចំពោះជនជាតិខ្មែរតែប៉ុណ្ណោះ។ ដំណើរការសើរើច្បាប់ភូមិបាលឆ្នាំ ១៩៩២ និងការតាក់តែងច្បាប់ថ្មីត្រូវបានធ្វើឡើងជាបន្តបន្ទាប់។ សេចក្តីព្រាងច្បាប់ថ្មីមួយដើម្បីជំនួសច្បាប់ភូមិបាលឆ្នាំ ១៩៩២ ត្រូវបានរៀបរៀងឡើងដោយផ្អែកភាគច្រើនលើច្បាប់ភូមិបាលឆ្នាំ ១៩៩២ និងបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីក្នុងខែតុលា ឆ្នាំ ១៩៩៨ ។ មានការជំទាស់យ៉ាងច្រើនគួរឲ្យកត់សម្គាល់ទៅលើសេចក្តីព្រាងច្បាប់នេះ ទើបជម្រុញឲ្យមានសេចក្តីព្រាងច្បាប់ថ្មីមួយទៀត។ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ច្បាប់ភូមិបាលថ្មីត្រូវបានប្រកាសឲ្យប្រើជាការប្រញាប់ដោយព្រះមហាក្សត្រសម្តេច នរោត្តម សីហនុ។ ច្បាប់នេះមិនទទួលស្គាល់កម្មសិទ្ធិមុនឆ្នាំ ១៩៧៩។ មាត្រា ២៧ នៃច្បាប់នេះចែងថា គ្មានជនណាម្នាក់អាចទាមទារសិទ្ធិលើកម្មសិទ្ធិចាស់មុនឆ្នាំ ១៩៧៩លើដីធ្លីបានទេ។

## ២.២ ការចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា

### ២.២.១ ការចុះបញ្ជីដីធ្លីមុនឆ្នាំ ១៩៨៩

ជាក់ស្តែង នៅប្រទេសកម្ពុជាយើងការងារគ្រប់គ្រងលើដីធ្លីមានការវិវឌ្ឍន៍ទៅតាមរបបដីធ្លីនៃសម័យកាលនីមួយៗ តួយ៉ាងដូចជាក្នុងរបបអាណានិគមនិយមបារាំង រដ្ឋបានសាកល្បងកសាងឯកសារបង្កើតសៀវភៅដី ៣ដង គឺនៅឆ្នាំ ១៨៨៤ ១៩០២ និង១៩០៨ តែត្រូវទទួលបរាជ័យ ហើយក្នុងឆ្នាំ ១៩២៥ រដ្ឋប្រកាសបើកសម័យចុះបញ្ជីអចលនវត្ថុលើកដំបូងក្នុងការផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ខ្លួនបានជោគជ័យតាមរយៈការកសាងសៀវភៅចុះបញ្ជីអចលនវត្ថុក្រោមគោលបំណងទទួលស្គាល់ជាផ្លូវការពីរដ្ឋនូវភោគៈ និងធានាតាមផ្លូវច្បាប់ជាភស្តុតាងដែលតតីតជនមិនអាចរំលោភបាន ផ្លាស់ប្តូរពីភោគៈទៅជាកម្មសិទ្ធិ ពេលកសាងបានប្លង់សុរិយោដី គឺក្រោយពេលដែលអចលនវត្ថុទាំងនោះបានចុះបញ្ជីលេខក្បាលដី ពិសេសកសាងបានបញ្ជីពន្ធដីប្រកបដោយភាពត្រឹមត្រូវផងដែរ។ ប៉ុន្តែឯកសារសុរិយោដីទាំងនោះត្រូវបានបំផ្លាញក្នុងសម័យខ្មែរក្រហមអស់រវាងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ។ ហើយនៅឆ្នាំ ១៩៨៩ រដ្ឋាភិបាលកម្ពុជាចាប់ផ្តើមបែងចែកដីជូនប្រជាពលរដ្ឋឡើងវិញ។

ដូច្នេះហើយទើបយើងឃើញថាមានលិខិតគតិយុត្តជាច្រើនបានអនុម័តឡើងជាបន្តបន្ទាប់ដូចនៅក្នុងតារាងនៃឧបសម្ព័ន្ធទី ១ ដើម្បីឲ្យក្រសួង ស្ថាប័ន និងអង្គភាពមានយុត្តនាការណ៍អនុវត្តនូវដំណើរការស្រង់ក្បាលដីទាំងអស់ ។ (សៀវភៅច្បាប់ភូមិបាលរៀបរៀងដោយ សាស្ត្រាចារ្យ **លឹម វ៉ាន់**)

២.២.២ ការចុះបញ្ជីដីធ្លីក្រោយឆ្នាំ ១៩៨៩

តាមការពិនិត្យមើលស្ថានភាពកាន់កាប់ដីធ្លី ចាប់ពីឆ្នាំ ១៩៨៩ មកយើងចាត់ទុកថា វាជាឆ្នាំសូន្យរបស់ប្រទេសកម្ពុជា ព្រោះរាល់ឯកសារដីធ្លីដូចជា ផែនទី និងប្រថព៌ីភាគ ត្រូវបានបំផ្លាញចោលអស់ក្នុងរបបខ្មែរក្រហម។ ប៉ុន្តែនៅដើម និងពាក់កណ្តាលទសវត្សរ៍ទី ៩០ រដ្ឋាភិបាលបានខិតខំប្រឹងប្រែងបើកយុទ្ធនាការដ៏ធំក្នុងការចុះបញ្ជីក្បាលដីកាន់កាប់ឯកជន ទាំងខ្លួនមិនមានបច្ចេកទេស ថវិកា និងការអនុវត្តដើម្បីដំណើរការចុះបញ្ជីក្បាលដី ៤.៥ លានឱ្យមានប្រសិទ្ធភាព និងប្រសើរក៏ដោយ ដែលឯកសារនោះចងក្រងតម្កល់ទុកក្នុងការិយាល័យសុរិយោដីតាមរយៈប្រព័ន្ធចុះបញ្ជីមានលក្ខណៈដាច់ដោយដុំដែលមានស្រាប់។ នៅពាក់កណ្តាលទសវត្សរ៍ទី ៩០ នោះដែររដ្ឋាភិបាលកម្ពុជាក៏បានស្នើសុំរដ្ឋាភិបាលប្រទេសអាឡឺម៉ង់នៅក្នុងឆ្នាំ ១៩៩៥ និងប្រទេសហ្វាំងឡង់ក្នុងឆ្នាំ ១៩៩៧ ដើម្បីគាំទ្រការអភិវឌ្ឍន៍នូវវិស័យរដ្ឋបាលដីធ្លី ដោយជាលើកដំបូងសង្កត់ធ្ងន់ជាពិសេសទៅលើប្រព័ន្ធចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដ៏ត្រឹមត្រូវមួយសម្រាប់គ្របដណ្តប់លើកម្មវិធីចុះបញ្ជីដីធ្លីដ៏មានប្រសិទ្ធភាព និងសមត្ថភាព ដែលអាចប្រើប្រាស់បានក្នុងប្រទេសទាំងមូល។ សំណើនេះត្រូវបានប្រទេសម្ចាស់ជំនួយទាំងពីរនេះទទួលយក ហើយជាលទ្ធផលការអភិវឌ្ឍន៍នូវប្រព័ន្ធសុរិយោដី និងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បានចាប់ផ្តើមក្នុងឆ្នាំ១៩៩៧ តាមរយៈការគាំទ្រផ្នែកហរិញ្ញវត្ថុពីរដ្ឋាភិបាលហ្វាំងឡង់ ជំនួយការបច្ចេកទេសពីក្រុមហ៊ុន FM-International Oy Finnmap និងត្រួតពិនិត្យពីអ្នកវាស់វែងដីធ្លីថ្នាក់ជាតិរបស់ហ្វាំងឡង់ NLSF ក្រោមគម្រោងសាកល្បងចុះបញ្ជីដីធ្លី និងផែនទីសុរិយោដី CMLRPP ហើយគម្រោងនេះបានបន្តជំហានទី ២ របស់ខ្លួននៅឆ្នាំ ២០០០ ក្រោមគម្រោងសុរិយោដីនៅកម្ពុជា CCP។ ការងារទាំងនេះត្រូវបានសហការយ៉ាងជិតស្និទ្ធជាមួយគម្រោងដែលដើរស្របគ្នាមួយ គឺគម្រោងគ្រប់គ្រងដីធ្លី LMAP ដែលគាំទ្រដោយរដ្ឋាភិបាលអាឡឺម៉ង់ ហើយត្រូវបាន GTZ អនុវត្តចាប់តាំងពីឆ្នាំ ១៩៩៥ មកដែលវាជាផ្នែកមួយនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដោយផ្តោតសំខាន់ទៅលើបញ្ហាគ្រប់គ្រងដីធ្លី។ ក្នុងកំឡុងពេល ៥ ឆ្នាំដំបូង ១៩៩៥ ដល់ ២០០២ គេសង្កត់ធ្ងន់លើការអភិវឌ្ឍន៍បច្ចេកទេស ការធ្វើតេស្តការសាកល្បង និងចុងក្រោយ គឺការអនុវត្តជាក់ស្តែងនូវនីតិវិធីចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ និងរកប្រព័ន្ធដ៏សមស្របសម្រាប់លក្ខខណ្ឌប្រទេសកម្ពុជា។ (សៀវភៅច្បាប់ភូមិបាល)

## ២.៣ ការចុះបញ្ជីដីធ្លីនៅប្រទេសកម្ពុជា

### ២.៣.១ ការចុះបញ្ជីដំបូង

ក្បាលដីដែលបានចុះបញ្ជី តាមដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ អនុលោមតាមអនុក្រឹតលេខ ៤៦ អនុក្រ.បកចុះថ្ងៃទី ៣១ ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីក្បាលដែលបានចុះបញ្ជីតាមដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដែលជ្រុងនៃក្បាលដីមាននិយាមការច្បាស់លាស់អនុលោមតាមអនុក្រឹតលេខ ៤៨ អនក្រ.បកចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២។

➢គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីមានទិសដៅរួម និងគោលបំណងដូចតទៅ៖

- ទិសដៅរួមរបស់គម្រោង គឺកាត់បន្ថយភាពក្រីក្រ ជម្រុញឲ្យមានស្ថេរភាពសង្គម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។
- គោលបំណងរបស់គម្រោង គឺធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងជម្រុញការអភិវឌ្ឍន៍ដីធ្លីប្រកបដោយប្រសិទ្ធិភាព។

➢ គោលបំណងនេះអាចសម្រេចទៅបានតាមរយៈ

- ការកសាងគោលនយោបាយដីធ្លី ក្របខណ្ឌច្បាប់ និងការពង្រឹងស្ថាប័នដែលទទួលខុសត្រូវលើរដ្ឋបាលដីធ្លី និងការរៀបចំដែនដី។
- ការចេញប័ណ្ណ និងការចុះបញ្ជីដីធ្លីទាំងនៅជនបទ និងនៅទីប្រជុំជន។
- ការកសាងប្រព័ន្ធរដ្ឋបាលដីធ្លីប្រកបដោយប្រសិទ្ធិភាព។

២.៣.២ ការចុះបញ្ជីបន្ត

១.លក្ខណៈទូទៅ

រយៈកាលកន្លងមកឯកសារសុរិយោដីត្រូវបានកសាង និងការកាន់កាប់តាមវិធីពីរ គឺវិធីចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

ឯកសារមូលដ្ឋាន នៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធមាន សៀវភៅគោលបញ្ជីដីធ្លី ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី បញ្ជីឈ្មោះម្ចាស់ដី ប្លង់សុរិយោដី និងឯកសារណបផ្សេងៗ។

ឯកសារមូលដ្ឋាន នៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ដែលជាជ្រុងនៃក្បាលដីមាន និយាមការច្បាស់លាស់មានពាក្យស្នើសុំចុះបញ្ជីដី ផែនទីមានលក្ខណៈដាច់ដោយដុំ និងឯកសារណបផ្សេងទៀត។

សៀវភៅចុះបញ្ជីអចលនវត្ថុ តារាងរាយនាមឈ្មោះអ្នកកាន់កាប់តាមលំដាប់អក្សរ ពាក្យស្នើសុំកាន់កាប់និងប្រើប្រាស់ដីធ្លី ប្រកាសជូនដំណឹងពីការចុះអង្កេតវាស់វែង កំណត់ហេតុអង្កេតដី ទម្រង់បែបបទនៃការប្រមូលទិន្នន័យ បញ្ជីឈ្មោះម្ចាស់ដី ផែនទីមានលក្ខណៈដាច់ដោយដុំ ផែនទីក្បាលដី គំនូសបង្ហាញទីតាំងក្បាលដី និងឯកសារណបផ្សេងៗ។

## ២.៤ នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

២.៤.១ ដំណាក់កាលត្រៀមរៀបចំ

**១.ការចេញសេចក្តីប្រកាស**

ការចេញសេចក្តីប្រកាស គឺជាការកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងដែលត្រូវធ្វើការវិនិច្ឆ័យ។ បន្ទាប់ពីអភិបាលខេត្ត រាជធានី ចេញសេចក្តីប្រកាសរួចហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីចាំបាច់មួយចំនួនទៀតរួមមាន៖ មន្ត្រីវាស់វែង មន្ត្រីកំណត់ព្រំដី និងមន្ត្រីវិនិច្ឆ័យឲ្យទៅបំពេញភារកិច្ចនៅក្នុងតំបន់វិនិច្ឆ័យនោះ។ ទន្ទឹមនឹងនោះមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត រាជធានី ពាក់ព័ន្ធនឹងតំបន់វិនិច្ឆ័យក៏ត្រូវចាត់តាំងមន្ត្រីម្នាក់ឲ្យទទួលខុសត្រូវលើការងាររដ្ឋបាលសុរិយោដី ជូនអភិបាលខេត្ត រាជធានី ដើម្បីបញ្ជូនជាសមាជិកនៃគណៈកម្មការរដ្ឋបាលផងដែរ។ អភិបាលខេត្ត

រាជធានី ជាអ្នករៀបចំធ្វើលិខិតអនុញ្ញាតជាផ្លូវការ នូវការអនុវត្តនីតិវិធីនេះទៅអាជ្ញាធរមូលដ្ឋានយ៉ាងហោចណាស់ ១៥ ថ្ងៃមុនបើក កិច្ចប្រជុំផ្សព្វផ្សាយ និងត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំយ៉ាងហោចណាស់ ៧ ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយ។

**២.ការប្រជុំប្រកាសតំបន់វិនិច្ឆ័យ**

ជាចាំបាច់លោកអភិបាលខេត្ត រាជធានីត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំ។ សេចក្តីជូនដំណឹងត្រូវបិទផ្សាយ និងអាចផ្សាព្វផ្សាយតាមឧគ្ឃោសនស័ព្ទជូនសាធារណៈជនយ៉ាងហោចណាស់ ៧ ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយក្នុងទីកន្លែងដែលងាយឃើញក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់។ ហើយសេចក្តីជូនដំណឹងនេះមានគោលបំណងឲ្យកម្មសិទ្ធិករ ឬអ្នកកាន់កាប់ដីព្រមទាំងជនដែលមានការពាក់ព័ន្ធនឹងក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យបានយល់ជ្រួតជ្រាបពីសារៈសំខាន់នៃកិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញ ដើម្បីឲ្យមកចូលរួមផ្តល់ ព័ត៌មានឯកសារ និងភស្តុតាងសំខាន់ៗដែលទាក់ទងនឹងអត្តសញ្ញាណនៃក្បាលដី អត្តសញ្ញាណនៃម្ចាស់ដីធ្វើឲ្យទិន្នន័យដែលប្រមូលបានមានភាពពិតប្រាកដ និងសុក្រឹត្យ។

ក្នុងពេលប្រជុំផ្សព្វផ្សាយអំពីការកំណត់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងតំបន់ ឬតំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់អំពីដំណើការនៃការវិនិច្ឆ័យភាពចាំបាច់ និងកាតព្វកិច្ចដែលត្រូវចូលរួមរបស់ប្រជាពលរដ្ឋ និងបំភ្លឺពីសិទ្ធិស្របច្បាប់លើអចលនវត្ថុព្រមទាំងឆ្លើយនូវសំណួរ ឬចម្ងល់ដែលបានលើកឡើងនៅក្នុងអង្គប្រជុំ។

ក្នុងសារាចរណ៍ណែនាំនេះចំពោះការបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់ទីតាំងធ្វើការវិនិច្ឆ័យត្រូវប្រព្រឹត្តិទៅនៅក្នុងទីកន្លែងណាមួយ ក្នុងតំបន់ធ្វើការវិនិច្ឆ័យដែលមានជាអាទិ៍ ទីសាធារណៈ សាលារៀន សាលាឃុំ សង្កាត់ សាលាក្រុង ស្រុក ខណ្ឌ ខេត្ត រាជធានីដោយយោងតាមស្ថានភាពជាក់ស្តែង នៃទីតាំងវិនិច្ឆ័យនីមួយៗ។

❖ សមាសភាពនៃគណៈកម្មការរដ្ឋបាលមាន៖

| | |
|---|---|
| - តំណាងអភិបាលខេត្ត ក្រុង | ជាប្រធាន |
| - មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី | ជាសមាជិក |
| - មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីនៃមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង | ជាសមាជិក |
| - អភិបាលស្រុក ខណ្ឌ ឬតំណាង | ជាសមាជិក |
| - មេឃុំ ចៅសង្កាត់ ឬតំណាង | ជាសមាជិក |
| - មេភូមិ ឬតំណាង | ជាសមាជិក |
| - ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប | ជាសមាជិក |

គណៈកម្មការនេះត្រូវរៀបចំប្រជុំណែនាំសមាជិកខ្លួន ឲ្យយល់ពីកិច្ចដំណើការ ក្នុងការកំណត់បែងចែកភារកិច្ច ឲ្យសមាជិកម្នាក់ៗរៀបចំផែនការសម្រាប់អនុវត្ត និងលើកសំណើទៅអភិបាលខេត្ត រាជធានីអំពីកាលបរិច្ឆេទ ទីកន្លែងដែលត្រូវបើកកិច្ចប្រជុំផ្សព្វផ្សាយអំពីការកំណត់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យ និងការងារវាលរបស់មន្ត្រីជំនាញ។

២.៤.២ តំណាក់ប្រតិបត្តិការបច្ចេកទេស

ក្រោយពីបានត្រៀមរៀបចំរួចរាល់ គឺចូលដល់ដំណាក់កាលបច្ចេកទេសដែលជាដំណាក់កាលចុះស្រង់ទិន្នន័យរបស់មន្ត្រី កំណត់ព្រំ វាស់វែង និងវិនិច្ឆ័យនៅទីវាលផ្ទាល់ រួចបញ្ជូនទិន្នន័យដែលប្រមូលបានទាំងនោះទៅឲ្យមន្ត្រី ការិយាល័យដើម្បីវាយបញ្ចូល និងគូសក្បាលដីដែលប្រមូលបាននោះទៅក្នុងកំព្យូទ័រ និងធ្វើការផ្ទៀងផ្ទាត់ទិន្នន័យ ទាំងនោះមុនពេលដែលយកទៅធ្វើការបិទផ្សាយ។

**១. ការកំណត់ព្រំ**

ការកំណត់ព្រំ គឺជាការកំណត់ជាក់ស្តែងនៅលើដី នូវព្រំនៃក្បាលដីព្រមទាំងព្រំប្រទល់រដ្ឋបាលខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ឬសេវភាពជាដើម។ ការកំណត់ព្រំដីត្រូវធ្វើឡើងដោយកំណត់ព្រំនៅចំពោះមុខម្ចាស់នៃក្បាលដីទាំងឡាយដែលមានព្រំដីជាប់គ្នា ក្នុងពេលដំណាលគ្នា ជាមួយនឹងដំណើការនៃការវិនិច្ឆ័យ។

ការកំណត់ចំនួនក្បាលដី និងទីតាំងដែលត្រូវចុះបំពេញការងារត្រូវរៀបចំធ្វើទៅតាមកាលវិភាគដោយធ្វើការជូនដំណឹងដល់អាជ្ញាធរដែនដី អញ្ជើញអ្នកដែលកាន់កាប់លើក្បាលដីទាំងឡាយ ក្នុងទីតាំងដែលបានកំណត់មកចូលរួមកំណត់ព្រំ។ ការកំណត់ព្រំអាចដំណើរការទៅលឿនបានលុះត្រាតែមានការចូលរួមពីម្ចាស់ដី ហេតុនេះហើយទើបមន្ត្រីចុះបំពេញការងារចាំបាច់ត្រូវស្នើសុំឲ្យម្ចាស់ដីធ្វើការដាំបង្គោលព្រំឲ្យបាននឹងមាំជាមួយ និងម្ចាស់ដីទាំងឡាយដែលជាប់ព្រំជាមុនសិន ដោយប្រើបង្គោល សញ្ញាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ដើម្បីជួយសម្រួលដល់មន្ត្រីកំណត់ព្រំ។ ដើម្បីធ្វើការកំណត់ព្រំបាននោះគឺ ត្រូវពិនិត្យមើលឯកសារនៃព្រំប្រទល់ដីមួយចំនួនដូចជា៖ ប័ណ្ណសម្គាល់សិទ្ធិ សាក្សី សេចក្តីប្រកាសរបស់ប្រកាសទ្រព្យ ឯកសារសាធារណៈដែលមានកំណត់ពីព្រំប្រទល់រដ្ឋបាលផ្លូវការ ឬរូបថតពីលើអាកាលជាដើម។ ក្រៅពីនេះត្រូវពិនិត្យលើភស្តុតាងទាំងឡាយផ្សេងទៀតដូចជា៖ សកម្មភាព និង របៀបនៃការប្រើប្រាស់ និងកាន់កាប់ដីបែបរចនានៃសំណង់ និងទំនៀមទំលាប់ប្រពៃណីក្នុងមូលដ្ឋាន។

**២. ការវាស់វែង**

ការវាស់វែង គឺធ្វើឡើងបន្ទាប់ពីធ្វើការកំណត់ព្រំរួចដើម្បីប្រមូលទិន្នន័យដែលជាតម្រូវការក្នុងការកសាងប្លង់ សុរិយោដី។

- ឧបករណ៍វាស់វែង និងសម្ភារៈវាស់វែងមាន
- តូតាល់ស្តេសិន ឧបករណ៍ផ្ទុកទិន្នន័យ Ipag-PC ព្រីសចំណាំងផ្លាត វិទ្យុទាក់ទង ឆ័ត្រ
- ខ្សែម៉ែត្រ(ដែក) បង្គោលតម្រង់ ព្រីសកែង ត្រីវិស័យ
- កុំព្យូទ័រ
- អ័រតូហ្វូតូមាត្រដ្ឋានគំរូ
- ផែនទីឋានលេខាដែលគ្របដណ្តប់លើតំបន់វិនិច្ឆ័យ

ឯកសារដែលពិពណ៌នាអំពីទីតាំងបង្គោលប្រថពីវិភាគ ដែលចេញដោយអគ្គនាយកដ្ឋានសុរិយោដីភូមិសាស្ត្រ។

**៣. ការវិនិច្ឆ័យ**

ការវិនិច្ឆ័យ ជាដំណើការមួយដែលកំណត់នូវសិទ្ធិដែលមានលើក្បាលដីមួយជាស្ថាពរ និងមានលក្ខណៈជាផ្លូវការហើយលទ្ធផលនៃការវិនិច្ឆ័យ គឺជាការទទួលបាននូវបញ្ជីដីធ្លីមួយដែលមានលក្ខណៈពេញលេញ ច្បាស់លាស់ និងស្ថាពរ។ ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីចែកចេញជា ៣ ផ្នែកគឺ៖

+ អត្តសញ្ញាណនៃក្បាលដី
  - លេខសម្គាល់ក្បាលដី
  - ទីតាំងក្បាលដី
  - មធ្យោបាយធ្វើអត្តសញ្ញាណកម្មក្បាលដី
  - ព័ត៌មានលម្អិតពីសំណង់
  - បន្ទុកលើអចលនវត្ថុ
  - ព្រំប្រទល់ក្បាលដី។
+ អត្តសញ្ញាណនៃម្ចាស់ដី
  - រូបវន្តបុគ្គល
  - នីតិបុគ្គល
  - អ្នកតំណាង ឬអ្នកគ្រប់គ្រង។
+ សិទ្ធិលើអចលនវត្ថុ
  - ប្រពភនៃការកាន់កាប់ដី
  - ប្រភេទទ្រព្យ
  - ស្ថានភាពផ្លូវច្បាប់
  - ក្បាលដីទំនាស់
  - ស្នាមមេដៃស្តាំម្ចាស់ទ្រព្យ និងសាក្សី (ទម្រង់បែបបទនៃឯកសារវិនិច្ឆ័យ) ។

**៤. ការងារនៅការិយាល័យ**

ការងារនៅការិយាល័យ គឺជាការបញ្ចូលទិន្នន័យដែលប្រមូលបានពីវាល ទៅក្នុងកុំព្យូទ័រ ដើម្បីកសាងផែនទីក្បាលដី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅចុះបញ្ជីដីធ្លី ចំពោះក្បាលដីទាំងឡាយណាដែលបានធ្វើការវាស់វែងរួចរាល់។

**២.៤.៣ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ជាដំណើរការមួយដែលត្រូវធ្វើការបិទផ្សាយឯកសារវិនិច្ឆ័យដើម្បីឲ្យម្ចាស់ដី ឬភាគីដែលមានប្រយោជន៍អាចស្នើសុំធ្វើការកែតម្រូវ ឬដាក់ពាក្យបណ្តឹងតវ៉ាចំពោះ ទិន្នន័យណាដែលមានកំហុស។

ឯកសារដែលតម្រូវឲ្យមាន សម្រាប់ការបិទផ្សាយជាសាធារណៈរួមមាន៖ ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី។

នៅលើប្លង់សុរិយោដី ត្រូវពិនិត្យមើលលេខសម្គាល់ក្បាលដី រូបរាងដី និងទីតាំងដី នៅបញ្ជីឈ្មោះម្ចាស់ដីត្រូវពិនិត្យ ឈ្មោះ ទំហំដី ប្រភេទទ្រព្យ ប្រភេទដី (កសិកម្ម ឬលំនៅដ្ឋាន) និងសវតា។

**១. ដំណើរការបិទផ្សាយ**

សមាសភាពអ្នកចូលរួមមានៈ

- មន្ត្រីជំនាញ ជាមន្ត្រីប្រចាំការដែលមានការងារពីផ្សេងគ្នាគឺៈ

+ ជាមន្ត្រីទទួលបន្ទុករង់ចាំពន្យល់ ឬបំភ្លឺអំពីខ្លឹមសារនៃទិន្នន័យ បកស្រាយចម្ងល់ផ្សេងៗ ដែលទាក់ទង ទៅនឹងឯកសារដែលត្រូវបានបិទផ្សាយ។

+ ជាមន្ត្រីទទួលបណ្តឹងតវ៉ា ឬការជំទាស់នានា និងទទួលបន្ទុកសម្រុះសម្រួលភាគីដែលមានវិវាទ

- សមាជិកគណៈកម្មការថ្នាក់ភូមិ ឃុំ ៖ មានតួនាទីទទួលបណ្តឹងតវ៉ា និងដោះស្រាយតាមការព្រមព្រៀង រាយការណ៍ និងលើកសំណើផ្តល់របស់ប្រជាពលរដ្ឋ។

- អ្នកជំនួយការ ជាអ្នកជួយអញ្ជើញប្រជាពលរដ្ឋទៅតាមទិសដៅរបស់ខ្លួនដែលបានដាក់ឲ្យក្នុងគោលបំណងឲ្យមានការចូលរួមពិនិត្យទិន្នន័យឲ្យបានគ្រប់ម្ចាស់នៃក្បាលដីទាំងអស់។

- ម្ចាស់ដី និងអ្នកពាក់ព័ន្ធមានកាតព្វកិច្ចចូលរួមដោយខានមិនបានដើម្បីពិនិត្យ និងបញ្ជាក់ឲ្យបានច្បាស់លាស់នូវរាល់ព័ត៌មានដែលខ្លួនបានផ្តល់ក្នុងកំឡុងពេលបំពេញការងារ។

## ២. ការប្តឹងជំទាស់ ឬកែតម្រូវទិន្នន័យ

បុគ្គលទាំងអស់ដែលមានផលប្រយោជន៍ អាចធ្វើការប្តឹងជំទាស់ទៅនឹងកម្មវត្ថុណាមួយដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ដោយដាក់ពាក្យបណ្តឹងទៅប្រធានគណៈកម្មការរដ្ឋបាល ប្រសិនបើយល់ថាទិន្នន័យនៃអត្តសញ្ញាណក្បាលដី និងអត្តសញ្ញាណនៃម្ចាស់ដីមានភាពមិនត្រឹមត្រូវដោយខុសឆ្គងត្រង់ចំនុចណាមួយនោះ។ ក្នុងអំឡុងពេលបិទផ្សាយជាសាធារណៈនេះ ម្ចាស់ដីអាចមានសិទ្ធិធ្វើការកែតម្រូវព័ត៌មានផ្សេងៗដូចជាៈ ប្រភេទដី (កសិកម្ម ឬលំនៅដ្ឋាន) ប្រភេទទ្រព្យ ឈ្មោះម្ចាស់ដី ទំហំដី ព្រំប្រទល់ លេខក្បាលដី និងសវតា។ ក្នុងការកែតម្រូវព័ត៌មានទាំងនេះ ចាំបាច់ត្រូវមានលិខិតរណបផ្សេងៗមួយចំនួនដែលទាក់ទងនឹងអត្តសញ្ញាណក្បាលដី និងអត្តសញ្ញាណម្ចាស់ដី ដើម្បីឲ្យគណៈកម្មការរដ្ឋបាលធ្វើការផ្ទៀងផ្ទាត់ និងដោះស្រាយទៅតាមករណីនីមួយៗ។

## ៣. ការរៀបចំជាជំហាននៃការបិទផ្សាយ

- បន្ទាប់ពីឯកសារនៃការវិនិច្ឆ័យ ត្រូវបានរៀបចំរួចគណៈកម្មការរដ្ឋបាលត្រូវលើកសំណើទៅអភិបាលខេត្ត រាជធានី ដើម្បីធ្វើការរៀបចំសេចក្តីជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈ។

- អភិបាលខេត្ត រាជធានី ផ្ញើរសេចក្តីជូនដំណឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការរដ្ឋបាល និងមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្ត រាជធានី ប្រកាសអំពីការបិទផ្សាយជាសាធារណៈ។

- អភិបាលខេត្ត រាជធានី ផ្ញើរលិខិតស្នើសុំការប្រកាសអំពីការបិទផ្សាយជាសាធារណៈតាមរយៈ

+ វិទ្យុ (លិខិតផ្ញើរជូនអគ្គនាយកនៃនាយកដ្ឋានវិទ្យុជាតិ) ស្នើសុំឲ្យធ្វើការចាក់ផ្សាយនូវព័ត៌មានស្តីពីការ បិទផ្សាយជាសាធារណៈក្នុងអំឡុងពេល ៧ ថ្ងៃមុនពេលបើកប្រកាសជាផ្លូវការ ដោយបញ្ជាក់ពីពេលវេលាច្បាស់លាស់ ឬម៉ោងដែលស្នើសុំឲ្យចាក់ផ្សាយ។

+ ទូរទស្សន៍ (លិខិតផ្ញើរជូនអគ្គនាយកនៃនាយកដ្ឋានទូរទស្សន៍ជាតិ "ទទក") ស្នើសុំឲ្យធ្វើការចាក់ផ្សាយ នូវព័ត៌មានស្តីពីការបិទផ្សាយជាសាធារណៈក្នុងអំឡុងពេល ៧ ថ្ងៃមុនថ្ងៃប្រកាសបើកជាផ្លូវការដោយបញ្ជាក់ពី ម៉ោងដែលស្នើសុំឲ្យចាក់ផ្សាយ។

+ លិខិតជូនដំណឹងរបស់អភិបាលខេត្ត រាជធានីទៅកាន់សារព័ត៌មានដើម្បីចុះផ្សាយ។

+ ឧគ្ឃោសនស័ព្ទ និងការបិទផ្សាយនៅតាមមូលដ្ឋាន (សេចក្តីជូនដំណឹង និងរូបភាព)

សេចក្តីជូនដំណឹងត្រូវបានបង្ហាញនូវទីតាំងវិនិច្ឆ័យជាក់ស្តែង តាមរយៈក្រដាសផ្សាយដែលពន្យល់អំពីដំណើរការជាលាយលក្ខណ៍អក្សរ បន្ទាប់ពីបានផ្ញើរសេចក្តីជូនដំណឹងរបស់អភិបាលខេត្ត រាជធានីទៅគណៈកម្មការរដ្ឋបាល។

ឃុំ សង្កាត់នីមួយៗ អាចបង្កើតកម្មវិធីជាក់លាក់សម្រាប់ការផ្សាយព័ត៌មានស្របទៅតាមលក្ខណៈជាក់ស្តែងព័ត៌មានផ្សព្វផ្សាយបានកាន់តែទូលំទូលាយ គឺជាការចាំបាច់។

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ត្រូវបានបង្កើតឡើងយ៉ាងស្របច្បាប់នូវទិន្នន័យដែលបានចុះបញ្ជីយ៉ាងមាន តម្លាភាព ហើយមិនអាចតវ៉ាទៀតបាន និងមានសុពលភាពផ្នែកច្បាប់ជាស្ថាពរ។

ដំណើរការនៃការបិទផ្សាយជាសាធារណៈ ស្ថិតនៅក្នុងដំណាក់កាលមួយដែលនឹងត្រូវយកឯកសារនៃការវិនិច្ឆ័យ (ទម្រង់ជាក្រាហ្វិច និងទម្រង់ជាអត្ថបទ) ទៅបិទនៅកន្លែងដែលងាយមើលក្នុងតំបន់វិនិច្ឆ័យ។ ដើម្បីផ្សព្វផ្សាយ ជាសាធារណៈក្នុងរយៈពេល ៣០ ថ្ងៃដោយគិតទាំងថ្ងៃឈប់សម្រាក និងថ្ងៃបុណ្យផ្សេងៗដើម្បីផ្តល់ឱកាសឲ្យបុគ្គលដែលពាក់ព័ន្ធធ្វើការពិនិត្យមើលទិន្នន័យនោះ និងធ្វើការតវ៉ាប្រសិនបើគាត់យល់ថាទិន្នន័យនោះមិនត្រឹមត្រូវ។

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយដែលបានចាត់ទុកថាឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញអាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលអំពីការជំទាស់របស់ខ្លួន។

ក្រោយពីផ្តល់នូវការកត់សម្គាល់ដ៏សមហេតុផល ដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការជំទាស់ និងបន្ទាប់ពីបានពិគ្រោះជាមួយអ្នកដែលធ្វើការជំទាស់គណៈកម្មការរដ្ឋបាលត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង។ ការជំទាស់ ឬវិវាទណាមួយដែលមិនអាចដោះស្រាយបានត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ស្របតាមនីតិវិធីដែលនឹងកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការសុរិយោដី។

បន្ទាប់ពីការយល់ព្រម គណៈកម្មការរដ្ឋបាលត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីពិនិត្យ និងឯកភាព ហើយបញ្ជូនទៅឲ្យអភិបាល ខេត្ត រាជធានី ចុះហត្ថលេខា។

**២.៤.៤ ការសម្រេចលើឯកសារនៃការវិនិច្ឆ័យ**

ដំណាក់កាលសម្រេចលើឯកសារនៃការវិនិច្ឆ័យគឺ ជាការផ្ញើរបាយការណ៍ស្តីពីលទ្ធផលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យរបស់គណៈកម្មការរដ្ឋបាលជូន អភិបាលខេត្ត រាជធានី ដើម្បីពិនិត្យ និងសម្រេច ក្រោយពីអភិបាលខេត្ត រាជធានី ចុះហត្ថលេខា ហើយឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរចំពោះក្បាលដីណាដែលមិនមានទំនាស់។

ពេលដែលឯកសារនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យលើក្បាលដីមានលក្ខណៈជាប្រព័ន្ធត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដីដើម្បីចុះបញ្ជី។

ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីដែលត្រូវបានកែតម្រូវបន្ទាប់ពីការបិទផ្សាយជាសាធារណៈរួចមកត្រូវបានចុះហត្ថលេខាដោយមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងប្រធានគណៈកម្មការរដ្ឋបាល។

### ២.៤.៥ ដំណាក់កាលចែកវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ

ក្រោយពីការសម្រេចលើឯកសារនៃការវិនិច្ឆ័យ របស់គណៈកម្មការរដ្ឋបាល និងការឯកភាពរបស់ឯកឧត្តមអភិបាលខេត្ត និងរដ្ឋបាលសុរិយោដីដែលស្ថិតនៅក្រោមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ លើគ្រប់ក្បាលដីណាដែលគ្មានវិវាទ បំពេញបានគ្រប់លក្ខណៈតាមផ្លូវច្បាប់នៃឯកសារនៃការវិនិច្ឆ័យដើម្បីចុះបញ្ជី និងគ្រប់គ្រង៖

- ថ្នាក់កណ្តាល (អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ចំពោះឯកសារទាក់ទងនឹងខេត្ត រាជធានី ណាដែលមិនទាន់បានប្រតិភូកម្ម។
- ថ្នាក់ខេត្ត រាជធានី (មន្ត្រីរៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដី) ចំពោះឯកសារដែលទាក់ទងនឹងខេត្ត រាជធានី ណាដែលបានប្រតិភូកម្មរួចហើយ។

➢ **គោលការណ៍នៃការចេញប័ណ្ណ**

១. ចេញវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ចំពោះក្បាលដី ឬអចលនវត្ថុដែល កាន់កាប់ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឲ្យប្រើច្បាប់ភូមិបាល (មាត្រា ៣០ វាក្យខណ្ឌទី ១ នៃច្បាប់ភូមិបាល ២០០១) ។

២. ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ (ប័ណ្ណភោគៈ) ចំពោះក្បាលដី ឬអចលនវត្ថុណាដែលកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ ហើយមានរយៈពេលតិចជាង ៥ ឆ្នាំមុនច្បាប់ភូមិបាលចូលជាធរមាន។ ប័ណ្ណប្រភេទនេះ អាចប្តូរយកវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ នៅពេលដែលរយៈពេលនៃការកាន់កាប់ដី ឬចលនវត្ថុនោះបានគ្រប់ ៥ ឆ្នាំ ឬលើស។

៣. អាចចេញប័ណ្ណជូនបានចំពោះតែក្បាលដី ឬអចលនវត្ថុណាដែលគ្មានពាក់ព័ន្ធនឹងវិវាទ។

៤. ការប្រគល់ប័ណ្ណ ត្រូវមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីអ្នកប្រគល់ និងកត់ឈ្មោះ រួចផ្តិតមេដៃទទួលទុកជាភស្តុតាង។ ការប្រគល់ប័ណ្ណត្រូវប្រព្រឹត្តិទៅនៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច។ មន្ត្រី សុរិយោដី មិនត្រូវបានអនុញ្ញាតឲ្យប្រគល់ប័ណ្ណ ជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយលើកលែង៖

- ករណីម្ចាស់សិទ្ធិ ទទួលមរណៈភាព ឬអវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាព ដែលច្បាប់ទទួលស្គាល់ ពេលនោះអ្នកដំណាងស្របច្បាប់មានសិទ្ធិទទួលជំនួស។
- ករណីពិសេស និងចាំបាច់ ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំប័ណ្ណបាន តែត្រូវបញ្ជាក់ច្បាស់ពីហេតុដែលមិនអាចមកទទួលយកប័ណ្ណនៅការិយាល័យ ទើបអនុញ្ញាតឲ្យប្រគល់ប័ណ្ណនៅគេហដ្ឋានរបស់កម្មសិទ្ធិករ ឬភោគី ដោយមន្ត្រីសុរិយោដី ២ នាក់។

៥. នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដី ឬអចលនវត្ថុ ត្រូវប្រគល់ប័ណ្ណចាស់ទាក់ទងនឹងសិទ្ធិលើដី ឬអចលនវត្ថុ នោះជូនមន្ត្រីសុរិយោដីប្រសិនបើមាន។

៦. ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព (នីតិបុគ្គលសាធារណៈ មានជាអាទិ៍ សាលារៀន សាលាឃុំ នីតិបុគ្គលឯកជន សមាគមន៍ ក្រុមហ៊ុន) មិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត។ ចំពោះដី ឬអចលនវត្ថុរបស់សមូហភាព ដូចជា វត្ត ឬសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប័ណ្ណក៏ត្រូវចុះឈ្មោះ វត្ត ឬសហគមន៍ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាតំណាងឡើយ។

ទាក់ទងដល់ការប្រើសិទ្ធិ និងការបំពេញកាតព្វកិច្ចផ្សេងៗ ក្នុងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ នីតិបុគ្គលនានា ក៏ដូចជាសមូហភាពទាំងអស់នោះ ត្រូវជ្រើសរើសតំណាងស្របច្បាប់រៀងៗខ្លួន តាមវិធីផ្សេងៗគ្នាដូចជា៖ នីតិបុគ្គលសាធារណៈមានលិខិតតែងតាំងនីតិបុគ្គលឯកជន មានការជ្រើសតាំងបណ្ណាធិការក្រុមហ៊ុន ឬប្រធាន សមាគមវត្តមានប្រធានគណៈកម្មការវត្ត សហគមន៍ជនជាតិដើមភាគតិចមានប្រធានសហគមន៍ ។ល។

តំណាងស្របច្បាប់ទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងអចលនវត្ថុ ដូចម្ចាស់សិទ្ធិជារូបវន្តបុគ្គលដែរ ឯប័ណ្ណដី ឬអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ និងឯកជនត្រូវប្រគល់ឲ្យតំណាងស្របច្បាប់នៃនីតិបុគ្គលនីមួយៗ ជាអ្នកទទួលយក និងរក្សាទុក។ ចំពោះប័ណ្ណដី ឬអចលនវត្ថុរបស់សមូហភាព ត្រូវប្រគល់ជូនដំណាងស្របច្បាប់ ឬប្រធានសហគមន៍ទទួលយក និងរក្សាទុក។

(ឯកសារបណ្តុះបណ្តាលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៤)។

# ជំពូក ៣

# វិធីសាស្ត្រសិក្សាស្រាវជ្រាវ

# ជំពូក ៣
# វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

## ៣.១ ការជ្រើសរើសទីតាំងសិក្សា

ដោយសារប្រធានបទសិក្សាស្រាវជ្រាវស្តីពី ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ មានសារៈសំខាន់ដែរនោះ ដូច្នេះហើយទើបយើងបានកំណត់យកសង្កាត់ មួយក្នុងក្រុងសៀមរាប ខេត្តសៀមរាបគឺ សង្កាត់គោកចក ដែលដីធ្លីនៅទីនោះបាននឹងកំពុងធ្វើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ម្យ៉ាងទៀតដើម្បីឲ្យ មានភាពងាយស្រួលដល់ការសិក្សាលើប្រធានបទនេះ យើងក៏បានជ្រើសរើស យកភូមិចំនួនពីរគឺ ភូមិត្រពាំងសេះ និងភូមិទក្សិណខាងត្បូង យកមកធ្វើការសិក្សា ពីព្រោះភូមិទាំងពីរនេះមានសក្តានុពលជាច្រើន ដែលទាក់ទងនឹង ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងបញ្ហានានាដែលបានជាប់ទាក់ទិនទៅនឹងតំបន់ថែរក្សាការពារ របស់អាជ្ញាធរជាតិអប្សរា។

## ៣.២ សម្ភារៈ និងមធ្យោបាយធ្វើដំណើរ

ដើម្បីឲ្យការសិក្សាស្រាវជ្រាវប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព និងមានភាពរលូននោះ កត្តាសម្ភារៈ និង ឧបករណ៍មួយចំនួន គឺជាកត្តាដ៏មានសារៈសំខាន់ក្នុងការប្រើប្រាស់ហើយវាមាន ២ ប្រភេទគឺ សម្ភារៈប្រើប្រាស់ សម្រាប់ការងារវាល និងការងារការិយាល័យដែលរួមមាន ៖

### ៣.២.១ សម្ភារៈសម្រាប់ការងារវាល

- ម៉ាស៊ីនថតរូប (Digital Camera)
- ម៉ាស៊ីនថតសម្លេង
- បញ្ជីសំណួរ
- ម៉ូតូ ឬយានជំនិះផ្សេងៗទៀត

### ៣.២.២ សម្ភារៈសម្រាប់ការងារការិយាល័យ

- កុំព្យូទ័រ
- ម៉ាស៊ីន ព្រីន, ស្កេន, និងថតចម្លង
- ឧបករណ៍ផ្ទុកទិន្នន័យ (flash drive)

### ៣.២.៣ មធ្យោបាយធ្វើដំណើរ

- រថយន្ត, ម៉ូតូ

## ៣.៣ វិធីសាស្ត្រជ្រើសរើសសំណាក

ការជ្រើសរើសសំណាក គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការស្រាវជ្រាវសារណាបទដែលអ្នកស្រាវជ្រាវត្រូវធ្វើការគិតគូរឲ្យបានល្អិតល្អន់ ដើម្បីជ្រើសរើសវិធីសាស្ត្រមួយឲ្យបានជាក់លាក់ដែលអាចធានាបានថាទិន្នន័យដែលប្រមូលបានមានកម្រិតលំអៀងអប្បបរមា និងអាចជឿជាក់បាន។

ការជ្រើសរើសសំណាកមាន ពីរប្រភេទ ៖

### ៣.៣.១ ការជ្រើសរើសសំណាកតាមគោលបំណង (Purposive Sampling)

ការជ្រើសសំណាកតាមគោលបំណង គឺធ្វើការបង្កើតនូវបញ្ជីសំនួរធ្វើបទសម្ភាសន៍ដើម្បីឆ្លើយតបទៅ នឹងគោលបំណងរបស់ប្រធានបទរួមមានធ្វើការសម្ភាសន៍ជាមួយ នឹងប្រធានមន្ទីរស្ថាប័នានាអាជ្ញាធរដែនដី ចាស់ព្រឹទ្ធាចារ្យ និងប្រជាពលរដ្ឋដែលជាកម្មសិទ្ធិករ ឬម្ចាស់អចលនទ្រព្យ។

តារាងទី៣.១ ចំនួនមន្ត្រីអាជ្ញាធរនៅមូលដ្ឋានដែលត្រូវសម្ភាសន៍តាមគោលបំណង

| ល.រ | អ្នកដែលត្រូវសម្ភាសន៍ | ចំនួន |
|---|---|---|
| ១ | អនុប្រធានមន្ទីរទទួលបន្ទុកការងារកម្មវិធីអនុវិស័យដីធ្លីខេត្តសៀមរាប | ១ |
| ២ | មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ (ប្រធានវាល) | ១ |
| ៣ | មន្ត្រីវាស់វែង និងកំណត់ព្រំ | ២ |
| ៤ | មន្ត្រីវិនិច្ឆ័យ | ២ |
| ៥ | មន្ត្រីអាជ្ញាធរអប្សរា | ១ |
| ៦ | ចៅសង្កាត់គោកចក | ១ |
| ៧ | មេភូមិត្រពាំងសេះ | ១ |
| ៨ | មេភូមិទក្សិណខាងត្បូង | ១ |
| ៩ | ប្រជាពលរដ្ឋ | ៧ |
| | សរុប | ១៧ |

ប្រភព៖ ទិន្នន័យអង្កេត

### ៣.៣.២ ការជ្រើសរើសសំណាកដោយចៃដន្យ

ក្រោយពីបានធ្វើការកំណត់បាននូវគោលដៅដើម្បីធ្វើការសម្ភាសន៍ហើយនោះ យើងធ្វើការប្រើប្រាស់នូវបញ្ជីសំនួរដើម្បីធ្វើការសម្ភាសន៍ប្រជាពលរដ្ឋដែលមាននៅក្នុងតំបន់សិក្សា។ ក្នុងការសម្ភាសន៍យើងមិនអាចធ្វើការសម្ភាសន៍ប្រជាពលរដ្ឋដែលមាននៅក្នុងភូមិនីមួយៗបានអស់នោះ ឡើយអាស្រ័យទៅលើពេលវេលានៃការសិក្សាមានការកំណត់ ដែលជាហេតុឲ្យយើងត្រូវជ្រើសរើសនូវសំណាកដោយចៃដន្យដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់ធ្វើការជ្រើសរើសសំណាកដើម្បីចុះទៅសម្ភាសន៍ និងប្រមូលទិន្នន័យពីប្រជាពលរដ្ឋនៅក្នុងតំបន់សិក្សា។ ចំពោះការជ្រើសរើសចំនួនសំណាកវិញត្រូវបានធ្វើនូវការគណនាតាម រូបមន្ត ២ ដូចខាងក្រោម៖

- រូបមន្តសម្រាប់គណនាសំណាកសរុប *(Yamane 1967)*

$$n = \frac{N}{1+\left(N \times e^{2}\right)}$$

-$n$ ជាចំនួនសំណាកសរុបដែលត្រូវជ្រើសរើស
-$N$ ជាចំនួនគ្រួសារក្នុងតំបន់សិក្សា
-$e$ ជាតម្លៃកម្រិតលំអៀងនៃបម្រែបម្រួល០%-១៥%

- រូបមន្តសម្រាប់គណនាសំណាកតាមភូមិនីមួយៗ *(Yamane 1973)*

$$n_i = \frac{n \times N_i}{N}$$

-$n$ ជាចំនួនសំណាកសរុបដែលត្រូវជ្រើសរើស
-$N_i$ ជាចំនួនគ្រួសារសរុបតាមភូមិនីមួយៗ
-$n_i$ ជាចំនួនសំណាកដែលត្រូវជ្រើសរើសក្នុងភូមិ

(**ប្រភព:** *Yamane, Taro 1967, Satistics book*)

ឆ្លងតាមលទ្ធផលនៃការគណនាចំនួនសំណាកសម្រាប់សម្ភាសន៍តាមភូមិមាន ភូមិត្រពាំងសេះ និងភូមិទក្សិណខាងត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ត្រូវបានសង្ខេបដូចតារាងខាងក្រោម៖

តារាងទី៣.២ ចំនួនគ្រួសាររបស់ប្រជាពលរដ្ឋក្នុងភូមិនៃសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រួសារ (នាក់) |
|---|---|---|---|---|
| សៀមរាប | សៀមរាប | គោកចក | ត្រពាំងសេះ | ២៦៨៣ |
| | | | ទក្សិណខាងត្បូង | ១១៩៦ |

( ប្រភព: ស្ថិតិទិន្នន័យសង្កាត់គោកចក ២០១៥ )

### ៣.៣.៣ វិធីសាស្ត្រគណនាសំណាក

តាមរូបមន្តរបស់ *Yamane* សំណាកសរុបគឺ ២៦៨៣+១១៩៦=៣៨៧៩ (e=១៣%)

ដូចនេះយើងបាន $n = \frac{៣៨៧៩}{១+(៣៨៧៩ \, x \, 0,១៣^{២})} = ៥៨.២៨ \approx ៥៨$ គ្រួសារ

ការគណនារកចំនួនសំណាកតាមភូមិនីមួយៗគឺ៖ $n_i = \frac{n \times N_i}{N}$

- ភូមិត្រពាំងសេះ $ni_{១} = \frac{២៦៨៣ \times ៥៨}{៣៨៧៩} = ៤0.១១ \approx ៤0$ គ្រួសារ

- ភូមិទក្សិណខាងត្បូង $ni_{២} = \frac{១១៩៦ \times ៥៨}{៣៨៧៩} = ១៧.៨៨ \approx ១៨$ គ្រួសារ

តារាងទី៣.៣ ចំនួនសំណាកដែលត្រូវជ្រើសរើសក្នុងការសម្ភាសន៍តាមភូមិនីមួយៗ

| ល.រ | ឈ្មោះឃុំ/សង្កាត់ | ឈ្មោះភូមិ | ចំនួនគ្រួសារសរុប | ចំនួនសំណាក | ភាគរយ |
|---|---|---|---|---|---|
| ១ | គោកចក | ត្រពាំងសេះ | ២៦៨៣ | ៤0 | ៦៩ |
| ២ | | ទក្សិណខាងត្បូង | ១១៩៦ | ១៨ | ៣១ |
| សរុប | | | **៣៨៧៩** | ៥៨ | ១00 |

ប្រភព: ទិន្នន័យអង្កេត

## ៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ

### ៣.៤.១ ទិន្នន័យមានស្រាប់

ចំពោះទិន្នន័យបន្ទាប់បន្សំ គឺជាទិន្នន័យ និងឯកសារដែលមានស្រាប់ដែលបានប្រមូលទុកសម្រាប់ជំនួយដល់ប្រធានបទ។ ឯកសារទាំងនេះ ជាភ្លើងបំភ្លឺផ្លូវដ៏សំខាន់ ក្នុងការស្វែងយល់ និងវិភាគនៅក្នុងការសិក្សាស្រាវជ្រាវនេះ ដោយឯកសារ និងទិន្នន័យទាំងនេះបានមកពី ៖

- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តសៀមរាប
- ស្ថាប័នផ្សេងៗទៀតដែលពាក់ព័ន្ធ
- បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទកសិកម្មឯកសាររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ឯកសារដែលផ្តល់ដោយសាស្ត្រាចារ្យដឹកនាំ និងជំនួយការ
- សារាចរណែនាំ សេចក្តីប្រកាសផ្សេងៗដែលពាក់ព័ន្ធ
- អ៊ិនធឺណែត

៣.៤.២ ទិន្នន័យបឋម

ទិន្នន័យនេះគឺជាទិន្នន័យដែលមានសារៈសំខាន់បំផុតដែលមិនអាចខ្វះបាន សម្រាប់យកមកធ្វើការវិភាគទិន្នន័យ ឬដើម្បីបង្ហាញលទ្ធផល។ ដើម្បីអាចទទួលបានទិន្នន័យនេះចាំបាច់ត្រូវចុះទៅតំបន់សិក្សា ដើម្បីធ្វើការអង្កេត និងសំភាសន៍រាល់បណ្តាអ្នកពាក់ព័ន្ធសំខាន់ៗ ដែលបានកំណត់ក្នុងការសិក្សាខាងលើ តាមរយៈការរៀបចំជាបញ្ជីសំនួរ ផ្សេងៗពីគ្នាតាមប្រភេទអ្នកពាក់ព័ន្ធ។ ការចុះអង្កេតផ្ទាល់នៅតាមតំបន់សិក្សាស្រាវជ្រាវ ដោយមានការសម្ភាសន៍ផ្ទាល់ជាមួយអ្នកដែលពាក់ព័ន្ធមួយចំនួនដូចជា៖

- អាជ្ញាធរមូលដ្ឋាន
- មន្រ្តីដែលពាក់ព័ន្ធ
- ប្រជាពលរដ្ឋដែលស្ថិតក្នុងតំបន់សិក្សាស្រាវជ្រាវ

## ៣.៥ វិធីសាស្រ្តវិភាគទិន្នន័យ

វិធីសាស្រ្តនេះ មានសារៈសំខាន់បំផុតក្នុងការសរសេរសារណាបទបញ្ចប់ការសិក្សារបស់អ្នកស្រាវជ្រាវឲ្យមានភាពល្អប្រសើរ និងជោគជ័យ។ ក្រោយពីបានប្រមូលទិន្នន័យរួចរាល់មក ទើបអ្នកស្រាវជ្រាវធ្វើការរៀបចំទិន្នន័យឲ្យបានរៀបរយទៅតាមប្រភេទទិន្នន័យនិងមានលក្ខណៈច្បាស់លាស់។ ការវិភាគទិន្នន័យធ្វើឡើងតាមវិធី សាស្រ្តពីរគឺ ការវិភាគទិន្នន័យតាមបែបបរិមាណ (Quantitative Analysis) និងការវិភាគទិន្នន័យតាមបែបគុណភាព (Qualitative Analysis)។

### ៣.៥.១ ការវិភាគទិន្នន័យតាមកម្មវិធី Microsoft Excel

ទិន្នន័យដែលប្រមូលបាននឹងត្រូវយកមកបញ្ចូល និងបំលែងជាតួលេខនៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយប្រើប្រាស់កម្មវិធី Microsoft Excel ដើម្បីវិភាគរកភាគរយ ក្នុងការបង្កើតជាតារាង ឬក្រាហ្វិក សម្រាប់បង្ហាញនៅក្នុងជំពូកលទ្ធផល និងការពិភាក្សា។

### ៣.៥.២ ការវិភាគទិន្នន័យបែប SWOT

SWOT ជាវិធីសាស្រ្តប្រើសម្រាប់វិភាគទៅលើភាពខ្លាំង ភាពខ្សោយ កាលានុវត្ត និងភាពគំរាមកំហែង។ វិធីសាស្រ្តនេះ នឹងជួយកំណត់កត្តាខាងក្នុង និងខាងក្រៅដែលសំខាន់ក្នុងការសម្រេចឲ្យបាននូវគោលបំណង។ វានឹងវិភាគ ដោយធ្វើឲ្យចំនុចខ្លាំង និងឱកាសកាន់តែខ្ពស់ ខណៈពេលដែលធ្វើឲ្យចំនុចខ្សោយ និងភាពគំរាមកំហែងកាន់តែទាប។ នៅក្នុងការសិក្សានេះ នឹងឆ្លុះបញ្ចាំងទៅលើទស្សនៈ គំនិតយោបល់ និងបទពិសោធន៍ ដើម្បីទាញចេញជាសេចក្តីសន្និដ្ឋានទៅលើប្រធានបទ ដែលលើកយកមកធ្វើការសិក្សា។

## ៣.៦ ដំណើរការនៃការចុះអង្កេត

គំនូសបំព្រួញទី ៣.១ ៖ ដំណើរការនៃការចុះអង្កេត



តារាងទី ៣.៤ ៖ តារាងវិភាគ SWOT




ប្រភព ៖ DSDP, MLMUPC, 2004

តារាងដែលមានប្រអប់បួនខាងលើ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការវិភាគទិន្នន័យ។ ជាមួយការវិភាគតាមកម្មវិធី Ms-Excel និងSWOT ក៏ត្រូវបានប្រើប្រាស់ក្នុងការទាញសេចក្តីសន្និដ្ឋាននៃការសិក្សាផងដែរ។

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

# ជំពូក ៤

# លទ្ធផល និង ការពិភាក្សា

## ៤.១ ស្ថានភាពទូរនៅតំបន់សិក្សា

### ៤.១.១ ស្ថានភាពទូទៅខេត្តសៀមរាប

ខេត្តសៀមរាបជាខេត្តមួយដែលមានទីតាំងនៅភាគពាយ័ព្យក្បែរបឹងទន្លេសាប។ ទីរួមខេត្តរបស់ខេត្តនេះគឺក្រុងសៀមរាប ។ ខេត្តនេះជាតំបន់ទេសចរណ៍ដ៏សំខាន់របស់ប្រទេសកម្ពុជា ដោយសារខេត្តសៀមរាបសំបូរទៅដោយប្រាង្គប្រាសាទបុរាណរាប់រយដ៏អស្ចារ្យ ជាពិសេសប្រាសាទអង្គរវត្តដ៏ល្បីល្បាញ។

ខេត្តសៀមរាបមានព្រំប្រទល់ ខាងកើតជាប់នឹងខេត្តកំពង់ធំ និងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ, ខាងជើងជាប់នឹងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ, និងខាងត្បូងជាប់នឹងខេត្តបាត់ដំបង និងបឹងទន្លេសាប។

( ប្រភព ៖ km.m.wikipedia.org )

ខេត្តសៀមរាបមានផ្ទៃដីសរុប ១០.២៩៩ គីឡូម៉ែតការ៉ចែកចេញជា ១២ ក្រុង ស្រុក ១០០ ឃុំ និង ៩០៧ ភូមិដោយមានប្រជាជនសរុប ៧៣៣.៨៨២ នាក់ ត្រូវជា ៦,០៩% នៃប្រជាជនសរុបទូទាំងប្រទេស។ មុខរបរសំខាន់នៃផ្នែកទាំងបីនេះមានភាពខុសៗគ្នាពោលគឺ៖

ក. ខាងលើធ្វើស្រូវចំការ និងរុករកអនុផលព្រៃឈើ

ខ. កណ្តាលធ្វើស្រែ និងសេវាកម្មផ្សេងៗ

គ. ខាងក្រោមធ្វើស្រែ និងចំការដំនាំតាមរដូវ និងប្រកបអាជីវកម្មនេសាទ។

ជាទូទៅខេត្តសៀមរាបមានលក្ខណៈជាតំបន់ជនបទ។ ប្រជាជនប្រមាណ ៧០% រស់នៅតាមទីជនបទឆ្ងាយពីក្រុងដែលផ្អែកលើមុខរបរកសិកម្មជាអាជីព។ ប្រជាជនប្រមាណ ១៨% រស់នៅតាមតំបន់ជាប់បឹងទន្លេសាបផ្អែកលើអាជីវកម្មនេសាទ និងធ្វើចំការដំណាំផ្សេងៗ និង ១២% ទៀតរស់នៅតាមទីប្រជុំជន និងក្រុងដែលមានមុខរបរពាណិជ្ជកម្ម ទេសចរណ៍ និងបុគ្គលិករដ្ឋ។

រូបភាពទី៤.១ ផែនទីរដ្ឋបាលខេត្តសៀមរាប
ប្រភព: នាយកដ្ឋានភូមិសាស្ត្រ



| ស្រុក | ឃុំ | ភូមិ |
|---|---|---|
| ស្រុកអង្គរជុំ | ៧ | ៨៤ |
| ស្រុកអង្គរធំ | ៤ | ២៥ |
| ស្រុកបន្ទាយស្រី | ៦ | ២៧ |
| ស្រុកជីក្រែង | ១២ | ១៤៧ |
| ស្រុកក្រឡាញ់ | ១០ | ៩៧ |
| ស្រុកពួក | ១៦ | ១៥៤ |
| ស្រុកប្រាសាទបាគង | ៩ | ៦៧ |
| ក្រុងសៀមរាប | ១០ | ៧៦ |
| ស្រុកសូត្រនិគម | ១០ | ១១៣ |
| ស្រុកស្រីស្នំ | ៦ | ៣៩ |
| ស្រុកស្វាយលើ | ៥ | ២១ |
| ស្រុកវ៉ារិន | ៥ | ២៥ |

### ៤.១.២ ទីតាំងភូមិសាស្ត្រក្រុងសៀមរាប

ក្រុងនេះ គឺស្ថិតក្នុងទីរួមខេត្តសៀមរាបតែម្តង ហើយដែលមានផ្ទៃក្រឡា ៣៤១ គ.ម² ហើយមានព្រំប្រទល់៖

- ខាងជើងទល់នឹង ស្រុកអង្គរធំ និង ស្រុកបន្ទាយស្រី
- ខាងត្បូងទល់នឹង បឹងទន្លេសាប និងស្រុកប្រាសាទបាគង
- ខាងកើតទល់នឹង ស្រុកប្រាសាទបាគង និងស្រុកបន្ទាយស្រី
- ខាងលិចទល់នឹង ស្រុកពួក

សណ្ឋានដីក្នុងស្រុកចែកចេញជា ២ ប្រភេទ ៖

1. ដីតំបន់ទំនាបកណ្តាល (សំរាប់ធ្វើស្រែ និងដំណាំចំការ)
2. ដីតំបន់ទំនាបក្រោមជាប់មាត់ទន្លេសាប (សំរាប់ធ្វើស្រែ និងដំណាំចំការ)

លក្ខណៈសណ្ឋានដីដូចនេះហើយ ដែលធ្វើឱ្យស្រុកមានអាកាសធាតុក្តៅ ហើយសើម សំបូរភ្លៀងដែលអំណោយផលដល់ដំណាំកសិកម្ម និងព្រៃឈើ។ ដីតំបន់ទំនាបជាប់មាត់ទន្លេសាបជាដីសំបូរជីជាតិ ដែលបង្កលក្ខណៈងាយស្រួលដល់ដំណាំស្រូវ និងអនុផល។ ដីតំបន់ទំនាបកណ្តាលជាដីខ្សោះជីជាតិ មានពណ៌សសំបូរខ្សាច់មិនសូវអំណោយផលដល់ដំណាំស្រូវទេ ។ ប្រភពទឹកសំខាន់ក្នុងស្រុកមាន ស្ទឹងសៀមរាប ដែលមានទឹកជាប្រចាំ និងប្រភពទឹកក្រោមដីប្រើប្រាស់ដោយជីកអណ្តូង។

(ប្រភព ៖ km.wikipedia.org/wiki/ក្រុងសៀមរាប)




រូបភាពទី៤.២ ផែនទីក្រុងសៀមរាប
ប្រភព: នាយកដ្ឋានភូមិសាស្ត្រ

## ៤.២ ស្ថានភាពភូមិសាស្ត្រសង្កាត់គោកចក

សង្កាត់គោកចក ជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំងឡាយក្នុងក្រុងសៀមរាប ដែលកំពុងទទួលបានការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធលើកដំបូង ដោយសារសង្កាត់នេះមានព្រំប្រទល់តំបន់ខ្លះជាប់នឹងដែនថៃរក្សាការពារអភិរក្សអង្គរ ទើបមានផលប៉ះពាល់ជាច្រើនជាមួយនឹងសង្កាត់នេះ។ សង្កាត់នេះមានទីតាំងនៅក្នុងទីរួមខេត្តសៀមរាបដែលមានព្រំប្រទល់

- ខាងជើងជាប់នឹង ស្រុកពួក និងស្រុកអង្គរធំ
- ខាងត្បូងជាប់នឹង សង្កាត់ស្រង៉ែ និងសង្កាត់ស្វាយដង្គំ
- ខាងកើតជាប់នឹង សង្កាត់គោកចក និងនគរធំ
- ខាងលិចជាប់នឹង សង្កាត់ទឹកវិល និងស្រុកពួក

សង្កាត់នេះមានចំនួន ៨ ភូមិ គឺភូមិទក្សិណខាងត្បូង ភូមិត្រពាំងសេះ ភូមិវាល ភូមិខ្វៀន ភូមិគោកចាន់ ភូមិនគរក្រៅ ភូមិគោករបេង និងភូមិគោកត្នោត ហើយមានផ្ទៃដីចំនួនសរុប ៧៥៨ ហិចតា មានចំនួន ៦១៨៥ ក្បាលដី។

(ប្រភព ៖ ទិន្នន័យសាលាសង្កាត់គោកចក)

### ក.ទីតាំងភូមិសាស្ត្រភូមិទក្សិណខាងត្បូង

ភូមិទក្សិណខាងត្បូង គឺស្ថិតនៅក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានប្រជាជនសរុបចំនួន ៤.៩៥៣ នាក់ ស្រីចំនួន ២.៤៨៤ នាក់ និងមានគ្រួសារសរុបចំនួន ១.៩៩៦ គ្រួសារ។

ភូមិទក្សិណខាងត្បូងមានព្រំប្រទល់ជាប់នឹង ៖

- ខាងជើងជាប់នឹង ភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
- ខាងកើតជាប់នឹង ក្រុងសៀមរាប ខេត្តសៀមរាប
- ខាងត្បូងជាប់នឹង ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
- ខាងលិចជាប់នឹង ភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប

ប្រភព: (ទិន្នន័យសាលាសង្កាត់សាលាគោកចក ឆ្នាំ ២០១៣)

### ខ. ទីតាំងភូមិសាស្ត្រភូមិត្រពាំងសេះ

ភូមិត្រពាំងសេះ គឺស្ថិតនៅក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានប្រជាជនសរុបចំនួន ១៣.៨៤៩ នាក់ ស្រីចំនួន ៨.២៨៤ នាក់ និងមានគ្រួសារសរុបចំនួន ២.៦៨៣ គ្រួសារ។

ភូមិត្រពាំងសេះមានព្រំប្រទល់ជាប់នឹង ៖

- ខាងជើងជាប់នឹង ភូមិខ្វៀន
- ខាងត្បូងជាប់នឹង ក្រុងសៀមរាប ខេត្តសៀមរាប
- ខាងកើតជាប់នឹង សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប
- ខាងលិចជាប់នឹង ភូមិទក្សិណខាងត្បូង

ប្រភព: (ទិន្នន័យសាលាសង្កាត់សាលាកំរើក ឆ្នាំ ២០១៣)




រូបភាពទី៤.៣ ផែនទីសង្កាត់គោកចក

ប្រភព: នាយកដ្ឋានភូមិសាស្ត្រ

## ៤.៣ ការកំណត់តំបន់ធ្វើការវិនិច្ឆ័យ

### ៤.៣.១ ការជ្រើសរើសតំបន់វិនិច្ឆ័យ

ការជ្រើសរើសតំបន់វិនិច្ឆ័យ គឺវាមានសារៈសំខាន់ណាស់សំរាប់ដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដោយត្រូវធ្វើការជ្រើសរើសយកតែតំបន់ណាដែលមានសុវត្ថិភាព ហើយគ្មានឧបសគ្គនានា និងមានការឯកភាពគ្នាក្នុង ការកំណត់ព្រំប្រទល់រដ្ឋបាល ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង។ ជាតំបន់ដែលកំណត់ព្រំប្រទល់ច្បាស់លាស់នូវ
ព្រំប្រទល់ដីសាធារណៈរបស់រដ្ឋជាដើម ដែលគ្មានបញ្ហាធ្វើអោយរំខានដល់ដំណើរការចុះបញ្ជីដីធ្លី ហើយតំបន់ដែលធ្វើទៅបាន គឺត្រូវតែជាតំបន់កំពុងរៀបចំធ្វើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

### ៤.៣.២ តំបន់ធ្វើការវិនិច្ឆ័យ

តំបន់ធ្វើការវិនិច្ឆ័យ គឺជាតំបន់ដែលត្រូវបានកំណត់យកដើម្បីធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដោយមានកិច្ច សហការរវាងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត រាជធានីជាមួយនឹងអាជ្ញាធរដែនដីដោយ ធ្វើការកំណត់រួមគ្នា និងបានចុះទៅធ្វើការសិក្សាពីព្រំប្រទល់ភូមិ ឬព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ខេត្ត រាជធានីដែលមានព្រំប្រទល់ជាប់ជាមួយ និងអំពីផលប៉ះពាល់ទាំងឡាយដែលកើតមានឡើងនៅក្នុងតំបន់នេះ នៅលើ រូបថតពីលើអាកាស ដើម្បីធ្វើការពិភាក្សាគ្នានៅពេលមានកិច្ចប្រជុំគណៈកម្មការអភិវឌ្ឍ ខេត្ត រាជធានី ដោយមានការ ចូលរួមពីមន្ទីរជុំវិញ ខេត្ត រាជធានី និងស្ថាប័នដែលពាក់ព័ន្ធ។

ក្រោយពីតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់រួចហើយ អភិបាលខេត្ត រាជធានី ត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនទី តាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ។

ក្នុងឱកាសប្រជុំផ្សព្វផ្សាយសេចក្តីប្រកាស់កំណត់ធ្វើការវិនិច្ឆ័យមន្ត្រីគ្រប់គ្រងការងារកំណត់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់អំពីដំណើរការនៃការវិនិច្ឆ័យ ភាពចាំបាច់ និងឱកាសដែលប្រជាជនជាម្ចាស់សិទ្ធិត្រូវចូលរួមបភ្លឺអំពីសិទ្ធិស្របច្បាប់លើអចលនវត្ថុ និងកាតព្វកិច្ចដែលត្រូវបំពេញព្រមទាំងឆ្លើយនូវរាល់សំណួរដែលបាន លើកឡើងក្នុងអង្គប្រជុំ។ ផ្អែកលើសារៈសំខាន់ដូចបានបញ្ជាក់ខាងលើសេចក្តីជូនដំណឹងត្រូវផ្សព្វផ្សាយឲ្យបានទូលំ ទូលាយ និងមានប្រសិទ្ធិភាព។ កិច្ចប្រជុំបន្ថែមសំរាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំដោយមន្ត្រីផ្សព្វផ្សាយ និងរៀបចំដែនដី ក្រោយពីបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ។

ការបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់ទីតាំងធ្វើការវិនិច្ឆ័យត្រូវប្រព្រឹត្តិទៅនៅក្នុង ទីកន្លែងណាមួយក្នុងតំបន់ធ្វើការវិនិច្ឆ័យដែលមានដូចជា៖ ទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ សង្កាត់ សាលាក្រុង ស្រុក ខណ្ឌ ខេត្ត រាជធានី ដោយយោងតាមស្ថានភាពជាក់ស្តែងនៃទីតាំងវិនិច្ឆ័យនីមួយៗ។

## ៤.៤ ការរៀបចំផែនការក្នុងតំបន់វិនិច្ឆ័យ និងនៅថ្នាក់ភូមិ

ដើម្បីអោយការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដំណើរការទៅបានល្អប្រសើរ លុះត្រាតែមានការចូលរួមយ៉ាងពេញទំហឹងពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក៏ដូចជាអាជ្ញាធរមូលដ្ឋានផ្ទាល់ផង ទាំងមន្ទីររៀបចំដែនដីត្រូវធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទាំងនោះ រួមទាំងប្រជាពលរដ្ឋដែលជាម្ចាស់ដី / ឬអ្នកកាន់កាប់ដីទាំងអស់ ព្រមទាំងអ្នកដែលពាក់ព័ន្ធ និងអ្នកដែលបោះទីលំនៅលើដីសាធារណៈផងដែរ។ ដើម្បីអោយការអនុវត្តការងារនៅក្នុងតំបន់វិនិច្ឆ័យ ទទួលបានជោគជ័យ មន្ត្រីផ្សព្វផ្សាយត្រូវផ្តោតសំខាន់ទៅលើការប្រមូលទិន្នន័យ ដែលទាក់ទងទៅនឹងប្រវត្តិដីភូមិ ធ្វើការផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ភូមិបាល និងនីតិវិធីក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

### ៤.៤.១ គោលបំណងនៃការផ្សព្វផ្សាយ

គោលបំណងនៃសមាសភាពរងនេះធានាអោយបាននូវ ៖

- សកម្មភាពការងាររបស់មន្ត្រីផ្សព្វផ្សាយ និងរៀបចំដែនដី សំរាប់ការងារទំនាក់ទំនង
- ការចូលរួមយ៉ាងពេញទំហឹងពីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន និងការចូលរួមរបស់ម្ចាស់ដី/អ្នកកាន់កាប់នៅក្នុងតំបន់វិនិច្ឆ័យ
- ការស្រាវជ្រាវលើឯកសារតម្កល់ ដើម្បីពិនិត្យមើលនូវសិទ្ធិធរមានលើដីដែលមានការចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីដែលមានជាធរមាននាពេលបច្ចុប្បន្ន
- ការយល់ដឹងថាពួកគាត់ដែលជាម្ចាស់ដី /អ្នកកាន់កាប់ដីគ្រប់រូបទាំងអស់ មានសិទ្ធិទទួលបាននូវកម្មសិទ្ធិនៅលើដីធ្លីជាដើម ព្រមទាំងកាតព្វកិច្ចចូលរួមក្នុងការចុះបញ្ជីដីធ្លី
- ប្រមូលយកបញ្ជីក្បាលដីដែលបានចុះបញ្ជី និងអ្នកកាន់កាប់ក្បាលដី ដែលស្ថិតនៅតំបន់វិនិច្ឆ័យ
- សហការជាមួយមន្ត្រីមកពីសាលាក្រុងដែលត្រូវចាត់តាំងអោយរៀបចំចុះបញ្ជីនោះ

ដើម្បីអោយការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធប្រព្រឹត្តិទៅបានល្អប្រសើរមន្ត្រីផ្សព្វផ្សាយត្រូវទៅទំនាក់ទំនង ជាមួយអាជ្ញាធរមូលដ្ឋាន ឬប្រជាពលរដ្ឋដែលមានការអប់រំ ហើយមានការគោរពពីប្រជាពលរដ្ឋនៅក្នុងភូមិដូចជា ៖

**ក. មេភូមិ**

គាត់ជាមនុស្សដែលអាចដឹងរឿងអ្វីៗដែលកើតឡើងនៅក្នុងភូមិ។ ប្រធានភូមិក៏ជាអ្នកពាក់ព័ន្ធដោយផ្ទាល់ក្នុងការចុះបញ្ជីដីធ្លីក្នុងឋានៈជាអ្នកតំណាងផ្លូវការរបស់ប្រជាជនក្នុងភូមិ។

**ខ. មេឃុំ / ចៅសង្កាត់**

គាត់ជាអ្នកពាក់ព័ន្ធនៅក្នុងដំណើរការតាំងទីលំនៅ និងចូលរួមចំណែកក្នុងការចុះបញ្ជីដីធ្លី តាមរយៈវត្តមាន
របស់គាត់នៅពេលបិទផ្សាយជាសាធារណៈ។

**គ. ប្រជាពលរដ្ឋដែលមានការអប់រំ និងមានការគោរពនៅក្នុងភូមិ**

- អ្នកដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ
- អ្នកមានតួនាទីសំខាន់នៅក្នុងភូមិដូចជា គ្រូបង្រៀន ចាស់ព្រឹទ្ធាចារ្យ
- អ្នកមានសមត្ថភាពខាងបញ្ញា អាចយល់ដឹងងាយស្រួលនូវដំណើរការ និងលទ្ធផលទទួលបានពីការចុះបញ្ជីដីធ្លី

### ៨.៨.២ តួនាទី និងភារកិច្ចរបស់មន្ត្រីផ្សព្វផ្សាយ

- រាល់អ្នកពាក់ព័ន្ធត្រូវបានទទួលបានព័ត៌មាន ដើម្បីចូលរួមក្នុងកិច្ចប្រជុំថ្នាក់ ខេត្ត ក្រុង
- មន្ត្រីផ្សព្វផ្សាយត្រូវធ្វើកិច្ចសហការជាមួយមន្ត្រីការិយាល័យនៃក្រុមចុះបញ្ជីដីធ្លី ដើម្បីរៀបចំរូបថតទៅតាម ឃុំ សង្កាត់ (តួរលេខ កំណត់ត្រា) ដែលមានមាត្រដ្ឋាន ១ = ១០០០០០ ទៅតាមទំហំផែនទីគោលដែលមានលក្ខណៈស្តង់ដា សម្រាប់គម្រោង និងរៀបចំការងារវាលសម្រាប់ការជជែកពិភាក្សា។ មាត្រដ្ឋានផ្សេងទៀតនឹងអាចរៀបចំឡើងតាមតម្រូវការជាក់ស្តែង។
- ប្រមូលទិន្នន័យសម្រាប់រៀបចំឯកសារប្រវត្តិដីភូមិ ដោយធ្វើការប្រជុំជាមួយមេភូមិ និងជាមួយ
- គណៈកម្មការអភិវឌ្ឍភូមិ ដើម្បីបង្កើតកិច្ចពិភាក្សាជាមួយក្រុមគោលដៅ (ក្រុមបុរស និងក្រុមស្ត្រី)
- កំណត់កាលបរិច្ឆេទ នៃការចូលរួមរបស់ប្រជាពលរដ្ឋតាមភូមិនីមួយៗ ក្នុងតំបន់វិនិច្ឆ័យ
- រៀបចំវគ្គផ្សព្វផ្សាយព័ត៌មានដីធ្លីជាសាធារណៈជាក្រុមបុរស និងក្រុមស្ត្រីដើម្បីជូនព័ត៌មានដល់ពួកគាត់អំពីច្បាប់ភូមិបាល សិទ្ធិ និងកាតព្វកិច្ចនៃដំណើរការចុះបញ្ជីដីធ្លី រួមទាំងផលប្រយោជន៍នៃ ប័ណ្ណកម្មសិទ្ធិដីធ្លី
- វិភាគ និងសង្ខេបព័ត៌មានដែលប្រមូលបានពីមេភូមិសម្រាប់ធ្វើការបង្ហាញទៅម្ចាស់ដី
- ប្រើប្រាស់សម្ភារៈអប់រំសមស្រប (រៀបចំដោយគម្រោង LMAP) ក្នុងកំឡុងពេលវគ្គអប់រំ
- បង្ហាត់បង្ហាញដល់ក្រុមពិសេស (ជនពិការ ស្ត្រីមេម៉ាយ គ្រួសារក្រីក្រ ជនមិនចេះអក្សរ) ដែលមិនបានចូលរួមវគ្គផ្សព្វផ្សាយព័ត៌មានដីធ្លីជាសាធារណៈ និងជួបជាមួយពួកគាត់ម្នាក់ៗដោយផ្ទាល់
- បង្ហាញពីជម្លោះដីធ្លីដែលមាននៅក្នុងភូមិក្នុងរូបថតពីលើអាកាស រក្សាឯកសារនោះទុក និងជូន ព័ត៌មាននេះដល់ក្រុមចុះបញ្ជីដីធ្លី
- រៀបចំការប្រជុំតាមភូមិនីមួយៗដើម្បីពន្យល់អំពីការផ្តល់ប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដំណើរការនៃការផ្ទេរប័ណ្ណកម្មសិទ្ធិ។
- រៀបចំរបាយការណ៍ស្តីពីប្រវត្តិដីភូមិ ជូនមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ

- រៀបចំផែនការការងារឲ្យទៀងទាត់ជាមួយមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ដើម្បីធ្វើផែនការជាមួយក្រុមចុះបញ្ជីដីធ្លី
- ឆ្លើយតបទៅនឹងសំណើររបស់មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ
- ជួយសមាជិកគណៈកម្មការរដ្ឋបាល (មេឃុំ/ចៅសង្កាត់ មេភូមិ និងចាស់ព្រឹទ្ធាចារ្យ) ក្នុងការរៀបចំផែនការសកម្មភាពការងារក្នុងភូមិ
- ត្រូវកំណត់បញ្ជាក់ឲ្យច្បាស់រវាងតំបន់ទីប្រជុំជន និងជនបទ ដីកសិកម្ម ដីលំនៅដ្ឋាន ដីរដ្ឋ និងដីឯកជន
- ត្រូវកំណត់បញ្ជាក់ព្រំប្រទល់ភូមិ និងព្រំប្រទល់រដ្ឋបាល (ឃុំ សង្កាត់ ខណ្ឌ ខេត្ត ក្រុង) នៅលើរូបថតពីលើអាកាស ដោយមានកំណត់ហេតុនៃការព្រមព្រៀងគ្នារវាងគូភាគីទាំងសងខាង
- ត្រូវធ្វើការវិនិច្ឆ័យដីចំណីសាធារណៈ (ផ្លូវ ប្រឡាយ អូរ ព្រៃក ស្ទឹង បឹង ទន្លេ សមុទ្រ...) ដើម្បីអនុវត្តឲ្យបានជោគជ័យនូវការងារទាំងនេះ មន្ត្រីទទួលបន្ទុកផ្នែកផ្សព្វផ្សាយ ចាំបាច់ត្រូវតែមានកិច្ចសហការយ៉ាងជិតស្និទ្ធិជាមួយអាជ្ញាធរមូលដ្ឋាន ដែលស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ និងត្រូវចុះទៅផ្សព្វផ្សាយជាមុនដល់ម្ចាស់ដី អ្នកកាន់កាប់ដីក្នុងតំបន់វិនិច្ឆ័យឲ្យយល់ច្បាស់ពីប្រភពនៃការកាន់កាប់ និងសិទ្ធិប្រើប្រាស់ដីរបស់ខ្លួននៅពេលដែលក្រុមចុះបញ្ជីទៅដល់ ដោយធ្វើការពន្យល់បកស្រាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ របស់គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ដល់ម្ចាស់ដីអ្នកកាន់កាប់ដូចជា ៖
    - ធ្វើការដាំបង្គោលព្រំដីរឹងមាំ ដោយមានការឯកភាពគ្នា រវាងអ្នកជាប់ព្រំ
    - ធ្វើការព្រមព្រៀងគ្នា និងកំណត់ផ្លូវចេញចូលដែលជាផ្លូវសេវភាព
    - បង្ហាញជូនដល់មន្ត្រីកំណត់ព្រំ មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ឬលិខិតឆ្លងដែន
    - រៀបចំប្រមូលឯកសារផ្លូវការ ឬភស្តុតាងផ្សេងៗទៀតត្រៀមទុកជាមុន
    - ឯកសារចេញដោយអាជ្ញាធរមានសមត្ថកិច្ច សំបុត្រកិច្ចសន្យា កិច្ចព្រមព្រៀង បណ្តាំមរតក សាលក្រមពីតុលាការ លិខិតអនុញ្ញាតិផ្លូវការដទៃទៀត ។ល។

### ៤.៤.៣ កាតព្វកិច្ចរបស់ម្ចាស់ដី និងអ្នកកាន់កាប់ដី

#### ក.តម្រូវការចាំបាច់របស់មន្ត្រីកំណត់ព្រំ និងវាស់វែង

- ម្ចាស់ដី/អ្នកកាន់កាប់ដីត្រូវបោះបង្គោលព្រំដីរបស់ខ្លួនក្រោយពីមានការព្រមព្រៀង
- ម្ចាស់ដីអ្នកកាន់កាប់ដីត្រូវចូលរួមធ្វើការកំណត់ព្រំជាមួយមន្ត្រីកំណត់ព្រំ (អ្នកដែលស្គាល់ព្រំប្រទល់ក្បាលដីច្បាស់ ដោយមិនអនុញ្ញាតឲ្យអ្នកផ្សេង ឬអ្នកដែលមិនគ្រប់អាយុផ្តល់ព័ត៌មានឡើយ)
- ជួយឆ្ការព្រៃក្នុងករណីដែលធ្វើឲ្យរាំងស្ទះដល់ការកំណត់ព្រំ និងវាស់វែង
- ចូលរួមធ្វើការកំណត់ព្រំប្រទល់ក្បាលដីរបស់ខ្លួនជាមួយមន្ត្រីវាស់វែង

- ធ្វើការបំភ្លឺឲ្យបានច្បាស់លាស់ចំពោះក្បាលដីណាដែលមានប័ណ្ណកម្មសិទ្ធិរួចហើយ
- ជួយកាន់សំភារៈវាស់វែងនៅពេលដែលមានការចាំបាច់ក្នុងការកំណត់ព្រំប្រទល់ក្បាលដី
- ម្ចាស់ដីត្រូវចូលរួមដោយផ្ទាល់ ក្នុងការផ្តល់ព័ត៌មានលម្អិតអំពីក្បាលដីរបស់ខ្លួន

ខ.តម្រូវការចាំបាច់របស់មន្ត្រីវិនិច្ឆ័យ

- តើដីនោះមានរូបភាពជាអ្វី (ដីសាងសង់ ដីផលិតកម្មកសិកម្ម)
- បង្ហាញនូវភស្តុតាងដែលបញ្ជាក់ថា ខ្លួនជាម្ចាស់ដី/ អ្នកកាន់កាប់ដី តាមរយៈឯកសារជាលាយលក្ខណ៍អក្សរ ភស្តុតាងជាក់ស្តែង ឫកស្សិណសាក្សីផ្ទាល់ពីអ្នកជិតខាង និងមេភូមិ
- តើអ្នកណាជាម្ចាស់ ឫជាអ្នកកាន់កាប់ទ្រព្យសម្បត្តិនេះ (ទ្រព្យខាងប្តី ទ្រព្យខាងប្រពន្ធ ទ្រព្យរួមប្តីប្រពន្ធ ទ្រព្យអវិភាគ សហកម្មសិទ្ធិ)
- ឈ្មោះថ្ងៃ ខែ ឆ្នាំកំណើត ឋានៈស៊ីវិល ទីកន្លែងកំណើត សញ្ជាតិ ឈ្មោះឪពុក ម្តាយ និងលំនៅបច្ចុប្បន្នម្ចាស់ដី / អ្នកកាន់កាប់ដី
- តើដីនេះមានជាប់បន្ទុកអីទេ (ជួល បញ្ចាំ ? ព័ត៌មានអស់ទាំងនេះត្រូវបានបំពេញនៅក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យ
- តើម្ចាស់ដី /អ្នកកាន់កាប់ដីមានអ្វីជាសំអាងលើស្ថានភាពនៃច្បាប់? (ប័ណ្ណកម្មសិទ្ធិ ប័ណ្ណសម្គាល់សិទ្ធិ)
- តើអ្នកបានធ្វើជាម្ចាស់ ឫកាន់កាប់ដីធ្លីនេះដោយវិធីណា និងកាលបរិច្ឆេទនៃការកាន់កាប់នេះជាលើកដំបូងបង្អស់?

## ៤.៥ ការងារចម្បងរបស់មន្ត្រីផ្សព្វផ្សាយ

### ៤.៥.១ ការរៀបចំជាមុននូវការងាររដ្ឋបាលរបស់មន្ត្រីផ្សព្វផ្សាយ

១. រៀបចំការជ្រើសរើស និង កំណត់តំបន់វិនិច្ឆ័យ (ភូមិ ឃុំ/សង្កាត់) ដោយធ្វើការសហការជាមួយគណៈកម្មការរដ្ឋបាល។ ផ្នែកនេះនឹងត្រូវអនុវត្តក្រោមការណែនាំរបស់នាយកចាត់ការគំរោងខេត្ត/ក្រុង និងមានកិច្ចសហកាដោយផ្ទាល់ជាមួយនឹងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ។

២. បោះពុម្ពចេញនូវរូបថតពីលើអាកាសនៃតំបន់វិនិច្ឆ័យ ដោយសហការជាមួយមន្ត្រីការងារការិយាល័យ។

៣. សហការជាមួយនឹងមន្ត្រីការិយាល័យនៃក្រុមការងារចុះបញ្ជីដីធ្លី ដើម្បីបញ្ចូលព្រំប្រទល់ ឃុំ/សង្កាត់ ដែលបានមកពីនាយកដ្ឋានភូមិសាស្រ្ត សំរាប់រៀបចំរូបថតដែលមានខ្សែព្រំប្រទល់ក្នុងមាត្រដ្ឋាន ១: ១០០០០០ សំរាប់ធ្វើជាផែនទីគោល និងជាស្តង់ដាសំរាប់ការធ្វើផែនការ ដើម្បីរៀបចំការងារនៅវាល និងសំរាប់បង្ហាញក្នុងការប្រជុំពិភាក្សា។ រូបថតអ័រតូហ្វូតូក្នុងមាត្រដ្ឋានដទៃទៀត និងធ្វើតាមការចាំបាច់។

៤. ស្រាវជ្រាវរកទិន្នន័យជំរឿន អំពីភូមិ ឃុំ/សង្កាត់ គោលដៅ (ជំរឿនប្រជាជន ឆ្នាំ ១៩៩៨ ឫទិន្នន័យថ្មីៗផ្សេងទៀត) ដើម្បីប្រើប្រាស់ធ្វើជាមូលដ្ឋានសំរាប់កំណត់ចំណាត់ថ្នាក់ដី និងការធ្វើផែនការលំអិតសំរាប់ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ (ដីសាធារណៈ ដីទំនាស់ ដីសាងសង់ តំបន់ទីប្រជុំជន.....

តាមគោលការណ៍នៃការកំណត់ព្រំដីប្រសិនបើមានព្រំប្រទល់រដ្ឋបាលណាមួយស្ថិតនៅក្នុងតំបន់វិនិច្ឆ័យ នោះវានឹងត្រូវបានគេធ្វើការពិនិត្យវាស់វែងមុនគេ ។ ការអនុវត្តន៍នេះត្រូវធ្វើឡើងក្រោមវត្តមាន របស់អភិបាលខេត្ត ក្រុង អភិបាលស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ និងមេភូមិ នៃភាគីទាំងពីររបស់ព្រំប្រទល់រដ្ឋបាល។ នៅពេលដែលវាលេចឡើងថាព្រំដីធម្មតានឹងក្លាយព្រំប្រទល់រដ្ឋបាលនោះគ្រប់ម្ចាស់ដីពិតប្រាកដនៃភាគីទាំងសងខាង និងក្លាយជាក្រុមតែមួយទោះបីជាពួកគេស្ថិតនៅក្រៅតំបន់វិនិច្ឆ័យក្នុងភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ឬខេត្ត/ក្រុងខុសគ្នាក៏ដោយ។ ពួកគេត្រូវតែចូលរួមក្នុងការកំណត់ព្រំដី និងការផ្សព្វផ្សាយជាសាធារណៈ (មាត្រា ១៥ និង ១៤៨ នៃច្បាប់ភូមិបាល ឆ្នាំ២០០១)។

ការប្រើប្រាស់ដែលធ្វើបានកម្មសិទ្ធករ នៃដីប្រើមានសិទ្ធិធ្វើរាល់ការចាំបាច់ផ្សេងៗ លើដីបំរើដើម្បីប្រើ និងរក្សាទុកសេវភាពបាន ការអនុញ្ញាតឲ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀងទាត់ឡើយ ហើយអាចដកហូតមកវិញបាន (មាត្រា ១៦៣ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១)។

### ៤.៥.២ ការពិភាក្សាជាមួយរដ្ឋអំណាចមូលដ្ឋានអំពីស្ថានភាពបច្ចុប្បន្ន

១. ធ្វើការជួបប្រជុំជាមួយមេភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងតំណាងអភិបាលស្រុក/ខណ្ឌ ដោយធ្វើការន្យល់
អំពី ដំណើរការនៃការកំណត់បញ្ជាក់ព្រំប្រទល់ឃុំ/សង្កាត់នៅលើផែនទី។ មេភូមិនៃភូមិដែលមានព្រំប្រទល់ប្រទល់ជាប់ព្រំ ឃុំ/សង្កាត់ ត្រូវបានស្នើសុំឲ្យចូលរួមផ្តល់យោបល់អំពីសេចក្តីព្រាងព្រំប្រទល់ឃុំ/សង្កាត់ និងជួយកែសំរួលនូវព្រំទល់ ប្រទល់ឃុំ/សង្កាត់ ដោយមានជំនួយពីមន្ត្រីផ្សព្វផ្សាយ ប្រសិនបើគាត់ត្រូវការ។ ក្នុងករណីដែលព្រំប្រទល់ភូមិ ឬព្រំប្រទល់រដ្ឋបាលពុំមានការព្រមព្រៀងគ្នា ឬខុសពីការកំណត់របស់ក្រសួងមហាផ្ទៃ មន្ត្រីផ្សព្វផ្សាយ និងធ្វើរបាយការណ៍ជាបន្ទាន់មន្ត្រីគ្រប់គ្រងការងារវិនិច្ឆ័យ ដើម្បីរាយការណ៍បន្តមកនាយកចាត់ការគម្រោងរៀបចំដែដី និងរដ្ឋបាលដីធ្លី ខេត្ត/ក្រុង ដើម្បីរាយការណ៍បន្តមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមរយៈប្រធានគណៈកម្មការរដ្ឋបាល។

២. ធ្វើការប្រជុំស្តីពីការកំណត់បញ្ជាក់ព្រំប្រទល់ឃុំ/សង្កាត់ ដើម្បីពិភាក្សាអំពីសេចក្តីព្រាងព្រំប្រទល់ និងការកែសំរួលព្រំប្រទល់ដែលបានស្នើឡើងវាយតំលៃអំពីស្ថានភាពជាក់ស្តែងនៅវាលប្រសិនបើចាំបាច់ដោយមានការផ្តល់មតិជាទូទៅ។ អ្នកចូលរួមមានអាជ្ញាធរស្រុក/ខណ្ឌ ក្រុមប្រឹក្សាឃុំ/សង្កាត់ មេភូមិ និងមន្ត្រីពាក់ព័ន្ធមូលដ្ឋាន។

៣.កំណត់ខ្សែបន្ទាត់ព្រំប្រទល់ទីប្រជុំជន ជនបទ និងលំនៅដ្ឋាន ( តំបន់កសិកម្ម ព្រៃឈើ ដែនទឹក) ដោយសហការជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ និងមន្ត្រីពាក់ព័ន្ធនៅមូលដ្ឋាន (ចំណុចទី ២ និងទី ៣ អាចធ្វើការក្នុងពេលតែមួយ ឬដាច់ដោយឡែក)។

៤. ទាក់ទងជាមួយមន្ទីសាធារណៈការ និងដឹកជញ្ជូន ដើម្បីរកស្តង់ដាដីចំណីសាធារណៈ (សេចក្តីប្រកាសលេខ ០៦ ប្រក ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លីចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ១៩៩៩ សំរាប់តំបន់) ដែលត្រូវធ្វើការកែសំរួលដូចជា

ក. តំបន់កសិកម្ម

ខ. តំបន់លំនៅដ្ឋាន ឬតំបន់ទីប្រជុំជនដែលមានចែងក្នុងចំណុច ៣ (អាចធ្វើការក្នុងពេលតែមួយ ឬដាច់ដោយឡែកជាមួយចំណុចទី២ និងទី ៣)

៥. ទាក់ទងជាមួយនឹងមន្ទីរធនធានទឹក និងឧត្តុនិយម ដើម្បីកំណត់ដីចំណីសាធារណៈតាមមាត់ទឹក

៦.ទាក់ទងនឹងអាជ្ញាធររាជាយស្ម័យយាន្ត ដើម្បីកំណត់ដីចំណីសាធារណៈតាមតំបន់ដងផ្លូវរថភ្លើង

៧. ទំនាក់ទំនងជាមួយមន្ទីវប្បធម៌ វិចិត្រសិល្បៈ និងមន្ទីបរិដ្ឋាន ដើម្បីកំនត់តំបន់ បេតិកភ័ណ្ឌ និងតំបន់ការពារ។

### ៤.៤.៣ ការប្រមូលទិន្នន័យពីអាជ្ញាធរមូលដ្ឋាន

បោះពុម្ភចេញនូវរូបថតពីលើអាកាស សំរាប់ភូមិ ឃុំ/សង្កាត់ (តំបន់ទីប្រជុំជន និងលំនៅដ្ឋានដែលមាន មាត្រដ្ឋាន ១:៤ ០០០ និងតំបន់ជនបទដែលមានមាត្រា ១:១០ ០០០)។

- ជួយដល់មេភូមិក្នុងការកំណត់រកទីតាំងនៃតំបន់លំនៅដ្ឋាន តំបន់ទីប្រជុំជនក្នុងភូមិ ដីចំណីផ្លូវ ដីចំណីមាត់ទឹក (មាត្រា ១០៤ និង១០៥ នៃច្បាប់ភូមិបាល) និងដីចំណីសាធារណៈផ្សេងទៀត នៅលើរូបថតអ័រតូហ្វូតូ( ផ្លូវដែលបានកំណត់រួចក្នុងប្រកាសលេខ ០៦(ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្រ្ទានកាន់កាប់ដីធ្លី) ផ្លូវភូមិ និងផ្លូវឯកជន មាត្រា ១៦០ និង១៦៧ នៃច្បាប់ភូមិបាល)។
- ជួយសំរួលដល់មេភូមិក្នុងការកំណត់ និងបង្ហាញទីតាំងព្រំប្រទប់ភូមិរបស់គាត់នៅលើរូបថត។ មន្ត្រីផ្សព្វផ្សាយត្រូវធ្វើការកំណត់សំគាល់ឲ្យបានច្បាប់អំពីបញ្ហា និងទំនាស់នៅលើរូបថត ហើយត្រូវសរសេរកំណត់ហេតុខ្លីៗ អំពីករណីនីមួយៗនៅលើក្រដាស់ដោយឡែក។ ប្រសិនបើការកំណត់បញ្ជាក់ព្រំប្រទល់មិនអាចធ្វើបាននៅក្នុងការិយាល័យទេ មន្ត្រីផ្សព្វផ្សាយត្រូវស្នើសុំទៅមេភូមិ និងមេភូមិជិតខាង ឬតំណាងក្រុមប្រឹក្សាឃុំ/សង្កាត់ចុះទៅ ទីតាំងជាក់ស្តែងដើម្បីធ្វើការផ្ទៀងផ្ទាត់ និងពិនិត្យមើលជាមួយរូបថត ដោយគូសបញ្ចូលតាមខ្សែបន្ទាត់ ដែលមេភូមិ ឃុំ/សង្កាត់ ទាំងអស់បានព្រមព្រៀងគ្នា(កំណត់ហេតុ)។
- ក្រោយពីទទួលបានរូបថតអ័រតូហ្វូតូនៃតំបន់វិនិច្ឆ័យ ដែលបង្ហាញ អំពីសេចក្តីពញ្ញរាងព្រំប្រទល់រដ្ឋបាល ដីចំណីសាធារណៈ ទីប្រជុំជននៅក្នុងតំបន់ទាំងនោះនិងយល់ដឹងពីទំនាស់ដែលកើតមានក្នុងករណីនីមួយៗ ហើយត្រូវបានរៀបចំទុកជារបាយការណ៍ដោយឡែក។ មន្ត្រីផ្សព្វផ្សាយត្រូវបង្ហាញអំពីឯកសារដែលរៀបចំរួច សំរាប់អង្គប្រជុំភូមិដើម្បីផ្ទៀងផ្ទាត់បញ្ចប់ និងប្រមូលទិន្នន័យចុងក្រោយ។ ផែនទីភូមិដែលបង្ហាញពីព្រំប្រទល់រដ្ឋបាល ដីចំណីសាធារណៈ ដីចំណីផ្លូវ ព្រំប្រទល់តំបន់ទីប្រជុំជន និងជនបទ និងរបាយការណ៍ ដែលកត់សំគាល់អំពីជំរឿន ប្រជាជនទីតាំងដែលមានបញ្ហា និងទំនាស់ដែលកើតមានឡើងក្នុងពេលចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ឯកសារទាំងនេះត្រូវប្រគល់ជូនទៅឲ្យមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យដើម្បីរៀបចំធ្វើផែនការ និងជារបាយការណ៍បីការិយាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លីខេត្ត/ក្រុង។

ការបង្ហាញនេះមិនរៀបរាប់លំអិតដូចប្លង់សុរិយោដីទេ ក៏ប៉ុន្តែបានវាយតំលៃស្ថានភាពដីជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋដែលធ្វើឡើងនៅលើរូបថតពីលើអាកាស។

ក្រុមការងារ ត្រូវកសាងផែនទីស្ថានភាពដីធ្លីសមស្របមួយដោយផ្អែកលើរូបថតពីលើអាកាស និងយករូបថតស្ថានភាពដីធ្លីនេះដាក់ស្នើទៅមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងក្រុមប្រឹក្សាឃុំ/សង្កាត់ ដើម្បី

ពិចារណា ប្រសិនបើការកំណត់តំបន់មានភាពត្រឹមត្រូវ ដូចនេះបណ្ណកម្មសិទ្ធិអាចធ្វើទៅបានសំរាប់ដីរដ្ឋ និងដីឯកជន។ កិច្ចការលំអិតស្តីពីការពិពណ៌នា និងការចុះបញ្ជីដីរដ្ឋចំណីសាធារណៈមិនទាន់មានការកំណត់ច្បាស់លាស់នៅឡើយ។

## ៤.៦ សកម្មភាពរបស់មន្ត្រីផ្សព្វផ្សាយចុះអនុវត្តជាក់ស្តែងនៅតាមភូមិ

### ៤.៦.១ ប្រមូលទិន្នន័យប្រវត្តដីភូមិ

នៅចុងបញ្ចប់នៃកិច្ចប្រជុំប្រកាសតំបន់វិនិច្ឆ័យក្រុមការងារផ្សព្វផ្សាយ និងរៀបចំដែនដី ត្រូវជួបជាមួយមេភូមិ និងអ្នកដឹកនាំភូមិផ្សេងទៀត ដើម្បីពិភាក្សាលំអិតអំពីផ្នែកប្រវត្តិដីភូមិ និងសកម្មភាពផ្សព្វផ្សាយ និងរៀបចំដែនដីផ្សេងៗក្នុងភូមិ។ ក្នុងកំឡុងពេលកិច្ចប្រជុំនេះមន្ត្រីផ្សព្វផ្សាយ និងរៀបចំដែនដី ត្រូវធ្វើដូចខាងក្រោមៈ

- ប្រាប់ប្រធានភូមិថាអ្នកណានឹងត្រូវពាក់ព័ន្ធក្នុងសកម្មភាពនីមួយៗនៃផ្នែកប្រវត្តិដីភូមិ និងវគ្គផ្សព្វផ្សាយព័ត៌មានដីធ្លីជាសាធារណៈ។
- ស្នើរមេភូមិ និងអ្នកដឹកនាំភូមិផ្សេងទៀត ក្នុងការរៀបចំប្រមូលអ្នកភូមិរបស់គាត់ សំរាប់សកម្មភាពនេះ។
- ពីពណ៌នាកម្មវិធី សំរាប់សកម្មភាពផ្សព្វផ្សាយ និងរៀបចំដែនដីក្នុងភូមិ ឧទាហរណ៍ តើសកម្មភាពនីមួយៗ មានរយៈពេលប៉ុន្មាន និងចាប់ផ្តើមនៅថ្ងៃណា?
- ស្នើមេភូមិឲ្យរៀបចំការពិភាក្សាសំរាប់ក្រុមគោលដៅ ដោយប្រមូលអ្នកចូលរួមដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលផ្តល់ដោយក្រុមមន្ត្រីផ្សព្វផ្សាយ និងមន្ត្រីរៀបចំដែនដី។

**សកម្មភាពពេលទៅដល់ភូមិៈ**

- ជួបជាមួយមេភូមិ និងអ្នកដឹកនាំភូមិដើម្បីពិនិត្យឡើងវិញ នូវគោលបំណងរបស់សកម្មភាពផ្សព្វផ្សាយ និងរៀបចំដែនដីក្នុងភូមិ កម្មវិធីសំរាប់គ្រប់សម្មភាព និងតួនាទីរបស់ចាស់ព្រឹទ្ធាចារ្យក្នុងដំណើរការនេះ
- រៀបចំកន្លែង ដែលធ្វើសកម្មភាពឲ្យបានសមរម្យ
- ដើម្បីជុំរុញភូមិ ដើម្បីធ្វើការកត់ត្រាចូលក្នុងរូបថតពីលើអាកាសដូចជា ស្រះទឹក វត្ត សាលារៀន ព្រំប្រទល់ភូមិ ដីចំណីសាធារណៈ និងកន្លែងផ្សេងៗនៅក្នុងភូមិ
- មន្ត្រីផ្សព្វផ្សាយ ត្រូវពិនិត្យឡើងវិញនៅកិច្ចការដែលបានធ្វើរួច

### ៤.៦.២ កិច្ចសំភាសន៍ជាមួយមេភូមិ

មុនចាប់ផ្តើមសំភាសន៍មន្ត្រីផ្សព្វផ្សាយត្រូវពន្យល់អំពីគោលបំណងនៃកិច្ចសំភាសន៍ ដោយសាកសួរសំនួរទៅតាមកំរងសំណួរសំរាប់មេភូមិ ដោយកត់ត្រា និងបំពេញចំលើយតាមចន្លោះនៃសំនួរ។

នៅក្នុងកិច្ចសំភាសន៍ជាមួយមេភូមិ មន្ត្រីផ្សព្វផ្សាយបានស្នើឲ្យមេភូមិផ្តល់ព័ត៌មានអំពីស្ថានភាពដីធ្លីនៅក្នុងភូមិ ចំនួនប្រជាជនសរុបនៅក្នុងភូមិ ស្ថានភាពនៃម្ចាស់ទ្រព្យ (ចំនួនគ្រួសារដែលលែងលះ ឬបាក់បែក) ចំនួន

ក្បាលដីទាំងអស់នៅក្នុងភូមិ ស្ថានភាពនៃច្បាប់ (ក្បាលដីដែលមានប័ណ្ណរួច) ក្បាលដីដែលកាន់កាប់ដោយអ្នករស់នៅក្រៅភូមិ ចំនួនគ្រួសារដែលគ្មានដី ចំនួនគ្រួសារដែលកាន់កាប់ដីធំ ទីផ្សារដី ដីឌែលមានទំនាស់ និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងភូមិ ដោយឲ្យគាត់ធ្វើការចង្អុលបង្ហាញក្បាលដីទាំងនោះនៅលើរូបថតពីលើអាកាសដោយខ្លួនឯង ដោយពន្យល់គាត់ឲ្យយល់អំពីទីតាំងដី(ដាក់រូបថតឲ្យត្រូវទិស)។ ដូច្នេះគាត់អាចកំណត់បាននូវរាល់ក្បាលដី ឬតំបន់ដែលត្រូវប្រើប្រាស់ផ្សេងទៀតបានត្រឹមត្រូវ។ ធ្វើបែបនេះគឺអាចកំណត់បាននូវរាល់ក្បាលដីដែលមានទំហំធំ ឬដីដែលមានបញ្ហា និងក្បាលដីដែលជាសម្បត្តិសាធារណៈ ធ្វើបែបនេះគឺវាបង្កភាពងាយស្រួលដល់ក្រុមការងារក្នុងការរៀបចំដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធប្រព្រឹត្តទៅបានល្អប្រសើរ។

## ៤.៧ ការជួបពិភាក្សាជាមួយក្រុមគោលដៅ

នៅក្នុងកិច្ចប្រជុំពិភាក្សាជាមួយក្រុមគោលដៅគឺមានបុរស ៦ ទៅ ៨នាក់ ឬស្ត្រី ៦ ទៅ ៨នាក់ ត្រូវបានស្នើឲ្យពិភាក្សាលើបញ្ហាដែលទាក់ទងទៅនឹងការកាន់កាប់ប្រើប្រាស់ដីធ្លី ដោយមានការសួរបញ្ជាក់ដេញដោលពីព័ត៌មានដែលទទួលបានពីលោកមេភូមិនៅលើរូបថតពីលើអាកាស ដោយអនុញ្ញាតឲ្យពួកគាត់ចូលរួមផ្តល់គំនិតនៅលើតំបន់របស់ពួកគាត់ ហើយមន្ត្រីផ្សព្វផ្សាយស្វែងយល់អំពីចំណេះដឹងរបស់ពួកគាត់ និងស្វែងយល់អំពីបញ្ហាដែលទាក់ទងទៅនឹងដីធ្លីជាដើម។

ក្រុមគោលដៅ គឺជាក្រុមដែលមានមនុស្សវ័យចំណាស់១រូប ស្រីមេម៉ាយ ឬ បុរសពោះម៉ាយ ១រូប អ្នកដែលគ្មានដី និងអ្នកដែឡមានជំលោះដីធ្លី ដោយមេភូមិជាអ្នកជ្រើរើសដោយផ្ទាល់ពីព្រោះគាត់អាចក្តាប់បានចំពោះប្រជាពលរដ្ឋទាំងអស់នោះ ដើម្បីធ្វើការផ្សព្វផ្សាយដល់ពួកគាត់ឲ្យបានយល់ដឹងអំពី សិទ្ធិ កាតព្វកិច្ច បែបបទនៃការចុះបញ្ជីដីធ្លីផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ និងអំពីផែនទីភូមិ ដែលធ្វើឲ្យពួកគាត់យល់បាន ហើយជួយធ្វើការផ្សព្វផ្សាយបន្ត និងមិនធ្វើឲ្យដំណើការចុះបញ្ជីដីមានការយឺតយ៉ាវក្នុងការជួបពិភាក្សាជាមួយក្រុមគោលដៅបុរស និងស្ត្រី គឺធ្វើឡើងដាច់ដោយឡែកពីគ្នា ដោយគ្មានវត្តមានរបស់អាជ្ញាធរដែនដីចូលរួមជាមួយឡើយ ក្នុងគោលបំណងធានាបាននូវការហ៊ានបញ្ចេញមតិ និងឡើងនូវបញ្ហា ឬសំណួរផ្សេងៗទៀត ដែលពាក់ពន្ធ័នឹងបញ្ហាដីធ្លីដោយគ្មានការខ្មាសអៀន និងខ្លាចញញើត។

នៅក្នុងតំបន់ធ្វើការសិក្សាស្រាវជ្រាវ ផ្អែកទៅលើស្ថានភាពជាក់ស្តែងមន្ត្រីផ្សព្វផ្សាយដល់ប្រជាបលរដ្ឋ ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅដោយប្រើឧគ្សោសនសព្ទ័ និងមានផ្ទាំងរូបភាពដែលទាក់ទងនឹងកាផ្សព្វផ្សាយនិយាយពីដំណាក់កាលនីមួយៗជាជំនួយដើម្បីឲ្យប្រជាពលរដ្ឋបានដឹងលឺគ្រប់គ្នាពីនីតិវិធីនៃដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ គឺធ្វើយ៉ាងណាឲ្យអ្នកភូមិទាំអស់មានឧត្តឱកាសអាចយល់ដឹងអំពីសិទ្ធិរបស់ពួកគាត់នឹងរំពឹងទុកថាគាត់ត្រូវធ្វើអ្វីខ្លះនៅពេលដំណើរការចុះបញ្ជិដីធ្លីមកដល់ពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ។

## ៤.៨ ការផ្សព្វផ្សាយជាមួយក្រុមបុរស និងស្ត្រី

នៅក្នុងតំបន់ធ្វើការសិក្សាស្រាវជ្រាវ ផ្អែកទៅលើស្ថានភាពជាក់ស្តែងក្នុងពេលផ្សព្វផ្សាយពីច្បាប់ នីតិវិធីនៃការចុះបញ្ជីដី ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ និងផែនទីភូមិ មន្ត្រីផ្សព្វផ្សាយបានធ្វើការជួបជុំដាច់ដោយឡែកពីគ្នារវាងក្រុមបុរស និងក្រុមស្ត្រីដែលមានពីអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ ហើយក្នុងនោះមានចំនួនស្ត្រីដែលបានចូលរួម មានច្រើនជាងចំនួនបុរសដែលបានចូលរួម។ នៅក្នុងពេលជួបប្រជុំផ្សព្វផ្សាយ មន្ត្រីផ្សព្វផ្សាយត្រូវប្រើផ្ទាំងរូបភាព

ជាជំនួយ ដើម្បីពន្យល់បង្ហាញអំពីដំណាក់កាលនីមួយៗនៃការចុះបញ្ជីមានលក្ខណៈជាប្រពន្ធ័ នឹងអំពីសិទ្ធី កាតព្វកិច្ចរបស់ពួកគាត់ដែលត្រូវជួយដល់មន្ត្រីក្នុងការកំណត់ព្រំ និងវាស់វែងដី។ នៅក្នុងនោះដែលក៏មានការ បង្ហាញ អំពីផែនទីភូមិដើម្បីឲ្យមានការពិចារណា និងពិភាក្សាគ្នាក្នុងការរៀបចំភូមិដ្ឋានក្នុងការកំណត់ទុកនូវ ដីចំណី ផ្លូវសាធារណៈ និងដីបំរុងរបស់ភូមិសំរាប់គោលដៅអភិវឌ្ឍន៍។ ក្នុងការផ្សព្វផ្សាយនេះគឺទុកពេលវេលាសំរាប់ការ ពិភាក្សា លើកឡើងអំពីផលប្រយោជន៍ នៃ
ប័ណ្ណកម្មសិទ្ធិ និងការផ្លាស់ប្តូរ ផ្ទេរសិទ្ធិនាពេលខាងមុខផងដែរ ដើម្បីឲ្យប្រជាពលរដ្ឋបានយល់ថា នៅពេលដែលធ្វើ ការផ្ទេរសិទ្ធិ គឺត្រូវធ្វើការចុះបញ្ជិដីនៅការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកដែល ក្បាលដីស្ថិតនៅ។

## ៤.៩ ការផ្សព្វផ្សាយជាមួយក្រុមពិសេស

នៅក្នុងការជួបជាមួយក្រុមពិសេសនេះ វាមានសារៈសំខាន់ខ្លាំងណាស់ ដោយមន្ត្រីចាំបាច់ត្រូវធ្វើការ ផ្សព្វផ្សាយនៅតាមផ្ទះរបស់ពួកគាត់ផ្ទាល់តែម្តងដូចជាបុរសពោះម៉ាយ ជនពិការ គ្រួសារក្រីក្រ និងជនដែលមិនចេះ អក្សរពីព្រោះអ្នកទាំងអស់នោះជួបការលំបាកក្នុងជីវភាពរស់នៅ ដើម្បីចិញ្ចឹមជីវិត និងគ្រួសារ។ ការផ្សព្វផ្សាយ នោះ ត្រូវធ្វើឡើងពិច្បាប់ភូមិបាល សិទ្ធិ និងនីតិវិធីនៃការចុះបញ្ជីដីធ្លី ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ ដើម្បីឲ្យពួក គាត់បានយល់ច្បាស់ និងទុកពេលវេលាឲ្យពួកគាត់សួរនូវបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងទ្រព្យរបស់ពួកគាត់។

## ៤.១០ ដំណើរការនៃការផ្សព្វផ្សាយ

ការចាប់ផ្តើមការផ្សព្វផ្សាយព័ត៌មានត្រូវបានចាប់ផ្តើមដោយការផ្សព្វផ្សាយសេចក្តីជូនដំណឹងប្រកាសតំបន់ វិនិច្ឆ័យ ដោយមានការចូលរួមពីម្ចាស់ដី/អ្នកកាន់កាប់ដីធ្លី មេភូមិ មន្ត្រីជំនាញ ដើម្បីធ្វើជាការជូនដំណឹងពីការចុះ បញ្ជីក្នុងតំបន់ទៅដល់ពួកគាត់ ហើយក៏មានផ្សព្វផ្សាយនូវព័ត៌មានពីការចុះបញ្ជីដីធ្លីកាន់តែច្បាស់នៅពេលដែលមាន ផ្សព្វផ្សាយព័ត៌មានទៅដល់ប្រជាជនក្នុងតំបន់វិនិច្ឆ័យតែម្តង ដោយមានការពន្យល់ណែនាំពីច្បាប់ដែលពាក់ព័ន្ធនឹង ការចុះបញ្ជី ដែលមានចែងពីសិទ្ធិលើដីធ្លីដែលបុគ្គលជាម្ចាស់ ឬអ្នកប្រើប្រាស់ត្រូវមានទៅដីធ្លីនោះ គឺជាច្បាប់ ភូមិបាល នីតិវិធីចុះបញ្ជីដីធ្លី ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ និងការចុះបញ្ជីបន្តនៅពេលខាងមុខជាដើម។

ការផ្សព្វផ្សាយព័ត៌មាន មាននៅក្នុងដំណាក់កាលនៃដំណោះរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បន្ថែម ពីលើការផ្សព្វផ្សាយជាទូទៅនៅដំណាក់កាលទីមួយ (ដំណាក់កាលរៀបចំ មានការប្រជុំផ្សព្វផ្សាយជាសាធារណៈ និង PACP) គឺមាននៅក្នុងដំណាក់កាលទីពីរ (ដំណាក់កាលបច្ចេកទេស) ដំណាក់កាលទីបី (ដំណាក់បិទផ្សាយជា សាធារណៈឯកសារនៃការវិនិច្ឆ័យ) និងដំណាក់កាលចុងក្រោយ (ដំណាក់កាលចែកប័ណ្ណ)។ នៅក្នុងដំណាក់កាល នីមួយៗ មានគោលបំណង នៃការផ្សព្វផ្សាយខុសៗ ដែលការផ្សព្ពផ្សាយនៅដំណាក់កាលទីពីរ គឺពេលវេលា សម្រាប់ការកំណត់ព្រំ វាស់វែង និងវិនិច្ឆ័យ ហើយពេលផ្សព្វផ្សាយដែលនៅមានក្នុងដំណាក់កាលទីបី គឺផ្តោតទៅ លើការផ្សព្វផ្សាយ ដើម្បីឲ្យម្ចាស់ដីចូលរួមពិនិត្យនូវព័ត៌មានដែលខ្លួនបានផ្តល់ទៅមន្ត្រីក្នុងដំណាក់កាលទីពីរ និង ចុងក្រោយក្នុងដំណាក់កាលចែកប័ណ្ណ គឺផ្តោតទៅលើការប្រើប្រាស់ និងថែរក្សាប័ណ្ណកម្មសិទ្ធិដែលទើបនឹងទទួល បាននេះ រួមជាការចុះបញ្ជីបន្តនៅពេលខាងមុខ បើក្បាលដីមានកែប្រែសិទ្ធិ និងតម្រង់របស់ក្បាលដី។

ដើម្បីឲ្យមានការចូលរួមពីម្ចាស់ដី និងអ្នកពាក់ព័ន្ធទៅក្នុងដំណាក់កាលបច្ចេកទេសឲ្យបានកាន់តែច្រើន និងមានភាពរលូន ក៏ដូចជាដំណាក់កាលផ្សេងទៀតនោះ អាចនឹងមានការផ្សព្វផ្សាយពិសេសមួយដែលបានត្រូវឡើងតាមក្រុមតូចៗ ដែលមានគ្នាពី៦ ទៅ៨នាក់ ឬក៏ចូលទៅផ្សព្វផ្សាយតាមផ្ទះប្រជាជនតែម្តង ដើម្បីពន្យល់ បកស្រាយឲ្យបានច្បាស់ពីដំណើរការចុះបញ្ជីដីធ្លី និងជំរុញឲ្យពួកគាត់ចូលរួមក្នុងដំណើរការចុះបញ្ជីដំបូង និងការចុះបញ្ជីបន្តនោះគឺ ការផ្សព្វផ្សាយនេះធ្វើឡើងតាមរយៈដំណើរការ PACP។

ចំពោះតំបន់ដែលបានយកមកសិក្សា ការផ្សព្វផ្សាយបានដោយមធ្យោបាយមួយចំនួនដូចជា ការប្រើឧគ្ឃោសនស័ព្ទ និងផ្ទាំងរូបភាពដែលទាក់ទងនឹងការផ្សព្វផ្សាយនិយាយពីដំណាក់កាលនីមួយៗ ដែលមានក្នុងដំណើរការចុះបញ្ជីជាជំនួយ តាមរយៈសេចក្តីប្រកាសរបស់អាជ្ញាធរវិទ្យុ និងទូរទស្សន៍ ដើម្បីធ្វើការផ្សព្វផ្សាយ។

ចំណុចខាងលើនេះជាការផ្សព្វផ្សាយ ដែលកើតមានក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដែលស្របពេលដែលការផ្សព្វផ្សាយក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំមាន តែការផ្សព្វផ្សាយនៅមុនពេលដែលមានការកំណត់ព្រំ និងវាស់វែងក្បាលដីដែលបានស្នើសុំចុះ(ករណីនេះកំណត់ព្រំ និងវាស់វែងមានចំពោះក្បាលដីដែលនៅក្រៅតំបន់វិនិច្ឆ័យ។

តារាងទី ៤ សង្ខេបពីការផ្សព្វផ្សាយជាទូទៅក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

| ការចុះមញ្ជីដីមានលក្ខណៈជាប្រព័ន្ធ | | | | |
|---|---|---|---|---|
| ព័ត៌មានត្រូវផ្សព្វផ្សាយ | អ្នកទទួលព័ត៌មាន | មធ្យោបាយសម្រាប់ការផ្សព្វផ្សាយ | ពេលវេលាផ្សព្វផ្សាយ | ទីកន្លែងផ្សព្វផ្សាយ |
| -ច្បាប់ភូមិបាល<br>-ដំណើរការ និងផលប្រយោជន៍ នៃចុះបញ្ជីដីធ្លី | -អាជ្ញាធរមូលដ្ឋាន<br>-គណៈកម្មការរដ្ឋបាល<br>-ប្រជាពលរដ្ឋម្ចាស់ដី និងអ្នកពាក់ព័ន្ធ | -ពន្យល់ដោយមន្ត្រី<br>-ផ្ទាំងរូបភាព<br>-វិទ្យុ និងទូរទស្សន៍<br>-សេចក្តីជូនដំណឹង | -ពេលប្រកាសតំបន់វិនិច្ឆ័យ<br>-ពេលធ្វើកិច្ចប្រជុំជាសាធារណៈ | ទីតាំងកន្លែងសមស្របក្នុងតំបន់វិនិច្ឆ័យ |
| ដំណាក់កាលទី ១<br>-ដំណើរការចុះបញ្ជី<br>-សិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់ និងអ្នកពាក់ព័ន្ធ<br>-ផលប្រយោជន៍ | -ប្រជាពលរដ្ឋម្ចាស់ដី និងអ្នកពាក់ព័ន្ធ | -ពន្យល់ដោយមន្ត្រី<br>-ផ្ទាំងរូបភាព<br>-វិទ្យុ និងទូរទស្សន៍<br>-សេចក្តីជូនដំណឹង | -ពេលចាប់ផ្តើមដំណាក់កាលទី១ | -ទីតាំងកន្លែងសមស្របក្នុងតំបន់វិនិច្ឆ័យ |
| ដំណាក់កាលទី ២<br>-ពេលវេលា ដែលមន្ត្រីមកធ្វើការវាស់វែងកំណត់ព្រំ និងវិនិច្ឆ័យ | | -សេចក្តីជូនដំណឹង<br>-ពន្យល់ដោយមន្ត្រី<br>-វិទ្យុ និងទូរទស្សន៍<br>-សេចក្តីជូនដំណឹង | -មុនពេលចាប់ផ្តើមដំណាក់កាលទី២ | -ទីតាំងវាស់វែងកំណត់ព្រំ និងវិនិច្ឆ័យ |
| ដំណាក់កាលទី ៣<br>-ចូលរួមពិនិត្យមើលទិន្នន័យដែលបានបិទផ្សាយថាត្រឹមត្រូវឬទេ | -ប្រជាពលរដ្ឋម្ចាស់ដី និងអ្នកពាក់ព័ន្ធ | -សេចក្តីជូនដំណឹង<br>-ពន្យល់ដោយមន្ត្រី<br>-វិទ្យុ និងទូរទស្សន៍<br>-សេចក្តីជូនដំណឹង | -ពេលចាប់ផ្តើមដំណាក់កាលទី៣ | -ទីតាំងបិទផ្សាយ |

| | | | | |
|---|---|---|---|---|
| ដំណាក់កាលទី ៥<br>-ទទួលយកប័ណ្ណ<br>-ការថែរក្សា<br>-ការចុះបញ្ជីបន្ត | | | -ពេលចាប់ផ្តើម ដំណាក់កាលទី៥ | -ទីតាំងចែកប័ណ្ណ |

ប្រភព: ទិន្នន័យអង្កេត

តារាងទី ៥ សង្ខេបពីការផ្សព្វផ្សាយតាមរយៈ PACP

| ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ (PACP) | | | | |
|---|---|---|---|---|
| ព័ត៌មានត្រូវផ្សព្វផ្សាយ | អ្នកទទួលព័ត៌មាន | មធ្យោបាយសម្រាប់ការផ្សព្វផ្សាយ | ពេលវេលាផ្សព្វផ្សាយ | ទីកន្លែងផ្សព្វផ្សាយ |
| -ច្បាប់ភូមិបាល<br>-ដំណើរការ និងផលប្រយោជន៍ នៃចុះបញ្ជីដីធ្លី | -ប្រជាពលរដ្ឋម្ចាស់ដី និងអ្នកពាក់ព័ន្ធ<br>-ធ្វើតាមក្រុមគោលដៅ | -ពន្យល់ដោយមន្ត្រី<br>-ផ្ទាំងរូបភាព | -ក្រោយពេលធ្វើកិច្ចប្រជុំជាសាធារណៈ | ទីតាំងកន្លែងសមស្របក្នុងតំបន់វិនិច្ឆ័យ ឬផ្ទះប្រជាពលរដ្ឋ |

ប្រភព: ទិន្នន័យអង្កេត

តារាង ៦ សង្ខេបពីការផ្សព្វផ្សាយក្នុងដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ

| ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ | | | | |
|---|---|---|---|---|
| ព័ត៌មានត្រូវផ្សព្វផ្សាយ | អ្នកទទួលព័ត៌មាន | មធ្យោបាយសម្រាប់ការផ្សព្វផ្សាយ | ពេលវេលាផ្សព្វផ្សាយ | ទីកន្លែងផ្សព្វផ្សាយ |
| -ដំណាក់កាលវាស់វែង កំណត់ព្រំ និងវិនិច្ឆ័យ | -ប្រជាពលរដ្ឋម្ចាស់ដី និងអ្នកពាក់ព័ន្ធ | -សេចក្តីជូនដំណឹង | -មុនពេលធ្វើការវាស់វែង កំណត់ព្រំនិងវិនិច្ឆ័យ | -ទីតាំងវាស់វែង កំណត់ព្រំ និងវិនិច្ឆ័យ |
| -ដំណាក់កាលបិទផ្សាយជាសាធារណៈឯកសារនៃការវិនិច្ឆ័យ | | -សេចក្តីជូនដំណឹង | -មុនពេលបិទផ្សាយឯកសារ | -ទីតាំងកន្លែងបិទផ្សាយ |

ប្រភព: ទិន្នន័យអង្កេត

## ៤.១១ ព័ត៌មានទូទៅរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់គោកចក

### ៤.១១.១ ចំនួនអ្នកផ្តល់បទសម្ភាសន៍

យោងតាមការសិក្សាស្រាវជ្រាវ ខ្ញុំបានធ្វើការជួបសំភាសន៏ផ្ទាល់ជាមួយប្រជាពលរដ្ឋទាំងពីរភូមិ គឺនៅក្នុងភូមិទក្សិណខាងត្បូង និងភូមិត្រពាំងសេះ ក្នុងសង្កាត់គោកចក ក្នុងនោះចំនួនអ្នកផ្តល់បទសំភាសន៏ជាមនុស្សប្រុសមានចំនួន ១៥ នាក់ ស្មើនឹង ២៦ ភាគរយ ហើយចំនួនអ្នកផ្តល់បទសំភាសន៏ជាមនុស្សស្រីមាន ៤៣ នាក់ ស្មើនឹង ៧៤ ភាគរយ នៃចំនួនសំណាកសរុបទាំងអស់ ៥៨ នាក់។

ដ្យាក្រាមទី ១ ៖ ភាគរយនៃការផ្តល់បទសំភាសន៍




ប្រភព ៖ ទិន្នន័យវិភាគ

តារាងទី ៧ ភាគរយនៃការផ្តល់បទសំភាសន៍

| ល.រ | ការផ្តល់បទសំភាសន៍ | ចំនួនគ្រួសារ | ភាគរយនៃការផ្តល់បទសំភាសន៍ |
|---|---|---|---|
| ១ | ស្ត្រី | ៤៣ | ៧៤ |
| ២ | បុរស | ១៥ | ២៦ |
| សរុប | | ៥៨ | ១០០ |

ប្រភព ៖ ទិន្នន័យវិភាគ

**៤.១១.២ ស្ថានភាពនៅក្នុងគ្រួសាររបស់ប្រជាពលរដ្ឋ**

ការផ្តល់បទសម្ភាសន៍ជាក់ស្តែងនៅក្នុងតំបន់ ដែលបានធ្វើការសិក្សាស្រាវជ្រាវភាគច្រើនអ្នកដែលបានផ្តល់បទសំភាសន៍ គឺជាអ្នកដែលបានរៀបការរួចដោយពួកគាត់បានចូលរួមច្រើនក្នុងការចូលរួមចុះបញ្ជីដីធ្លី ដែលមានលក្ខណៈជាប្រព័ន្ធ ពីព្រោះប្រជាពលរដ្ឋគិតថាអ្នកដែលបានរៀបការរួចច្រើនតែមានការយល់ដឹងច្រើន ទាំងការចាប់យកចំណេះដឹងថ្មីពីមន្ត្រីផ្សព្វផ្សាយជាដើម។

**៤.១១.៣ កំរិតវប្បធម៌របស់ប្រជាពលរដ្ឋ**

តាមរយៈការសិក្សាបានអោយយល់ឃើញថាមានប្រជាជនចេះអានបានច្រើន។ ក្នុងចំណោមប្រជាពលរដ្ឋ ៥៨ គ្រួសារមាន ២០ គ្រួសារស្មើនឹង ៣៤ ភាគរយនៃចំនួនសំណាកសរុបដែលបានរៀនត្រឹមបឋមសិក្សា ហើយក្នុងនោះដែរមាន ១១ គ្រួសារ ស្មើនឹង ២០ ភាគរយដែលបានរៀនត្រឹមអនុវិទ្យាល័យ ហើយមាន ១០ គ្រួសារស្មើនឹង ១៧ ភាគរយ ដែលបានរៀនត្រឹមវិទ្យាល័យ និងមានប្រជាពលរដ្ឋរៀនដល់មហាវិទ្យាល័យចំនួន ១៧ គ្រួសារស្មើនឹង ២៩ ភាគរយនៃចំនួនសំណាកសរុប។

កំរិតវប្បធម៌របស់ប្រជាពលរដ្ឋនៅក្នុងតំបន់សិក្សា យើងអាចវាយតំលៃបានថានៅមានកំរិតល្អច្រើនជាងមុន បើប្រៀបធៀបទៅនឹងជំនាន់មុន ដូចនេះហើយការផ្សព្វផ្សាយមានសភាពទូលំទូលាយ ប្រជាពលរដ្ឋភាគច្រើនយល់ដឹងពីដំណើរការចុះបញ្ជីដីធ្លី។

តារាងទី ៨ ភាគរយនៃកម្រិតវប្បធម៌របស់ប្រជាពលរដ្ឋ

| ល.រ | កម្រិតវប្បធម៌ | ចំនួនគ្រួសារ | ភាគរយនៃកម្រិតវប្បធម៌ |
|---|---|---|---|
| ១ | បឋមសិក្សា | ២០ | ៣៤ |
| ២ | អនុវិទ្យាល័យ | ១១ | ២០ |
| ៣ | វិទ្យាល័យ | ១០ | ១៧ |
| ៤ | មហាវិទ្យាល័យ | ១៧ | ២៩ |
| សរុប | | ៥៨ | ១០០ |

ប្រភព ៖ ទិន្នន័យវិភាគ

ដ្យាក្រាមទី ២ ៖ ភាគរយនៃកម្រិតវប្បធម៌របស់ប្រជាពលរដ្ឋ




ប្រភពទិន្នន័យ ៖ ទិន្នន័យវិភាគ

### ៤.១១.៤ ប្រភពព័ត៌មាននៃការចុះបញ្ជីដីធ្លី

នៅក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ មុននឹងចាប់ផ្តើមធ្វើការចុះបញ្ជីនៅក្នុងតំបន់វិនិច្ឆ័យណាមួយនោះ ជាតំបូងត្រូវមានការផ្សព្វផ្សាយជាសាធារណៈ ជូនសល់ប្រជាពលរដ្ឋអំពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធជាមុនសិន គឺធ្វើឡើងដើម្បីអោយប្រជាពលរដ្ឋមានការយល់ដឹង និងមកចូលរួមដោយស្ម័គ្រចិត្ត និងបាន

ត្រៀមរៀបចំទុកជាមុននៅរាល់ឯកសារដែលចាំបាច់មួយចំនួនសំរាប់ផ្តល់ជូនដល់មន្ត្រី កំណត់ព្រំដី វាស់វែង ឮ វិនិច្ឆ័យ ដើម្បីធ្វើការកំនត់នូវសិទ្ធិដែលមាននៅលើដី (អត្តសញ្ញាណម្ចាស់ដី និងអត្តសញ្ញាណនៃក្បាលដី)។

តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ប្រភពព័ត៌មានទទួលបានពីប្រជាពលរដ្ឋទាំងអស់ ៥៨ គ្រួសារ ក្នុងចំនោមនោះមានចំនួន ២២ គ្រួសារ ស្មើនឹង ៣៨ ភាគរយ ទទួលបានពីប្រជាពលរដ្ឋដែលបានមកចូលរួមប្រជុំក្នុងភូមិជាមួយមន្ត្រីផ្សព្វផ្សាយ ចំណែក ៣០ គ្រួសារ ស្មើនឹង ៥២ ភាគរយ ទទួលបានពីមន្ត្រីផ្សព្វផ្សាយដែលបានផ្តល់ព័ត៌មានស្តីអំពីការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្នុងភូមិ ហើយចំនួន ៦ គ្រួសារ ទៀតស្មើនឹង ១០ ភាគរយ បានដឹងព័ត៌មានតាមរយៈមេភូមិ ឬចៅសង្កាត់។ ដូចនេះប្រជាពលរដ្ឋមួយចំនួនធំបានយល់ដឹង និងបានចូលរួមសហការអំពីដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនេះ។

តារាងទី ៩ ប្រភពព័ត៌មានស្តីពីការចុះបញ្ជីដីធ្លី

| ល.រ | ព័ត៌មានស្តីពីការចុះបញ្ជីដីធ្លី | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | ចូលរួមប្រជុំក្នុងភូមិ | ៣០ | ៥២ |
| ២ | អ្នកជិតខាង | ២២ | ៣៨ |
| ៣ | មេភូមិ ឬចៅសង្កាត់ | ៦ | ១០ |
| សរុប | | ៥៨ | ១០០ |

ប្រភព៖ ទិន្នន័យវិភាគ

ដ្យាក្រាមទី៣ ៖ ភាគរយនៃប្រភពព័ត៌មានស្តីពីការចុះបញ្ជីដីធ្លី




ប្រភព ៖ ទិន្នន័យវិភាគ

### ៤.១១.៥ ការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះការផ្សព្វផ្សាយ

ក្រោយពីការផ្សព្វផ្សាយបានចប់ទៅ តាមការជួបសម្ភាសន៍បានបង្ហាញអោយឃើញថាមានប្រជាពលរដ្ឋចំនួន ៥៥ គ្រួសារ ស្មើនឹង ៩៥ ភាគរយពេញនឹងការផ្សព្វផ្សាយ ព្រមទាំងយល់ដឹងច្រើនអំពីនីតិវិធីដែលទាក់ទង់ទៅដំណើរការចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ រីឯ ៣ គ្រួសារផ្សេងទៀត ស្មើនឹង ៥ ភាគរយដែលមិនពេញចិត្តនឹងការផ្សព្វផ្សាយ ពីព្រោះចំនេះដឹងរបស់ពួកគាត់នៅមានកម្រិត ជាហេតុធ្វើអោយក្តាប់មិនបានព័ត៌មានដែលទាក់ទងទៅនឹងនីតិវិធីនៃដំណើរការចុះបញ្ជីដីធ្លីនេះ។

តារាងទី ១០ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះការផ្សព្វផ្សាយ

| ល.រ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | ពេញចិត្ត | ៥៥ | ៩៥ |
| ២ | មិនពេញចិត្ត | ៣ | ៥ |
| | សរុប | ៥៨ | ១០០ |

ប្រភព ៖ ទិន្នន័យវិភាគ

ដ្យាក្រាមទី ៤ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះការផ្សព្វផ្សាយ




ប្រភព ៖ ទិន្នន័យវិភាគ

### ៤.១១.៦ ការយល់ដឹងរបស់ប្រជាពលរដ្ឋ ក្នុងដំណាក់កាលត្រៀមរៀបចំ

នៅក្នុងដំណាក់កាលត្រៀមរៀបចំ ប្រជាពលរដ្ឋត្រូវត្រៀមនូវឯកសារ ដែលចាំបាច់មួយចំនួនសំរាប់ផ្តល់ជូន ដល់មន្ត្រីកំណត់ព្រំ វាស់វែង និងវិនិច្ឆ័យ ដើម្បីផ្ទៀងផ្ទាត់នូវរាល់ទិន្នន័យដែលពាក់ព័ន្ធទៅនឹងក្បាលដីរបស់ខ្លួន។ ហើយម្យ៉ាងវិញទៀតក្នុងដំណាក់កាលនេះប្រជាពលរដ្ឋត្រូវចូលរួម និងតាមដានស្តាប់អោយបានយល់ពីព័ត៌មានទាំងឡាយដែលមន្ត្រីផ្សព្វផ្សាយបានប្រកាស និងត្រូវត្រៀមរៀបចំឯកសារព្រមទាំងការដាំបង្គោលព្រំដីរឹងមាំនៅលើក្បាលដីរបស់ខ្លួនដោយមានការយល់ព្រម និងឯកភាពគ្នាជាមួយនឹងអ្នកជាប់ព្រំ ក្នុងនោះមានប្រជាពលរដ្ឋ ៥៦ គ្រួសារ ដែលស្មើនឹង ៩៧ ភាគរយ បានចូលរួមប្រជុំជាមួយមន្ត្រីផ្សព្វផ្សាយ និងបានយល់ដឹងចំពោះដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ ចំណែកឯ ២ គ្រួសារដែលស្មើនឹង ៣ ភាគរយបានចូលរួមនៅក្នុងការប្រជុំផ្សព្វផ្សាយដែរ ប៉ុន្តែដោយសារពួកគាត់មិនសូវយល់អំពីការប្រជុំផ្សព្វផ្សាយនេះ ទើបធ្វើអោយពួកគាត់មិនបានត្រៀមរៀបចំទុកជាមុន។

ដ្យាក្រាមទី ៥ ភាគរយនៃការយល់ដឹងររបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលរៀបចំ




ប្រភព ៖ ទិន្នន័យ

តារាងទី ១១ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ក្នុងដំណាក់កាលត្រៀមរៀបចំ

| ល.រ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | យល់ | ៥៦ | ៩៧ |
| ២ | មិនយល់ | ២ | ៣ |
| | សរុប | ៥៨ | ១០០ |

ប្រភព: ទិន្នន័យវិភាគ

### ៤.១១.៧ ការយល់ដឹងរបស់ប្រជាពលរដ្ឋ ក្នុងដំណាក់កាលបច្ចេកទេស

ដំណាក់កាលបច្ចេកទេស ជាដំណាក់កាលដែលត្រូវធ្វើការអនុវត្តនូវការកំណត់ព្រំ វាស់វែង និងវិនិច្ឆ័យដែលតម្រូវអោយប្រជាពលរដ្ឋ ដែលជាម្ចាស់ត្រូវដាំបង្គោលនៅលើក្បាលដីរបស់ខ្លួនអោយបានត្រឹមត្រូវ ផ្តល់នូវឯកសារដែលពាក់ព័ន្ធមួយចំនួនសំរាប់ធ្វើការវិនិច្ឆ័យ (អត្តសញ្ញាណម្ចាស់ដី និងអត្តសញ្ញាណក្បាលដី) ដើម្បីងាយស្រួលក្នុងការអនុវត្តនៃការចុះបញ្ជី។ ការកំណត់ព្រំ គឺជាដំណើរការមួយដែលប្រជាពលរដ្ឋត្រូវតែចូលរួមជាមួយមន្ត្រីកំណត់ព្រំ ក្នុងការចង្អុលបង្ហាញព្រំដីរបស់ខ្លួន ដើម្បីអោយមន្ត្រីវាស់វែងធ្វើការវាស់វែងតាមបង្គោលព្រំដីដែលបានដាំរួច និងមានការព្រមព្រៀងគ្នាពីអ្នកជាប់ព្រំ។ ក្នុងចំនោម ៥៨ គ្រួសារ នៃសំណាកសរុបដែលបានធ្វើការសម្ភាសន៍ ក្នុងនោះ ៥៥ គ្រួសារ ដែល ស្មើនឹង ៩៥ ភាគរយដែលបានយល់ដឹង និងចូលរួមជាមួយមន្ត្រីកំណត់ព្រំ វាស់វែង វិនិច្ឆ័យ និងធ្វើការដាំបង្គោលព្រំដីដែលមានការព្រមព្រៀងគ្នាជាមួយអ្នកជាប់ព្រំ។ ចំណែក ៣ គ្រួសារដែលស្មើនឹង ៥ ភាគរយទៀតបានចូលរួមនៅក្នុងដំណើរការកំណត់ព្រំ វាស់វែង និងវិនិច្ឆ័យជាមួយមន្ត្រីដែរ ប៉ុន្តែពួកគាត់មិនបានធ្វើការដាំបង្គោលព្រំលើដីរបស់ខ្លួនទេ។

ដ្យាក្រាមទី ៦ ភាគរយការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើការដំណាក់កាលបច្ចេសទេស




ប្រភព៖ ទិន្នន័យវិភាគ

តារាងទី ១២ ភាគរយការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើការដំណាក់កាលបច្ចេសទេស

| ល.រ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | យល់ | ៥៥ | ៩៥ |
| ២ | មិនយល់ | ៣ | ៥ |
| | សរុប | ៥៨ | ១០០ |

ប្រភពៈ ទិន្នន័យវិភាគ

### ៤.១១.៨ ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលបិទផ្សាយឯកសារនៃការវិនិច្ឆ័យ

នៅក្នុងដំណាក់កាលបិទផ្សាយជាសារធារណៈនូវឯកសារនៃការវិនិច្ឆ័យ គឺជាដំណាក់កាលទីបីនៃការចុះបញ្ជីដីហើយដំណាក់កាលនេះវាមានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រជាពលរដ្ឋដែលជាម្ចាស់ដី ត្រូវចូលរួមពិនិត្យមើលជាចាំបាច់នូវឯកសារនៃការវិនិច្ឆ័យ (ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី) ក្នុងរយៈពេល ៣០ ថ្ងៃ ព្រោះវាជាឱកាសចុង ក្រោយដែលចាំបាច់ត្រូវចូលរួមក្នុងនោះមានប្រជាពលរដ្ឋ ៥១ គ្រួសារ ស្មើនឹង ៨៨ ភាគរយដែលបានយល់ ហើយចូលរួម រីឯ ៧ គ្រួសារស្មើនឹង ១២ ភាគរយដែលបានចូលរួមហើយ តែមិនយល់អំពីដំណើរការនេះ។

តារាងទី ១៣ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលបិទផ្សាយ

| ល.រ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | យល់ | ៥១ | ៨៨ |
| ២ | មិនយល់ | ៧ | ១២ |
| | សរុប | ៥៨ | ១០០ |

ប្រភព ៖ ទិន្នន័យវិភាគ

ដ្យាក្រាមទី ៧ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលបិទផ្សាយ




ប្រភព ៖ ទិន្នន័យវិភាគ

### ៤.១១.៩ ដំណាក់កាលសំរេចលើឯកសារនៃការវិនិច្ឆ័យ

ដំណាក់កាលសំរេចលើឯកសារនៃការការវិនិច្ឆ័យ គឺជាការធ្វើរបាយការណ៍លទ្ធផលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យរបស់គណៈកម្មការរដ្ឋបាលជូន អភិបាលខេត្ត រាជធានី ដើម្បីពិនិត្យ និងសំរេច ក្រោយពីអភិបាលខេត្ត រាជធានីចុះហត្ថលេខាហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរចំពោះក្បាលដីណាដែលមិនមានទំនាស់ ឬមិនពាក់ព័ន្ធនឹងដីរដ្ឋដែលបានហាមឃាត់។ ចំពោះក្បាលដីដែលមានវិវាទ ត្រូវបញ្ជូនទៅដោះស្រាយនៅគណៈកម្មការសុរិយោដី ឬតុលាការបន្តទៅទៀត។

### ៤.១១.១០ ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងដំណាក់កាលចេញប័ណ្ណ

ក្រោយពីបានឆ្លងកាត់ដំណាក់កាលទីបួនហើយ ការចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ គឺជាដំណាក់កាលទីប្រាំ ដែលបានត្រូវចែកប័ណ្ណកម្មសិទ្ធិជូនដល់ប្រជាពលរដ្ឋដែលជាម្ចាស់ដីផ្ទាល់។ នៅក្នុងដំណាក់កាលនេះប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានមានការចូលរួមច្រើន ពីព្រោះពួកគាត់ត្រូវមកទទួលយកប័ណ្ណ ដែលក្នុងនោះមានប្រជាពលរដ្ឋចំនួន ៥៦ គ្រួសារស្មើនឹង ៩៧ ភាគរយដែលបានយល់ និងចងចាំ ហើយ ២ គ្រួសារ ស្មើនឹង ៣ ភាគរយដែលមិនមានការយល់ដឹង។

ដ្យាក្រាមទី ៨ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការចេញប័ណ្ណ




ប្រភព ៖ ទិន្នន័យវិភាគ

តារាងទី ១៤ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការចេញប័ណ្ណ

| ល.រ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | យល់ | ៥៦ | ៩៧ |
| ២ | មិនយល់ | ២ | ៣ |
| | សរុប | ៥៨ | ១០០ |

ប្រភព ៖ ទិន្នន័យវិភាគ

**៤.១១.១១ តំលៃសេវានៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ**

ចំពោះតំលៃសេវាក្នុងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ភាគច្រើនប្រជាពលរដ្ឋមានការយល់ដឹង និងមានការចងចាំបានល្អ ដោយនៅក្នុងតំបន់របស់ពួកគាត់ជាតំបន់ជាយទីប្រជុំជនខេត្ត ដូច្នេះតំលៃដីមានតំលៃ ២០ រៀល ក្នុងមួយម៉ែត្រក្រឡា និងដីទីប្រជុំជនខេត្ត តំលៃ ២៥០ រៀល ក្នុងមួយម៉ែត្រក្រឡា ដែលក្នុងនោះមានប្រជាពលរដ្ឋ ៥៤ គ្រួសារ ស្មើនឹង ៩៣ ភាគរយដែរបានយល់ នឹងចងចាំ ហើយមានតែ ៤ គ្រួសារ ស្មើនឹង ៧ ភាគរយដែលមិនបានដឹង។

តារាងទី ១៥ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ នៃតំលៃសេវាក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

| ល.រ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | យល់ | ៥៤ | ៩៣ |
| ២ | មិនយល់ | ៤ | ៧ |
| | សរុប | ៥៨ | ១០០ |

ប្រភព: ទិន្នន័យវិភាគ

ដ្យាក្រាមទី ៩ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ នៃតំលៃសេវាក្នុងការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ




ប្រភព: ទិន្នន័យវិភាគ

### ៤.១១.១២ ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ

ក្នុងចំណោមប្រជាពលរដ្ឋដែលបានសម្ភាសន៍ អំពីផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិបានបង្ហាញអោយឃើញថាមានប្រជាពលរដ្ឋរហូតដល់ ៥៧ គ្រួសារ ស្មើនឹង ៩៨ ភាគរយ បានទទួលស្គាល់ពីផលប្រយោន៍នេះ និងមានត្រឹមតែ ១ គ្រួសា ស្មើនឹង ២ ភាគរយ ដែលមិនបានទទួលស្គាល់ពីផលប្រយោន៍នេះ ព្រោះពួកគេយល់ថាដីនៅតែជាដីរបស់គេ ម្យ៉ាងពួកគេមិនទាន់បានយកដីទៅដាក់ធានាគារដើម្បីខ្ចីប្រាក់ដែរ។

ដ្យាក្រាមទី ១០ ការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ




ប្រភព៖ ទិន្នន័យវិភាគ

តារាងទី ១៦ ភាគរយនៃយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ

| ល.រ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | យល់ | ៥៧ | ៩៨ |
| ២ | មិនយល់ | ១ | ២ |
| សរុប | | ៥៨ | ១០០ |

ប្រភព៖ ទិន្នន័យវិភាគ

### ៤.១១.១៣ ការយល់ដឹងរបស់ប្រជាពលរដ្ឋចំពោះដីដែលមានប័ណ្ណ និង ដីដែលគ្មានប័ណ្ណកម្មសិទ្ធិ

យោងតាមការចុះសិក្សាស្រាវជ្រាវបានអោយដឹងថាមានប្រជាពលរដ្ឋ ៥៦ គ្រួសារដែលស្មើនឹង ៩៧ ភាគរយ ដែលយល់ឃើញថាដីដែលមានប័ណ្ណកម្មសិទ្ធិ គឺងាយស្រួលសំរាប់យកទៅ ដាក់បញ្ចាំ ក្នុងការខ្ចីលុយយកមកប្រើប្រាស់សំរាប់ប្រកបមុខរបរចិញ្ចឹមជីវិតដោយពុំចាំបាច់យក មាស ប្រាក់ គោ ក្របី ទៅលក់ឡើយ ហើយម្យ៉ាងទៀត គាត់យល់ឃើញថានៅពេលដែលពួកគាត់ទទួលបានប័ណ្ណកម្មសិទ្ធិនោះ ហើយវានឹងធ្វើអោយដីនៅក្នុងតំបន់មានតំលៃ កាន់តែខ្ពស់ ហើយក៏ពុំភ័យខ្លាចមានជនខិលខូចមកលួចធ្វើប្លង់ នៅលើក្បាលដីរបស់ពួកគាត់ ឬត្រូវបាត់បង់ដោយការ រំលោភបំពានណាមួយពីសំណាក់អ្នកមានអំណាចឡើយ ព្រោះក្បាលដីទាំងអស់ត្រូវបានធ្វើការចុះបញ្ជី ដោយបានធ្វើ ការកត់ត្រាយ៉ាងច្បាស់លាស់ ហើយត្រូវបានដំកល់ទុកយ៉ាងត្រឹមត្រូវ និងមានសុវត្ថិភាព។ ចំណែកឯប្រជាពលរដ្ឋ ២ គ្រួសារដែលស្មើនឹង ៣ ភាគរយផ្សេងទៀតគិតថាដីដែលគ្មានប័ណ្ណ គឺងាយស្រួលជាងសំរាប់ពួកគាត់ ដោយពុំចាំបាច់ ចំណាយពេលវេលាទៅចូលរួមក្នុងការចុះបញ្ជី ដែលជាហេតុធ្វើអោយបាត់បង់ការរក

ស៊ីរបស់ពួកគាត់ និងពុំមានជន ណាមួយអាចមកដណ្តើមយកដីរបស់ពួកគាត់បានឡើយ ត្បិតដីនេះពួកគាត់បានកាន់កាប់ជាយូរមកហើយ។

តារាងទី ១៩ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ចំពោះដីដែលមានប័ណ្ណ និងដីដែលគ្មានប័ណ្ណ

| ល.រ | ការយល់ដឹងរបស់ប្រជាពលរដ្ឋ | ចំនួនគ្រួសារ | ភាគរយនៃការយល់ដឹង |
|---|---|---|---|
| ១ | យល់ | ៥៦ | ៩៧ |
| ២ | មិនយល់ | ២ | ៣ |
| | សរុប | ៥៨ | ១០០ |

ប្រភព: ទិន្នន័យវិភាគ

ដ្យាក្រាមទី ១១ ភាគរយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ចំពោះដីដែលមានប័ណ្ណ និងដីដែលគ្មានប័ណ្ណ




ប្រភព: ទិន្នន័យវិភាគ

## ៤.១២ បញ្ហាជួបប្រទះនៅក្នុងដំណើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

ដំណើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានជួនប្រទះនូវបញ្ហាមួយចំនួនដូចជា៖

- ការកំណត់ព្រំ និងការវាស់វែង ៖ មានការលំបាកដោយសារតែក្បាលដីមួយចំនួននៅក្នុងភូមិមានម្ចាស់ ច្រើនមកចង្អុលបង្ហាញមិនត្រឹមត្រូវ មិនដឹងថាព្រំប្រទល់ដីដល់ចំនុចណា ចង្អុលរហូតដល់ដីរបស់ម្ចាស់ផ្សេងហើយ ម្យ៉ាងទៀតម្ចាស់ដីកាលពីមុនបានយកដីរបស់ខ្លួនទៅដាក់បញ្ចាំ អោយបុគ្គលម្នាក់ទៀតនៅក្នុងភូមិ រហូតដល់ មានការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ម្ចាស់ដីបាននាំមន្ត្រីទៅធ្វើការវាស់វែងដីធ្លីរបស់ខ្លួន ស្រាប់តែបុគ្គលម្នាក់ ដែលទទួលបញ្ចាំដី ឆ្លើយថាដីនេះជាដីរបស់ខ្លួន ដែលគាត់បានទិញ

កាលពីឆ្នាំមុន។ ដូច្នេះហើយទើបធ្វើអោយ ដំណើការវាស់វែងមិនអាចដំណើការទៅបានដោយរង់ចាំការដោះស្រាយ។

- ការវិនិច្ឆ័យ៖ មានបញ្ហាដោយសារកំរិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ នៅខ្សោយ ជាហេតុនេះហើយ មានប្រជាជនមួយចំនួនមិនស្គាល់ឈ្មោះប្តី ឬប្រពន្ធ ម្តាយ ឬឪពុកបង្កើតរបស់ខ្លួន។ ម្យ៉ាងទៀតឯកសារផ្សេងៗ ដែលត្រូវប្រើប្រាស់ក្នុងការបំពេញទំរង់បែបបទរបស់ប្រជាពលរដ្ឋមានឈ្មោះ និងត្រកូលមិនដូចគ្នា ហេតុនេះហើយ ប្រសិនបើចាំបាច់ត្រូវចំណាយពេលដូរឈ្មោះ និងត្រកូលអោយដូចគ្នា។
- ការងារក្នុងការិយាល័យ៖មានបញ្ហាខ្លះដោយសារតែម្ចាស់ដីម្នាក់មានក្បាលដីច្រើនកន្លែងដែលឋិតនៅក្នុងភូមិមួយហើយទំរង់បែបបទនៃក្បាលដីទាំងអស់មានឈ្មោះម្តាយ និងឪពុកផ្សេងគ្នា ។
- ការបិទផ្សាយ៖ គឺមិនមានបញ្ហាអ្វីគួរអោយគត់សំគាត់នោះទេ ពីព្រោះបើមានការមន្ទិលសង្ស័យនូវទិន្នន័យណាមួយ គឺមានមន្ត្រីម្នាក់ដែលនៅទទូលខុសត្រូវក្នុងការពន្យល់ណែនាំបងប្អូនប្រជាពលរដ្ឋអោយបានយល់។
- ចំពោះក្រុមការងារ៖ គឺមិនមានបញ្ហាអ្វីចោទនោះឡើយ។

## ៤.១៣ ការពិភាក្សា

ការយល់ដឹងជាសាធារណៈ និងការចូលរួមពីសហគមន៍មានចំណុចសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការចុះទៅតាមដានសកម្មភាពការងារផ្សព្វផ្សាយ ពង្រឹងសមត្ថភាពរបស់មន្ត្រីផ្សព្វផ្សាយ និងវិធីសាស្ត្រនៃការផ្សព្វផ្សាយ ដែលអនុវត្តឲ្យកាន់តែប្រសើរឡើងថែមទៀត ៖

- សកម្មភាពមន្ត្រីផ្សព្វផ្សាយដែលបានអនុវត្តសព្វថ្ងៃ ភាគច្រើនមន្ត្រីផ្សព្វផ្សាយយល់ឃើញថាភារកិច្ចរបស់ខ្លួនជាចំបងគឺជាសកម្មភាពគាំទ្រដល់ការងាររបស់មន្ត្រីក្រុមចុះបញ្ជីដីធ្លី ដូចជា ការប្រមូលប្រជាពលរដ្ឋឲ្យមកចូលរួមក្នុងការកំណត់ព្រំ វាស់វែង និងការវិនិច្ឆ័យ ជាជាងធ្វើការផ្សព្វផ្សាយឲ្យប្រជាពករដ្ឋយល់ច្បាស់ពីសារៈប្រយោជន៍នៃការចុះបញ្ជីដី និងផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ។
- ស្របតាមការយល់ដឹងភាគច្រើន និងរបៀបអនុវត្តជាក់ស្តែងបច្ចុប្បន្ននេះ សមាសភាគរង និងការចូលរួមពីសហគមន៍ ផ្តោតការយកចិត្តទុកដាក់ចំពោះការផ្សព្វផ្សាយព័ត៌មាន ដែលទាក់ទងនឹងទិដ្ឋភាពច្បាប់ និងរដ្ឋបាលនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ។
- វិធីសាស្ត្រផ្តល់ព័ត៌មាន និងសម្ភារៈដែលរៀបចំឡើងដើម្បីបម្រើគោលបំណងផ្តល់ព័ត៌មានជារួមរៀបចំបានល្អ ប៉ុន្តែពុំសូវបានយកទៅប្រើប្រាស់ឲ្យទូលំទូលាយទេ។ ពុំមានវិធីសាស្ត្រទៀងទាត់ និងស៊ីសង្វាក់គ្នាដើម្បីវាស់វែងការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីព័ត៌មានដែលបានផ្សព្វផ្សាយនៅអំឡុងពេលពេលប្រមូលផ្តុំជួបប្រជុំទេ។
- ការយល់ដឹងជាសាធារណៈ និងការចូលរួមលើការផ្សព្វផ្សាយជាសាធារណៈរបស់ម្ចាស់ដី

និងភាគីដែលពាក់ព័ន្ធបានគាំទ្រដល់ការងារផ្តល់កម្មសិទ្ធិដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធតាមរយៈការផ្សព្វផ្សាយព័ត៌មាន។ ប៉ុន្តែត្រូវមានការរៀបចំផែនការ ការអនុវត្ត និងការគ្រប់គ្រងឲ្យបានត្រឹមត្រូវ។

- មន្រ្តីផ្សព្វផ្សាយនៅខ្វះខាតសម្ភារៈដើម្បីចងក្រងឯកសារ ឬរបាយការណ៍ពីចំណុចខ្លាំង និងចំណុចខ្សោយតាមការចុះបញ្ជីដីដែលមានលក្ខណៈជាប្រព័ន្ធ។ ជាលទ្ធផលការរៀនសូត្រនេះនៅមានកម្រិតទាប ហើយពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើការបណ្តុះបណ្តាលរំលឹកបន្ថែម ដែលត្រូវធ្វើឡើងឲ្យបានញឹកញាប់បំផុត។

# ជំពូក ៥

# សន្និដ្ឋាន និងអនុសាសន៍

# ជំពូក ៥
# សន្និដ្ឋាន និងអនុសាសន៍

## ៥.១ សន្និដ្ឋាន

បន្ទាប់ពីបានធ្វើការចុះស្រាវជ្រាវ និង វិភាគទិន្នន័យអាចធ្វើការសន្និដ្ឋានបានថា ក្នុងចំណោមភូមិពីរ នៃ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ដែលបានលើកយកមកសិក្សានេះ គឺសុទ្ធតែជាភូមិដែលមាន ប្រជាពលរដ្ឋភាគច្រើនជាអ្នក រកស៊ី និងធ្វើការ។

នៅពេលដែលការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធត្រូវបានចាប់ផ្តើមក្នុងតំបន់នោះ ការផ្សព្វផ្សាយ ព័ត៌មានត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយអំពីច្បាប់ភូមិបាល ( សិទ្ធិ និង ការតព្វកិច្ច ) បែបបទនៃការចុះបញ្ជីដីធ្លី ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ និង អំពីផែនទីភូមិ គឺធ្វើយ៉ាងណាអោយពួកគាត់មានការយល់ដឹងគ្រប់ៗគ្នា ហើយ នាំគ្នាត្រៀមរៀបចំទុកជាមុននូវឯកសារចាំបាច់ ដែលជាតំរូវការរបស់មន្ត្រីកំណត់ព្រំ វាស់វែង និងវិនិច្ឆ័យ ហើយ ជាមួយគ្នានោះដែលក៏ត្រូវមានការកំណត់ព្រំប្រទល់ក្បាលឱ្យបានច្បាស់ជាមួយអ្នកជិតមានព្រំប្រទល់ជាប់រួចរាល់ ស្រេច នៅពេលដែលមន្ត្រីបច្ចេសទេសចុះទៅដល់។

ក្រោយពេលដែលការផ្សព្វផ្សាយត្រូវបានបញ្ចប់ តាមការអង្កេតបានបង្ហាញអោយឃើញថាមាន ប្រជាពលរដ្ឋមួយចំនួនមានការយល់ដឹង និងចងចាំពីដំណាក់កាលនីមួយៗនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជា ប្រព័ន្ធ អាស្រ័យទៅលើការចូលរួមរបស់ប្រជាពលរដ្ឋនៅតាមភូមិនីមួយៗក្នុងតំបន់នោះ។ ជាក់ស្តែងនៅក្នុង ចំណោម

ប្រជាពលរដ្ឋ ៦១ គ្រួសារដែលបានត្រូវជួបសំភាសន៏នូវក្នុងភូមិទាំងពីរបង្ហាញថា ការផ្សព្វផ្សាយពិតជាមានសារៈ សំខាន់ហើយប្រជាជនមានកំរិតយល់ដឹងច្រើនចំពោះ ៖

- ការផ្សព្វផ្សាយគឺជា ដំណើរការមួយដែលផ្តល់នៅសារៈប្រយោជន៏ជាច្រើនដល់ប្រជាពលរដ្ឋ ចំនួន ៥៨ គ្រួសារ ស្មើនឹង ៩៥ភាគរយ គិតថាមានប្រយោជន៏សំរាប់ពួកគាត់។ ចំណែក៣គ្រួសារទៀត ស្មើនិង ៥ភាគរយមិនសូវជាគិតចំពោះបញ្ហានេះ ហើយពួកគេគិតជាវាមិនបានប្រយោជន៏អ្វីដល់ពួកគេ។
- តាមរយៈការសំភាសន៏បានបង្ហាញអោយឃើញថា មានប្រជាពលរដ្ឋ ៥៦គ្រួសារ ស្មើនឹង ៩២ ភាគ រយ មានការយល់ដឹងច្រើនដោយគិតថាដីដែលមានកម្មសិទ្ធិមានភាពងាយស្រួលប្រើប្រាស់ ចំណែក ៥ គ្រួសារ ទៀតស្មើនឹង ៨ ភាគរយ គិតថាមិនចាំបាច់មានប័ណ្ណក៏បាន។
- ផលប្រយោជន៏នៃប័ណ្ណកម្មសិទ្ធិ ក្នុងចំណោម ៥៨ គ្រួសារ ស្មើនឹង ៩៥ ភាគរយ គិតថាមានផល ប្រយោជន៏ខ្លាំង ហើយក៏មានប្រជាពលរដ្ឋ៣គ្រួសារទៀត ស្មើនិង ៥ ភាគរយ គិតថាមិនសូវមាន ប្រយោជន៏សំរាប់ពួកគេទេ។

សរុបសេចក្តីមក ការផ្សព្វផ្សាយពីការយល់ដឹងជាសាធារណៈ និងការចូលរួមមានសារៈប្រយោជន៏ណាស់ សំរាប់ប្រជាពលរដ្ឋក្នុងតំបន់ ដែលធ្វើអោយពួកគាត់មានការយល់ដឹង ពីសិទ្ធិក្នុងការកាន់កាប់ និង ប្រើប្រាស់ដីក្នុង ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

## ៥.២ អនុសាសន៍

តាមការចុះសិក្សាមកនេះ នាងខ្ញុំសូមផ្តល់ជាអនុសាសន៍ ចំពោះគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី និងដល់មន្ត្រីផ្សព្វផ្សាយដែលកំពុងអនុវត្តការងារនៅតាមបណ្តាខេត្តក្រុងសម្រាប់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធដូចតទៅ៖

- ត្រូវពិនិត្យ និងការកែសម្រួលសម្ភារៈ ៖ គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី គួរខិតខំជាប់ជាបន្តនិងរួមគ្នាដើម្បីរក្សាភាពសមស្របនៃសម្ភារៈដែលត្រូវប្រើប្រាស់។ ព័ត៌មានដែលត្រូវផ្តល់ជូនដល់អាជ្ញាធរមូលដ្ឋាន និងម្ចាស់ដីនៅក្នុងតំបន់វិនិច្ឆ័យ ត្រូវផ្សព្វផ្សាយជាលំដាប់លំដោយ (អនុវត្តតាមជំហាននៃដំណើរការចុះបញ្ជីដីធ្លី) ដោយប្រើប្រាស់មធ្យោបាយទំនាក់ទំនងតាមរយៈរូបភាព។
- ត្រូវមានការចុះតាមដាន ហើយត្រូវបែងចែកការទទួលខុសត្រូវដល់មន្ត្រីម្នាក់ៗ ដើម្បីជៀសវាងការផ្សព្វផ្សាយមិនបានទូលំទូលាយ និងស៊ីជម្រៅដល់ប្រជាពលរដ្ឋ។
- រៀបចំកែលម្អ និងពង្រឹងសមត្ថភាពដល់មន្ត្រីផ្សព្វផ្សាយ
- ត្រូវចូលរួមជាប់ជាប្រចាំក្នុងបណ្តាញការងារ ៖ ដើម្បីធានានិរន្តរភាពការងារផ្សព្វផ្សាយ គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី ត្រូវចាត់វិធានការសមស្រប ដើម្បីចូលរួមជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត (ដូចជា ក្រសួង មន្ទីរ អង្គការក្រៅរដ្ឋាភិបាល ក្រុមសង្គមស៊ីវិល។ល។)។

ការបណ្តុះបណ្តាលមន្ត្រីផ្សព្វផ្សាយ ៖ ក្រៅពីការបណ្តុះបណ្តាលទូទៅអំពីច្បាប់ភូមិបាល និងការផ្តល់កម្មសិទ្ធិដីធ្លី មន្ត្រីផ្សព្វផ្សាយគួរបានទទួលការបណ្តុះបណ្តាលអុះពីជំនាញសម្របសម្រួល និងការទំនាក់ទំនងចាមួយសហគមន៍ផងដែរ។ ការងារតាមផ្នែក/វិស័យ ដូចជាអភិវឌ្ឍន៍សហគមន៍ និងការគ្រប់គ្រងការប្រើប្រាស់ដីជាដើម អាចនឹងមានប្រយោជន៍សម្រាប់រយៈពេលយូរអង្វែង។

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

**មហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី**



# ព្រឹត្តិបត្រព័ត៌មាននិស្សិត
# ការពារសារណាបញ្ចប់ការសិក្សានៃមហាវិទ្យាល័យ
# រៀបចំដែនដី និងរដ្ឋបាលដីធ្លី ជំនាន់ទី១០

នាម និងគោត្តនាម ៖ ថោន បញ្ញាវត្តី អក្សរឡាតាំង ៖ THON PANHAVATEY
ថ្ងៃ ខែ ឆ្នាំកំណើត ៖ ២៩ កញ្ញា ១៩៩៤
ទីកន្លែងកំណើត ៖ ភូមិបន្ទាយចាស់ ឃុំ ស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប
មានគ្រួសារ រឺនៅលីវ ៖ នៅលីវ
ឪពុកឈ្មោះ ៖ ង៉ោ ប៊ុនថោន មុខរបរ ៖ គ្រូពេទ្យ
ម្តាយឈ្មោះ ៖ ញឹម ស៊ីឡៃន មុខរបរ ៖ (ស្លាប់)
ទីលំនៅបច្ចុប្បន្ន ៖ ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
ប្រធានសារណាបទ ៖ ការផ្សព្វផ្សាយពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប
៖ THE DISSEMINATION PROCEDURE OF SYSTEMMATIC IN SANGKAT KOUK CHAK , KRONG SIEM REAP, SIEM REAP PROVINCE
ចំនួនទំព័រនៃសារណាបទ ៖ ទំព័រ ៥៦
សាស្ត្រាចារ្យដឹកនាំ ៖ **លោក សំ សុមនោ**
សាស្ត្រាចារ្យជំនួយការ ៖ **លោក រឹង សេដ្ឋា**
សាស្ត្រាចារ្យជំនួយការ ៖ **លោក ពិន សុខខន**
កាលបរិច្ឆេទនៃការចងក្រងសារណាបទ ៖ ថ្ងៃទី............ខែ..............ឆ្នាំ២០១៥
កាលបរិច្ឆេទនៃការការពារគម្រោងសារណាបទ ៖ ថ្ងៃទី............ខែ..............ឆ្នាំ២០១៥

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៥
ហត្ថលេខា

ថោន បញ្ញាវត្តី